ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្លឿនការសិក្សា

ភាសាខ្មែរ

ថ្នាក់ឆ្នាំទី ៣



សម្រាប់គ្រូបង្រៀន

ព.ស. ២៥៥៨ គ.ស. ២០១៤



ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

គណិតវិទ្យា

ថ្នាក់ឆ្នាំទី ៣

ឯកសារសម្រាប់គ្រូ

បោះពុម្ពលើកទី ២

ឆ្នាំ ២០១៥

គណៈកម្មការត្រួតត្រង

ឯកឧត្តម ណាត ប៊ុនរឿន	លោក អ៊ុក សុវណ្ណ
ឯកឧត្តម អ៊ឹម កុច	លោក ចាន់ សុភា
ឯកឧត្តម សំ សេរីរតន៍	លោក ជា វណ្ណេត

គណៈកម្មការនិពន្ធ

លោកស្រី ទូច សុភាព	លោកស្រី ឡាច កញ្ញា
លោកស្រី ហ៊ុន សុជាតិ	លោក ធន់ សាមិត្ត
លោកស្រី សាន ណារ៉ា	លោក សួន សាម៉ែត
លោកស្រី ចក់ វណ្ណា	

អ្នករៀបរៀងនិងរចនាចំពីរ

លោកស្រី ខ្វង់ គឹមទូច	លោក អាន រ៉ូប្រាវ

គណៈកម្មការត្រួតពិនិត្យ

លោក ជា វណ្ណេត	លោកស្រី ខ្វង់ គឹមទូច
លោក អាន រ៉ូប្រាវ	លោកស្រី មិន វិចិត្រា

បញ្ជីអត្ថបទ

អារម្ភកថា ១
ផ្នែកទី១៖ បំណែងចែកកម្មវិធីសិក្សា ២
ផ្នែកទី២៖ អត្ថបទស្តាប់ ៧
ផ្នែកទី៣៖ លំនាំនៃការបង្រៀន ១៧
ផ្នែកទី៤៖ សលាកប័ត្រជំពូកនិងមេរៀន ២៦
ជំពូកទី១ : វីរជនឆ្នើម ២៧
ជំពូកទី២ : សម្បត្តិអក្សរសិល្ប៍ ៣៣
ជំពូកទី៣ : កំណាព្យខ្មែរ ៣៩
ជំពូកទី៤ : ប្រយោជន៍នៃសារព័ត៌មាន ៤៤
ជំពូកទី៥ : ស្មារតីទទួលខុសត្រូវ ៤៨
ជំពូកទី៦ : អតីតកាលរបស់យើង ៥៣
ជំពូកទី៧ : ទូរគមនាគមន៍នៅកម្ពុជា ៥៧
ជំពូកទី៨ : ផលិតផលខ្មែរ ៦១
ជំពូកទី៩ : ពេលវេលាជាមាសប្រាក់ ៦៥
ជំពូកទី១០ : ប្រយោជន៍នៃវិទ្យាសាស្ត្រ ៦៨
ជំពូកទី១១ : អ្នកមានគុណ ៧២
ជំពូកទី១២ : ក្តីសង្ឃឹមរបស់កុមារ ៧៦
ជំពូកទី១៣ : ធនធានរ៉ែនៅប្រទេសកម្ពុជា ៨២
ជំពូកទី១៤ : ប្រយោជន៍នៃធម្មជាតិ ៨៨
ជំពូកទី១៥ : ធនធានដលផលនៅកម្ពុជា ៩៤
ជំពូកទី១៦ : ទំនៀមទម្លាប់ប្រពៃណីខ្មែរ ៩៩
ជំពូកទី១៧ : តន្ត្រីនិងសិល្បៈបុរាណ ១០៥
ជំពូកទី១៨ : ជំនឿនិងសាសនា ១០៨
ជំពូកទី១៩ : រមណីយដ្ឋានទេសចរណ៍នៅកម្ពុជា ១១៣
ជំពូកទី២០ : សេចក្តីថ្លៃថ្នូរ ១១៦

អារម្ភកថា

ឯកសារជំនួយគ្រូមុខវិជ្ជាភាសាខ្មែរ ថ្នាក់ឆ្នាំទី៣ នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការ រវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអង្គការដើម្បីភាពញញឹមនៃកុមារ នៅក្នុងគម្រោងចងក្រងសៀវភៅពន្លឿនការសិក្សាសម្រាប់សាលាបឋមសិក្សា។ ឯកសារនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មការនិពន្ធក្នុងគម្រោងនេះ និងដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សា នៅអង្គការដើម្បីភាពញញឹមនៃកុមារ។

ឯកសារនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការបង្រៀន មុខវិជ្ជាភាសាខ្មែរថ្នាក់ឆ្នាំទី៣ របស់លោកគ្រូអ្នកគ្រូ។ ខ្លឹមសារសំខាន់នៃឯកសារនេះ មានការបង្ហាញពីកម្មវិធីពន្លឿនការសិក្សានៅសាលាបឋមសិក្សា លំនាំនៃការបង្រៀន តាមសមត្ថភាពនីមួយៗនិងសលាកប័ត្រជំពូកនិងមេរៀនពិសេស ផ្តោតទៅលើចម្លើយរបស់សំណួរ និងកំណែលំហាត់ដែលផ្តល់នូវភាពងាយស្រួលសម្រាប់លោកគ្រូអ្នកគ្រូ ក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។

ក្នុងការបង្រៀន គណៈកម្មការយើង មិនទាមទារឱ្យលោកគ្រូអ្នកគ្រូអនុវត្តឯកសារនេះទាំងស្រុងនោះទេ។ ប៉ុន្តែកត្តាសំខាន់គឺជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រពៃ ដោយពឹងផ្អែកលើចំណេះដឹង បទពិសោធក្នុងការរៀបចំវិធីបង្រៀន បំណិនប្រសប់ក្នុងការប្រើប្រាស់វាក្យស័ព្ទ និងសម្ភារឧបទេសក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។

ក្រោយពីបញ្ចប់មេរៀននីមួយៗ លោកគ្រូអ្នកគ្រូធ្វើរង្វាយតម្លៃលើកម្រិតយល់ដឹងរបស់សិស្ស ដោយធ្វើសំណួរសរសេរ ឬសំណួរផ្ទាល់មាត់ ឬលំហាត់អនុវត្ត ព្រោះវាអាចបង្ហាញឱ្យគ្រូដឹងពីលទ្ធផលបង្រៀន ដើម្បីឱ្យលោកគ្រូអ្នកគ្រូជ្រើសរើសនិងកែសម្រួលវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារជំនួយគ្រូភាសាខ្មែរថ្នាក់ឆ្នាំទី៣នេះនឹងបានជាប្រយោជន៍ច្រើនដល់ការបង្រៀនរបស់គ្រូ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពរៀននិងបង្រៀនប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការនិពន្ធ

ផ្នែកទី១
បំណែងចែកកម្មវិធីសិក្សា

កម្មវិធីសិក្សាថ្នាក់ពន្លឿនការសិក្សា មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ឆ្នាំទី៣នេះ គឺជាការសំយោគបញ្ចូលគ្នា រវាងកម្មវិធីសិក្សា មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ទី៥ និងថ្នាក់ទី៦ នៃកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ឆ្នាំទី៣នេះ មានចំនួន១៣ម៉ោងសិក្សា ក្នុង១សប្តាហ៍ ដែល១ម៉ោងសិក្សាមានរយៈពេល៤០នាទី។

ជំពូក	មេរៀន	ប្រភេទមេរៀន	ចំណងជើងមេរៀន	រយៈពេល
ទី១៖ វីរជនឆ្នើម	១	បំណិន	ការប្រើវចនានុក្រម	១ម៉
	២	បំណិន	ការប្រៀបធៀបតួអង្គ	២ម៉
	៣	ស្តាប់	រឿង ចចកនិងកំពឹស	២ម៉
	៤	វេយ្យាករណ៍	គុណនាមប្រក្រតី	១ម៉
	៥	អំណាន	សម្តេចព្រះសង្ឃរាជ ជួន ណាត	២ម៉
	៦	និយាយ	ការពណ៌នាអំពីជនគំរូ	២ម៉
	៧	អំណាន	វីរបុរសក្រឡាហោមគង់	២ម៉
	៨	បំណិន	វេចនសព្ទនិងបដិសព្ទ	១ម៉
	៩	សំណេរ	ការពណ៌នាអំពីតួអង្គ	២ម៉
ទី២៖ សម្បត្តិអក្សរសិល្ប៍	១	បំណិន	ការឆ្លើយនឹងសំណួរដោយផ្អែកលើអំណៈអំណាង	២ម៉
	២	អំណាន	រឿង ភ្នំប្រុស ភ្នំស្រី	២ម៉
	៣	ស្តាប់	រឿង ក្រពើនិងអ្នកបរទេះ	២ម៉
	៤	វេយ្យាករណ៍	គុណនាមកំណត់	១ម៉
	៥	បំណិន	សទិសសព្ទ (ពាក្យសូរដូច)	២ម៉
	៦	និយាយ	ការនិទានរឿងឡើងវិញ	២ម៉
	៧	សំណេរ	ការតាក់តែងរឿងខ្លី	២ម៉
ទី៣៖ កំណាព្យខ្មែរ	១	បំណិន	ពាក្យចួន	២ម៉
	២	អំណាន	មេសូត្រៈ លម្អបីប្រការ (បទពាក្យប្រាំពីរ)	២ម៉
	៣	វេយ្យាករណ៍	គុណនាមកម្មសិទ្ធ	២ម៉
	៤	បំណិន	គំនិតសំខាន់របស់អត្ថបទ	២ម៉
	៥	អំណាន	កំណាព្យខ្មែរ	២ម៉
	៦	អំណាន	មេសូត្រៈ ឆ្គួតបីប្រការ	២ម៉
ទី៤៖ ប្រយោជន៍នៃសារព័ត៌មាន	១	អំណាន	ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល	២ម៉
	២	ស្តាប់	បទសម្ភាស	២ម៉
	៣	អំណាន	បំណងរបស់ខ្ញុំ	២ម៉
	៤	និយាយ	ការសម្ភាស	២ម៉
	៥	សំណេរ	ការសរសេរអត្ថបទសារព័ត៌មាន	២ម៉
ទី៥៖ ស្មារតីទទួលខុសត្រូវ	១	បំណិន	ការសង្ខេបព័ត៌មាន	២ម៉
	២	អំណាន	រឿង ជីតាថាដូ	២ម៉
	៣	ស្តាប់	ភ្លៀងធ្លាក់និងខ្យល់ព្យុះនៅខេត្តកំពង់ស្ពឺ	២ម៉
	៤	វេយ្យាករណ៍	សព្វនាមបុរិសៈ	១ម៉

	៥	បំណិន	ព្រឹត្តិការណ៍ពិតនិងព្រឹត្តិការណ៍ប្រឌិត	២ម៉
	៦	អំណាន	សេចក្តីជូនដំណឹងអំពី " បាតុភូតអាកាសធាតុ "	២ម៉
	៧	សំណេរ	សេចក្តីជូនដំណឹង	២ម៉
ទី៦៖ អតីតកាលរបស់យើង	១	អំណាន	បំភ្លេចមិនបាន	២ម៉
	២	ស្តាប់	ខ្ញុំសាកល្បង	២ម៉
	៣	វេយ្យាករណ៍	សញ្ញារះមុខ " ◌ៈ "	២ម៉
	៤	អំណាន	ប្រាសាទព្រះវិហារ	២ម៉
	៥	អំណាន	ស្រមោលអតីតកាល	២ម៉
	៦	សំណេរ	កំណត់ត្រាប្រចាំថ្ងៃ	២ម៉
ទី៧៖ ទូរគមនាគមន៍នៅកម្ពុជា	១	បំណិន	ការផ្តល់មូលហេតុដើម្បីគាំទ្រមតិ ដកស្រង់ចេញពីសំបុត្រ	២ម៉
	២	វេយ្យាករណ៍	កម្រិតគុណនាម	២ម៉
	៣	ស្តាប់	សំបុត្រផ្ទាល់ខ្លួន	២ម៉
	៤	វេយ្យាករណ៍	ឈ្នាប់ ឬចំណងឈ្នាប់	២ម៉
	៥	អំណាន	រឿង កំណើតទូរស័ព្ទ	២ម៉
	៦	សំណេរ	សំបុត្រសួរសុខទុក្ខ	២ម៉
	៧	សំណេរ	សំបុត្រសូមអភ័យទោស	២ម៉
ទី៨៖ ផលិតផលខ្មែរ	១	បំណិន	ប្រធានបទនៃអត្ថបទ	២ម៉
	២	អំណាន	ផលិតផលនៅប្រទេសកម្ពុជា	២ម៉
	៣	បំណិន	ការឃោសនា	២ម៉
	៤	អំណាន	ដំណឹងពិសេស	២ម៉
	៥	វេយ្យាករណ៍	ប្រធាននិងកិរិយាបង្គោល	២ម៉
	៦	អំណាន	បទបង្ហាញអំពីផលិតផលក្នុងខ្មែរ	២ម៉
	៧	សំណេរ	អត្ថបទឃោសនា	២ម៉
ទី៩៖ ពេលវេលាជាមាសប្រាក់	១	អំណាន	មេសូត្រ៖ តម្លៃនៃពេលវេលា (បទពាក្យប្រាំពីរ)	២ម៉
	២	ស្តាប់	វិជ្ជាជាឃ្លាំងទ្រព្យ	២ម៉
	៣	វេយ្យាករណ៍	សញ្ញាចុចពីរ (◌:)	១ម៉
	៤	សំណេរ	ការតែងកំណាព្យបទពាក្យប្រាំពីរ	២ម៉
ទី១០៖ ប្រយោជន៍នៃវិទ្យាសាស្ត្រ	១	ស្តាប់	រឿង ចៅប្រាក់ភ្នែកបី	២ម៉
	២	វេយ្យាករណ៍	សញ្ញាឧទាន (!)	១ម៉
	៣	អំណាន	ប្រដាប់ជំនួយត្រចៀក	២ម៉
	៤	និយាយ	ការផ្តល់ការណែនាំផ្ទាល់មាត់	២ម៉
	៥	សំណេរ	ការណែនាំច្រើនជំហាន	២ម៉
ទី១១៖ អ្នកមានគុណ	១	អំណាន	មេសូត្រ៖ កតញ្ញូប្រាំប្រការ (បទពាក្យប្រាំពីរ)	២ម៉
	២	សំណេរ	ពណ៌នាអំពីមនុស្ស	២ម៉

	៣	បំណិន	ការកត់ត្រាគំនិតសំខាន់ៗនៅក្នុងកំណាព្យ	២ម៉
	៤	វេយ្យាករណ៍	គុណនាមចំនួន	២ម៉
	៥	អំណាន	រឿង បងប្រុស	២ម៉
ទី១២៖ ក្តីសង្ឃឹមរបស់កុមារ	១	បំណិន	ការសង្ខេបរឿង	២ម៉
	២	អំណាន	រឿង បងប្អូនពីរនាក់	២ម៉
	៣	ស្តាប់	រឿង ទឹកចិត្តមេមាន់	២ម៉
	៤	អំណាន	រឿង អ្នកគ្រូរបស់គុណ	២ម៉
	៥	វេយ្យាករណ៍	គុណនាមសំណួរ	១ម៉
	៦	សំណេរ	សំណេរបាយការណ៍ស្តីពីអំណាន រឿងសម្រាប់អ្នកស្តាប់	២ម៉
ទី១៣៖ ធនធានរ៉ែនៅប្រទេសកម្ពុជា	១	បំណិន	ការកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន	២ម៉
	២	អំណាន	ធនធានធម្មជាតិនៅក្នុងដី	២ម៉
	៣	ស្តាប់	ត្បូងពណ៌ស្វាយមួយគ្រាប់	២ម៉
	៤	វេយ្យាករណ៍	គុណនាមចង្អុល	១ម៉
	៥	អំណាន	រ៉ែប្រេងកាត	២ម៉
	៦	អំណាន	រ៉ែមាសនៅកម្ពុជា	២ម៉
	៧	សំណេរ	អត្ថបទព័ត៌មានខ្លី	២ម៉
ទី១៤៖ ប្រយោជន៍នៃធម្មជាតិ	១	បំណិន	ព្រឹត្តិការណ៍រឿង	២ម៉
	២	អំណាន	រឿង ការភ្ញាក់រលឹករបស់ **អ៊ំ សែម**	២ម៉
	៣	ស្តាប់	រឿង ស្រីកណ្តុរល្អោច	២ម៉
	៤	វេយ្យាករណ៍	កិរិយាអកម្ម	១ម៉
	៥	អំណាន	យើងរួមគ្នាថែរក្សាបរិស្ថាន	២ម៉
	៦	វេយ្យាករណ៍	សញ្ញាផាត់លើ ឬសំយោគសញ្ញា	១ម៉
	៧	និយាយ	ការពណ៌នាអំពីប្រយោជន៍នៃព្រៃឈើ	២ម៉
	៨	សំណេរ	សំណេររឿងនិទាន	២ម៉
ទី១៥៖ ធនធានដីលផលនៅកម្ពុជា	១	បំណិន	តម្លៃអប់រំនៃរឿង	២ម៉
	២	អំណាន	រឿង វាសនាបឹងទន្លេសាប	២ម៉
	៣	សំណេរ	អត្ថបទពណ៌នា	២ម៉
	៤	ស្តាប់	រឿង ដើមកំណើតសត្វផ្សោត	២ម៉
	៥	វេយ្យាករណ៍	កិរិយាសកម្ម	១ម៉
	៦	អំណាន	រឿង សុបិនចម្លែក	២ម៉
	៧	និយាយ	ការរៀបរាប់ពីធនធានដីលផល	២ម៉
	៨	សំណេរ	ការរៀបរាប់ឡើងវិញព្រឹត្តិការណ៍មួយក្នុងរឿង	២ម៉
ទី១៦៖ ទំនៀមទម្លាប់	១	អំណាន	ពិធីបំបួសនាគ	២ម៉
	២	វេយ្យាករណ៍	សញ្ញាវង់ក្រចក (…)	១ម៉

ប្រពៃណីខ្មែរ	៣	អំណាន	រឿង ទំនៀមទម្លាប់ដាក់ប្រាក់កាក់ក្នុងមាត់អ្នកស្លាប់	២ម៉	
	៤	និយាយ	ការបញ្ចេញមតិ	២ម៉	
	៥	សំណេរ	ការពណ៌នាអំពីពិធីផ្សេងៗ	២ម៉	
ទី១៧៖ តន្ត្រីនិង សិល្បៈបុរាណ	១	អំណាន	របាំក្លោក	២ម៉	
	២	វេយ្យាករណ៍	សព្វនាមសំណួរ	១ម៉	
	៣	អំណាន	របាំត្រុដិ	២ម៉	
ទី១៨៖ ជំនឿនិង សាសនា	១	អំណាន	កំណាព្យ៖ ព្រះពុទ្ធសាសនា (បទពាក្យប្រាំពីរ)	២ម៉	
	២	ស្តាប់	កំណាព្យ៖ អ្នកបួសតាមពុទ្ធសាសនា (បទកាកគតិ)	២ម៉	
	៣	វេយ្យាករណ៍	សព្វនាមចង្អុល	១ម៉	
	៤	អំណាន	មេសូត្រ៖ បុណ្យតាមជំនឿព្រះពុទ្ធសាសនា (បទព្រហ្មគីតិ)	២ម៉	
	៥	សំណេរ	ការគោរពសាសនា	២ម៉	
	៦	និយាយ	ការរៀបរាប់អំពីជំនឿសាសនាផ្សេងៗ	២ម៉	
ទី១៩៖ រមណីយដ្ឋាន ទេសចរណ៍ នៅកម្ពុជា	១	អំណាន	អន្លង់ព្រីង	២ម៉	
	២	ស្តាប់	ទេសភាពមាត់សមុទ្រ	២ម៉	
	៣	អំណាន	រឿង បឹងយក្សឡោម	២ម៉	
ទី២០៖ សេចក្តីថ្លៃថ្នូរ	១	អំណាន	រឿង ក្តីស្រមៃ	២ម៉	
	២	សំណេរ	ពណ៌នាអំពីមនុស្សល្អ	២ម៉	
	៣	វេយ្យាករណ៍	សព្វនាមឈ្នាប់	១ម៉	
	៤	អំណាន	កំណាព្យ៖ បុត្រល្អ (បទពំនោល)	២ម៉	
	៥	សំណេរ	ពណ៌នាអំពីលំនៅឋាន	២ម៉	
	៦	អំណាន	សេចក្តីថ្លៃថ្នូររបស់មនុស្ស	២ម៉	
	៧	និយាយ	ការរៀបរាប់ពីមនុស្សថ្លៃថ្នូរ	១ម៉	
	៨	អំណាន	រឿង បុរសចិត្តធម៌	២ម៉	

សរុបម៉ោងក្នុងមួយឆ្នាំសិក្សា

- សរុបម៉ោងទាំងអស់ ១០ម៉ × ៣៨សប្តាហ៍ = ៣៨០ ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន ២២៧ ម៉ោងសិក្សា
- សរុបម៉ោងសល់ ១៥៣ ម៉ោង

ផ្នែកទី២
អត្ថបទស្តាប់

ជំពូកទី១

អត្ថបទស្តាប់ ៖ រឿង ចចកនិងកំពឹស

រដូវប្រាំងក្តៅហួតហែង ថ្ពក ត្រពាំងរីងខះ។ ចចកមួយស្វែងរកចំណី។ វាប្រទះនឹងកូនថ្ពកមួយមានកំពឹសនិងត្រីជាច្រើន។ វាលាន់មាត់៖ **«ថ្ងៃនេះ អញ មានលាភធំណាស់»។** កំពឹសនិងត្រីយល់ថាចចកចង់ស៊ីក៏អង្វរ៖ **«សូមលោកយកពួកខ្ញុំទៅលាងទឹកឱ្យស្អាតសឹមចឹ»។** ចចកជញ្ជូនកំពឹសនិងត្រីទាំងអស់ទៅលាងក្នុងត្រពាំងទឹកមួយ។ ពួកមច្ឆជាតិមុជក្នុងទឹកជ្រៅបាត់អស់។ ចចកខឹង ទៅបបួល ដំរី ខ្លា ត្រុំ អក កេ ពស់ថ្លាន់ មកបាចទឹកត្រពាំង។ ហ្វូងមច្ឆជាតិកិតភ័យក៏បញ្ជូនត្រីក្រាញ់ឱ្យទៅជួបសុភាទន្សាយ។ សុភាទន្សាយបេះស្លឹកឈើមាន ស្នាមដង្កូវរារលើមកប្រកាស៖ **«ព្រះឥន្ទ្រនឹងកាច់ជើងត្រុំ ប្រមុំជើងអក កាប់ក្បាលចចក ដកភ្នែកដំរីសារ កាប់ក្បាលសត្វខ្លាឱ្យជ្រៅជាងគេ វះពោះសត្វកេ កាត់កពស់ថ្លាន់»។**

សត្វទាំងអស់ឮហើយកិតភ័យ រត់ជាន់គ្នាធ្លាយទំនប់ លង់ទឹកស្លាប់អស់។

(ដកស្រង់ចេញពីសៀវភៅភាសាខ្មែរថ្នាក់ទី៣ពោះពុម្ពឆ្នាំ២០០៩)

ជំពូកទី២

អត្ថបទស្តាប់ ៖ រឿង ក្រពើនិងអ្នកបរទេះ

មានសត្វក្រពើមួយអាស្រ័យនៅបឹងធំ។ លុះដល់រដូវប្រាំង ទឹកបឹងនោះរីងស្ងួតអស់ ក្រពើនោះនៅពុំបាន ទើបវារឡើងលើគោកត្រាច់ចរកទីមានទឹក។ កាលនោះ មានតាចាស់ម្នាក់បរទេះមកបានជួបនឹងក្រពើនៅកណ្តាលផ្លូវ។ ក្រពើឃើញតាបរទេះក៏ស្រែកសុំដោយសារទេះតានោះទៅរកកន្លែងមានទឹក។ តាក៏យល់ព្រម ទើបដោះគោចេញពីនឹមហើយលើកក្រពើដាក់សណ្តែកលើទូករទេះ។ ក្រពើនៅតែខ្លាចធ្លាក់ ទើបប្រើឱ្យតានោះ យកខ្សែមកចងខ្លួនភ្ជាប់នឹងទូករទេះ។ តាក៏ធ្វើតាមពាក្យក្រពើ ស្រេចហើយតាក៏ទឹមគោបរចេញទៅ។ លុះដល់ទីបឹង មួយមានទឹក តាក៏បញ្ឈប់រទេះដោះគោចេញ ស្រាយចំណងក្រពើហើយប្រាប់៖ **«បឹងនេះមានទឹកគួរហើយ ចូរចៅលូនទៅនៅក្នុងបឹងនោះចុះ»។** ក្រពើជាសត្វ អកតញ្ញូមិនដឹងគុណគេ ថែមទាំងអត់អាហារដោយរួរថ្ងៃមកហើយ ក៏និយាយទៅតា៖ **«តាឯងចងយើងភ្ជាប់នឹងទូករទេះ យើងមានសេចក្តីទុក្ខវេទនាណាស់ ដូចនេះតាឯងត្រូវឱ្យគោយើងមួយស៊ី ទើបតាឯងរួចទោស បើមិនឱ្យគោដល់យើងទេ យើងនឹងស៊ីតាឯងឥឡូវនេះហើយ»។** តាឮក្រពើពោលពាក្យដូចនោះ កិតភ័យណាស់ទើបអង្វរ៖ **«នែក្រពើ! អញខំធ្វើគុណនឹងឯង បែរជាឯងចង់ស៊ីសាច់អញទៅវិញ។ ដូចនេះ អញមិនសុខចិត្តទេ អញទៅរកចៅក្រមឱ្យជួយវិនិច្ឆ័យរឿងនេះសិន»។** ក្រពើតបមកវិញ៖ **«អើតាឯងទៅរកចៅក្រមណា ក៏ទៅឱ្យឆាប់ចុះ យើងនឹងចាំឯងនៅទីនេះ»។** តាដើរចេញពីទីនោះបានបន្តិច ក៏ជួបនឹងទន្សាយគល់មួយនៅលើដំបូក។ ក្រឡេកឃើញតា ទន្សាយក៏សួរ៖ **«អើតា! តាទៅណាមកណាមានទឹកមុខសោកសៅខ្លាំងម្ល៉េះ តាមានការអីដែរ?»។** តាក៏និយាយរឿងខ្លួនគាត់និងក្រពើកើតហេតុនឹងគ្នាប្រាប់ទន្សាយសព្វប្រការ។ ទន្សាយបានស្តាប់ក៏ពោល៖ **«អើសត្វក្រពើនោះជាសត្វមិលគុណតា បើដូចនេះ ខ្ញុំទទួលធ្វើចៅក្រមជម្រះក្តីឱ្យ តាកុំភ័យ»។** តាក៏នាំទន្សាយទៅកាន់កន្លែងកើតហេតុ។ ដល់ហើយ ទន្សាយនិយាយនឹងក្រពើ៖ **«ម៉េចចៅក្រពើក្រែងចៅឯង ដោយសារមកជាមួយតា ឥឡូវបានដល់ទីសមគួរនឹងអាស្រ័យនៅហើយ ម្តេចចៅគិតវេរឃ្លើសគុណដល់គាត់ទៅវិញ?»។** ក្រពើឆ្លើយបញ្ជាក់៖ **«អើបងសុភា តានេះគាត់ឱ្យខ្ញុំដោយសារមកមែន ប៉ុន្តែគាត់ចងខ្ញុំភ្ជាប់ទៅនឹងទូករទេះខ្លាំងពេក រកតែរើខ្លួនដកដង្ហើមមិនបានហេតុនេះបានជាខ្ញុំខឹង ទើបខ្ញុំឱ្យគាត់ប្រគល់គោ មួយមកឱ្យខ្ញុំស៊ី។ បើគាត់មិនព្រមទេ ខ្ញុំត្រូវស៊ីគាត់វិញ?»។** ទន្សាយសួរតា៖ **«មើល៍តា! តាឯងម៉េចក៏ចងគេតឹងខ្លាំងម្ល៉េះ?»។** តាឆ្លើយ៖ **«ទេ ខ្ញុំមិនបានចង តឹងទេចងល្មមតែជាប់ កុំឱ្យធ្លាក់តែប៉ុណ្ណោះ»។** ទន្សាយថា៖ **«អើខាងដើមចោទថា ចងតឹងខ្លាំងខាងចម្លើយថា ចងល្មម បើដូចនេះ ត្រូវចៅក្រពើឯងលូន ឡើងមកលើទូករទេះវិញឱ្យតាគាត់ចង ម្តងទៀតយើងនឹងមើលឱ្យដឹងថាតឹង ឬធូរទើបយើងកាត់សេចក្តីនេះឱ្យយុត្តិធម៌បាន»។** ក្រពើជាសត្វខ្លៅក៏វារឡើងទៅក្រាបលើទូករទេះ តា

ក៏យកចំណងមកចងដូចមុន។ ទន្សាយសួរក្រពើ៖ **«ម៉េច បងក្រពើ តាគាត់ចងរឹតយ៉ាងនេះឬ?»។** ក្រពើឆ្លើយ៖ **«ទេ កាលគាត់ចងខ្ញុំមុននោះ តឹងលើសនេះខ្លាំងណាស់។ បើចងប៉ុននេះ ខ្ញុំទៅខឹងអីនឹងគាត់»។** ទន្សាយប្រាប់គា៖ **«ចូរតែរឹតទ្វេឡើងថែមទៀតឱ្យគេសុខចិត្ត»។** តារឹតចំណងឡើងទៀត។ ទន្សាយសួរ៖ **«ម៉េចម្តងនេះ តឹងដូចកាលពីមុនហើយឬនៅ?»។** ក្រពើឆ្លើយ៖ **«នៅពុំទាន់ស្មើមុនទេ»។** ទន្សាយបង្គាប់ឱ្យតាកាប់ឈើ មកធ្វើជាកូនកំព្រាតែបន្ថែមទៀត។ ក្រពើកាលបើត្រូវគេត្របែងខ្លាំង តឹងខ្លួន ស្ទើរដេកដង្ហើមចេញចូលពុំបានក៏ប្រាប់៖ **«បងសុភា កាលពីមុននោះ គាត់ចងតឹងយ៉ាងនេះឯង ។ សូមបងធ្វើជាសាក្សីផងចុះ តើអ្នកណាខុស អ្នកណាត្រូវ»។** ទន្សាយឃើញ ក្រពើរើខ្លួនពុំរួចហើយ ទើបបង្គាប់គា៖ **«តាចាំអ្វីទៀត ពូថៅធំក្នុងរទេះនោះមិនយកមកពុះក្បាលវាទៅ ទុកវាឱ្យរស់ធ្វើអ្វី ខ្មោចអាសត្វអកតញ្ញូពុំដឹងគុណគេធ្វើមកលើខ្លួន»។** តាចាស់ក៏ស្ទុះទៅយកពូថៅធំមក សំពងក្បាលក្រពើនោះ ក្រពើក៏លុះនូវក្តីមរណៈនាពេលនោះឯង ។

(ដកស្រង់និងកែសម្រួលពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគទី៧ ទំ.៧-១០)

ជំពូកទី៤

អត្ថបទស្តាប់៖ បទសម្ភាស

អ្នកកាសែត	:	ជម្រាបសួរអ្នកមីង! ខ្ញុំបាទជាអ្នកសាព័ត៌មាន។ ខ្ញុំចង់ជម្រាបសួរព័ត៌មានខ្លះៗបានឬទេ?
មីងចន្ថា	:	ចា៎! ជម្រាបសួរក្មួយ! ចាក្មួយ! មិនជាការខុសទាស់អ្វីទេ!
អ្នកកាសែត	:	ខ្ញុំបានទទួលដំណឹងថា អ្នកមីង និងកូនប្រុសរងគ្រោះថ្នាក់ចរាចរណ៍។ តើពិតមែនឬទេ?
មីងចន្ថា	:	ចា៎! ពិតមែនហើយក្មួយ។
អ្នកកាសែត	:	តើគ្រោះថ្នាក់នេះ បណ្តាលមកពីអ្វី?
មីងចន្ថា	:	សប្តាហ៍មុន ខ្ញុំបានជិះម៉ូតូទៅផ្សារដោយនុបកូនពីក្រោយ។ ពេលជិតដល់ផ្សារទៅហើយ ស្រាប់តែមានម៉ូតូមួយគ្រឿងបានជិះវ៉ា មកប៉ះចង្កូតម៉ូតូរបស់មីង បណ្តាលឱ្យមីងដួលបោកខ្លួនមកខាងស្តាំយ៉ាងខ្លាំង។
អ្នកកាសែត	:	តើនៅពេលនោះ អ្នកមីងរងរបួសឬទេ? ត្រង់ណាខ្លះ?
មីងចន្ថា	:	សំណាងណាស់ដៃលខ្ញុំមានមួកការពារ។ ខ្ញុំគ្រាន់តែរលាត់ជើងបន្តិចបន្តួច។ ចំណែកកូនរបស់ខ្ញុំវិញត្រូវរបួសក្បាលយ៉ាងខ្លាំង រហូតដល់សន្លប់បាត់ស្មារតី ព្រោះខ្ញុំមិនបានឱ្យកូនពាក់មួកសុវត្ថិភាព។
អ្នកកាសែត	:	ក្នុងហេតុការណ៍នោះ តើមាននរណាខ្លះជួយអ្នកមីង?
មីងចន្ថា	:	ពេលនោះនគរបាលចរាចរណ៍បានឃាត់ម្ចាស់ម៉ូតូដែលបានបង្កហេតុ ដើម្បីដោះស្រាយ។ ចំណែកអ្នកដែលនៅក្នុងហេតុការណ៍នោះ បានហៅរថយន្តសង្គ្រោះបន្ទាន់ ដើម្បីដឹកខ្ញុំនិងកូនទៅមន្ទីរពេទ្យ។
អ្នកកាសែត	:	ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកមីង ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយផ្តល់ព័ត៌មានដល់រូបខ្ញុំ។
មីងចន្ថា	:	ចា៎! អរគុណក្មួយ។

ជំពូកទី៥

អត្ថបទស្តាប់៖ ភ្លៀងធ្លាក់និងខ្យល់ព្យុះនៅខេត្តកំពង់ស្ពឺ

ខេត្តកំពង់ស្ពឺ៖ យ៉ាងហោចណាស់មានលំនៅឋានចំនួន៩៩ខ្នង ស្ថិតនៅក្នុងភូមិចំនួន៥ នៃឃុំរលាំងគ្រើល ស្រុកសំរោងទង បានដួលរលំដោយខ្យល់ព្យុះបក់បោកយ៉ាងខ្លាំងជាមួយភ្លៀងមួយមេធំ កាលពីវេលាម៉ោង២និង១១ នាទី រសៀលថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១២។

អភិបាលស្រុកសំរោងទង **លោក ហង្សគីមញ៉ែន** មានប្រសាសន៍ឱ្យដឹងថា មានលំនៅឋានក្នុងភូមិចំនួន៥ នៃស្រុកសំរោងទងរងការខូចខាតដោយព្យុះភ្លៀង ខ្លះរលំទាំងស្រុង ខ្លះរបើកដំបូល ខ្លះរបើកក្បឿងមួយចំហៀងផ្ទះ។ ភូមិទាំង៥ ក្នុងឃុំរលាំងគ្រើល ដែលទទួលរងនូវគ្រោះមហន្តរាយនេះ មានភូមិអង្គមេត្រី ភូមិកំណប់ ភូមិក្រាំង ភូមិស្វាយ ភូមិព្រៃសាលា និងភូមិចំបក់ផ្អែម។ លំនៅឋានដែលរងការខូចខាតទាំងស្រុងខូចខាតមធ្យម និងខូចខាតស្រាល សរុបទាំងអស់មានចំនួន៩៩ខ្នង។ នៅព្រឹកថ្ងៃទី១៤ ឧសភាទាំងថ្នាក់ស្រុក ថ្នាក់ខេត្ត និងក្រុមកាកបាទក្រហមបានចុះសួរសុខទុក្ខនិងធ្វើកំណត់ហេតុ នៃការខូចខាតដោយសារខ្យល់ព្យុះនេះ ក្នុងនោះ អគារសិក្សាអនុទិវាល័យហ៊ុនសែន ក៏រងការខូចខាតអស់ចំនួន៣ខ្នងដែរ គឺខូចខាតធ្ងន់ធ្ងរ ២ខ្នងដោយរបើកដំបូលទាំងស្រុង។

លោកអភិបាលស្រុកសំរោងទងបន្តទៀតថា គ្រោះធម្មជាតិដោយព្យុះភ្លៀងនេះបានកួចយកដើមចេក ដើមស្វាយតាមដងផ្លូវបាក់អស់ជាច្រើនដើម និងបង្កឱ្យមានការរាំងស្ទះចរាចរណ៍តាមផ្លូវលំផងដែរ។ ទន្ទឹមនេះ ការរលំផ្ទះនោះ ក៏បង្កឱ្យស្ត្រីចំណាស់ម្នាក់ឈ្មោះ **មុិញញ៉ែន** អាយុ៦៨ឆ្នាំ នៅក្នុងភូមិក្រាំងស្វាយ រងរបួសធ្ងន់រហូតដើរពុំរួច កំពុងទទួលការព្យាបាលនៅ។ **លោក ឃុតសុផល** អធិការនគរបាលស្រុកសំរោងទង បាននិយាយថា ចំពោះករណីខ្យល់ព្យុះបំផ្លិចបំផ្លាញផ្ទះសម្បែងប្រជាពលរដ្ឋនេះលោកមិនទាន់ដឹងចំនួនពិតប្រាកដទេ ព្រោះសមត្ថកិច្ចតាមប៉ុស្តិ៍កំពុងតែចុះស្រង់ស្ថិតិផ្លូវការ ដើម្បីផ្តល់ជំនួយសង្គ្រោះនាពេលឆាប់ៗខាងមុខនេះ។

(ដកស្រង់ចេញពីការសែតកោះសន្តិភាព ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១២)

ជំពូកទី៦

អត្ថបទស្តាប់៖ ខ្ញុំសាកល្បង

១. ព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០១២

ម៉ែបាននាំខ្ញុំទៅលេងផ្ទះមីងនៅជិតផ្សារពោធិ៍ចិនតុង។ បន្ទាប់ពីរថយន្តឈប់ត្រូវបានឈប់ចតលើចិញ្ចើមថ្នល់ ខ្ញុំនិងម៉ែបានចុះពីលើរថយន្ត ហើយដើរឆ្ងាយបន្តិច ដើម្បីរកកន្លែងឆ្លង។ ម៉ែកាន់ដៃខ្ញុំជាប់ឈររង់ចាំឆ្លង។ យានយន្តបើកបរបន្តកន្ទុយគ្នាហូរហែតជាប់ រកដកឃ្លាពុំបាន។ ខ្ញុំគិតថា បើតែយ៉ាងនេះ រហូតទល់ល្ងាចទៀតក៏មិនអាចឆ្លងបានដែរ។ រំពេចនោះ ខ្ញុំសង្កេតឃើញអ្នកដំណើរចំនួនបួន ឬប្រាំនាក់បានឆ្លងថ្នល់បានយ៉ាងទំនង។ ខ្ញុំក៏នឹកឃើញកាលពីអ្នកគ្រូឱ្យខ្ញុំសម្តែងតួជាអ្នកឆ្លងថ្នល់នៅមុខថ្នាក់រៀន ដើម្បីឱ្យមិត្តរួមថ្នាក់មើលនិងអនុវត្តតាមមេរៀន។ ខ្ញុំក៏សាកល្បងចាប់ដៃម៉ែដើរឆ្លង។ មុនដំបូង ខ្ញុំមានអារម្មណ៍ភ័យក្តុកក្តាក់ៗ ខ្ញុំខំពង្រឹងស្មារតីឡើងវិញ ហើយក្រឡេកមើលខាងឆ្វេងដៃ ពេលដែលយានយន្តរៀងរយាលបន្តិច ខ្ញុំក៏ដើរសន្សឹមៗទៅមុខរហូតដល់គំនូសកណ្តាលនៃទ្រូងផ្លូវ។ ខ្ញុំនិងម៉ែមិនលែងដៃគ្នាឡើយឈរបន្តិចរង់ចាំយានយន្តខាងស្តាំដៃបង្អង់ល្បឿន។ ទីបំផុត ខ្ញុំនិងម៉ែក៏ឆ្លងថ្នល់ផុតបានដោយសុវត្ថិភាព។

ខ្ញុំត្រេកអរនិងមានមោទនភាពខ្លាំងណាស់ ចំពោះការសាកល្បងរបស់ខ្ញុំលើកនេះ។

២. ពេលរសៀលថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២

ពុកម៉ែបាននាំខ្ញុំទៅផ្សារសុរិយា ដើម្បីទិញសម្ភារៈមួយចំនួន។ ពេលចូលទៅដល់ ខ្ញុំមានអារម្មណ៍ថាត្រជាក់ស្រេបនិងប្លែកភ្នែកយ៉ាងក្រៃលែង។ របស់របរទំនើបៗជាច្រើនដាក់តាំងតម្រៀបជាជួរៗគួរជាទីប៉ងប្រាថ្នា។ ម៉ែនិងពុកកំពុងជ្រើសរើសវត្ថុសម្រាប់ផ្ទះបាយ ខ្ញុំបានសុំអនុញ្ញាតពីគាត់ដើរទៅមុខបន្តិច។ ឱកាសនេះ ខ្ញុំចាប់អារម្មណ៍ខ្លាំងបំផុតគឺការឡើងចុះជណ្តើរយន្ត។ បន្ទាប់ពីសង្កេតមើលគេ ឡើងនិងចុះដោយយកចិត្តទុកដាក់មក ខ្ញុំក៏សម្រេចចិត្តឡើងសាក

ល្បង។ ខ្ញុំជាន់កាំទី១ ដោយឈរទប់ជើងទាំងពីរយ៉ាងនឹង ដៃម្ខាងកាន់បង្គាន់ដៃជណ្តើរ។ ជណ្តើរយន្តចាប់រំលើងទៅលើស្រឹតៗ ខ្ញុំក៏ស្រឹតពោះដែរ។ ភ្នែករបស់ខ្ញុំសម្លឹងទន្ទឹងចាំមើលជណ្តើររំលងដល់ខាងលើ ខ្ញុំក៏ឈានជើងចេញពីជណ្តើរយន្តយ៉ាងរហ័ស។ ខ្ញុំត្រេកអរក្រៃលែង សម្លឹងមកក្រោមវិញដោយក្តីសោមនស្ស។ ពុកម៉ែងាកចុះឡើងៗ រកមើលខ្ញុំ។ ខ្ញុំក៏ប្រញាប់ចុះមកវិញដោយឥរិយាបថដូចការដែលឡើងដែរ ក៏ប៉ុន្តែវាជាការដែលជណ្តើររំលចុះមកក្រោមវិញ។

ខ្ញុំរត់ទៅឱបពុកដោយអរកខិបកខុបហើយនិយាយថា ពុកម៉ែខ្ញុំចេះឡើងជណ្តើរយន្តហើយ!។

(ក្រុមសំណេរភាសាខ្មែរ)

ជំពូកទី៧

អត្ថបទស្តាប់៖ សំបុត្រផ្ញើរាល់ខ្លួន

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២

សុផាតជាទីស្រឡាញ់ និងជាទីនឹករឭក

សួស្តីសុផាត! តើឯងសុខសប្បាយជាទេ? តើឯងកំពុងធ្វើអ្វី នាពេលថ្មីនេះ? តើឯងដឹងទេ មួយរយៈនេះ ខ្ញុំនឹកឯងណាស់ ប៉ុន្តែរកឆ្លៀតពេល ដើម្បីសួរសុខទុក្ខឯងមិនបានសោះ ទើបតែពេលនេះជាឱកាសដ៏ល្អ ខ្ញុំក៏ចាប់ផ្តើមបង្ហូរចិត្តនឹកតាមរយៈចុងប៊ិកដ៏តូចនេះ។ គ្រាន់តែចាប់ផ្តើមសរសេរភ្លាម អារម្មណ៍របស់ខ្ញុំដូចជាកំពុងស្ថិតនៅក្នុងអតីតកាល ជួនខ្ញុំញញឹម ជួនផ្ទុះសំណើចដោយមិនដឹងខ្លួន។ កំពុងតែញញឹមមែនទេ? ខ្ញុំគិតថា ឯងក៏មានអារម្មណ៍ដូចខ្ញុំដែរ។

សុផាត! ថ្វីត្បិតតែយើងទើបបានស្គាល់គ្នាត្រឹមតែ៣ឆ្នាំក៏ពិតមែន តែអ្វីៗសព្វបែបយ៉ាងក្នុងការរស់នៅ ទាំងការនៅផ្ទះ ទាំងការដើរកម្សាន្ត និងការនិយាយគ្នាលេង វាមានច្រើនសន្ធឹកសន្ធាប់ណាស់ ហើយបានជិតជាប់ក្នុងចិត្តខ្ញុំជារៀងរហូតមក។ និយាយដល់រឿងនេះ ខ្ញុំហាក់មានអារម្មណ៍កក់ក្តៅយ៉ាងចម្លែក! ខ្ញុំនឹកឃើញអនុស្សាវរីយ៍ទាំងអស់នោះផុសឡើងនៅនឹងមុខនិងនៅថ្មីៗនៅឡើយ ដូចជាទើបនឹងកើតនៅថ្ងៃម្សិលមិញអញ្ចឹង។ ខ្ញុំមិនដឹងថា ឯងនៅចាំរឿងរ៉ាវទាំងអស់នេះដែរឬអត់?

ក្រៅពីទំនាក់ទំនងដ៏ល្អជាច្រើន នៅមានរឿងមួយទៀត ដែលខ្ញុំរំភើបរកទីបំផុតគ្មាន ចំពោះកាយវិការរបស់ឯងដែលបានរួមសុខទុក្ខជាមួយខ្ញុំ នៅពេលដែលឪពុកខ្ញុំឈឺធ្ងន់នៅឯមន្ទីរពេទ្យ។ ឯងក្លាហានណាស់។ កាលនោះ ឯងមានអាយុទើបតែ ១២ឆ្នាំប៉ុណ្ណោះ ឯងហ៊ានជិះកង់ទៅមន្ទីរពេទ្យដែលមានចម្ងាយ១០គីឡូម៉ែត្រ ដើម្បីជួយកំដរឪពុកខ្ញុំរាល់យប់រហូតគាត់ចេញពីមន្ទីរពេទ្យ។ ខ្ញុំពិតជាមិនអាចបំភ្លេចបានឡើយ។ ពីថ្ងៃនេះតទៅ បងសូមចាត់ទុកឯងជាប្អូនបង្កើតរបស់ខ្ញុំ។ យប់ជ្រៅណាស់ហើយ បងសូមបញ្ចប់អក្ខរាតែត្រឹមនេះចុះ។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់ទេវតាឆ្នាំថ្មី សូមលោកជួយបីបាច់ថែរក្សាប្អូននិងក្រុមគ្រួសារឱ្យបានជួបតែសេចក្តីសុខ សេចក្តីចម្រើនរុងរឿងជានិច្ចនិរន្តរ៍។

ហត្ថលេខា

ណារ៉ា

ជំពូកទី៩

អត្ថបទស្តាប់៖ វិជ្ជាជាឃ្លាំងទ្រព្យ

១. ចំណេះវិជ្ជាជាឃ្លាំងទ្រព្យ	ថ្លៃប្រសើរគាប់ទ្រព្យនានា
អ្នកមានតំរិះមានវិជ្ជា	គ្មានអ្វីពាធាយាយីបាន។
២. ដូចនេះអ្នកផងទាំងពួងអើយ	ចូរកុំកន្តើយគ្រប់ៗប្រាណ

ស្វែងរកវិជ្ជា តាមលំអាន ដែលចាស់បុរាណបានប្រដៅ។
៣. បើមិនបានរៀននៅទំនេរ ធំឡើងគ្មានទេ ព្រោះខ្លួនខ្លៅ
ត្រូវគេមើលងាយតពង្សពៅ ពាក្យចាស់ប្រដៅមិនត្រង់ត្រាប់។
៤. ទាន់នៅវ័យក្មេង ទាំងប្រុសស្រី ចូរប្រុងស្មារតី ផ្ទៀងចាំស្តាប់
ព្យាយាមសិក្សា ក្លាហានក្តាប់ អ្នកប្រាជ្ញបានប្រាប់ស្តាប់ឱ្យបាន។
៥. កុំលួងទាល់ងាប់ ធ្វើមិនដឹង បើចេះហើយប្រឹង កុំខាន
សិក្សារៀនសូត្រគ្រប់ៗប្រាណ ដណ្តើមឱ្យបានវិជ្ជាខ្ពស់។

ជំពូកទី១០

អត្ថបទស្តាប់៖ រឿង ចៅប្រាក់ភ្នែកបី

មានរឿងតំណាលថា កុមារម្នាក់ឈ្មោះប្រាក់ បានសម្រេចចិត្តថានឹងទៅស្នេចត្រីកម្សាន្តជាមួយឪពុកនិងប្អូនប្រុសវានៅថ្ងៃខាងមុខ តែចៃដន្យអាក្រក់ប្រាក់ដួលគ្រេចជើង មុនពេលទៅស្នេចត្រី។ លុះដល់ថ្ងៃកំណត់ ប្រាក់មិនទាន់ជាជើងនៅឡើយ។ ប្រាក់កំពុងតែអផ្សុកស្រាប់តែឃើញប្អូនប្រុសវាយួរបាយសំណុំ ទឹក និងដងសន្ទូចចេញពីផ្ទះបាយមក។ ប្រាក់ស្តាយឱកាសដ៏ល្អនេះណាស់។ ពេលជិតចេញដំណើរ ឪពុកប្រាក់ចូលមកក្នុងបន្ទប់ប្រាក់ហើយសួរ៖ **«តើជើងកូនឯងយ៉ាងម៉េចហើយ?»។ ប្រាក់តប៖ «បាទពុក! កូនបានធូរស្រាលច្រើនហើយ»។** តាមពិត ចម្លើយនេះជាការកុហកទេ ព្រោះប្រាក់មិនចង់ឱ្យឪពុកមានអារម្មណ៍មិនល្អ ក្នុងការធ្វើដំណើរកម្សាន្ត។ ឪពុកប្រាក់យល់ចិត្តកូនក៏ហុចឧបករណ៍មួយទៅឱ្យកូនរួចនិយាយ៖ **«នេះជាវត្ថុជួយឱ្យកូនបានចូលរួមកម្សាន្តស្នេចត្រីជាមួយពុក»។** ប្រាក់ទទួលឧបករណ៍នោះពីដៃឪពុក រួចលាន់មាត់៖ **«អីយ៉ាកែវយឹត! កូនរីករាយណាស់ពុក។ កូនអរគុណពុកណាស់។ វត្ថុនេះកូនចេះប្រើវាហើយ»។** ពេលនោះដែរ ព្រឹងជាប្អូនប្រុសរបស់ប្រាក់ចូលមកដល់បន្ទប់ប្រាក់ល្មម។ វាឃើញប្រាក់កំពុងលើកកែវយឹតឆ្លុះមើលតាមបង្អួច។ ព្រឹងក៏លាន់មាត់៖ **«អីយ៉ាបងប្រាក់មានភ្នែកដល់ទៅបី»។**

ក្រោយពីសំណេះសំណាលគ្នារួច ឪពុកនិងព្រឹងដើរសំដៅកន្លែងមានត្រីច្រើន។ ចំណែកប្រាក់តាមមើលដំណើរឪពុកនិងប្អូនប្រុសរហូត។ ប្រាក់បានលើកកែវយឹតចាប់តាំងពីប្អូនចេញដំណើរពីផ្ទះ។ មើលបានយូរបន្តិច ប្រាក់អស់កម្លាំងក៏ប្រែខ្លួនដេកលេង ហើយក៏លក់ទៅ ស្រាប់តែទូរស័ព្ទរោទ៍រឹងៗដូចជាដាស់ប្រាក់ឱ្យដឹងខ្លួនឡើងវិញ។ ប្រាក់ចាប់ទូរស័ព្ទស្តាប់ រួចសួរ៖ **«អាឡូ! តើមានហេតុការណ៍អ្វីព្រឹង?»។** ព្រឹងឆ្លើយ៖ **«ខ្ញុំនិងពុកកំពុងជួបឧបសគ្គ។ ទូកខូចម៉ាស៊ីនហើយកំពុងតែរសាត់ទៅជិតកន្លែងដែលមានជើងកប លិចទូករាល់ៗឆ្នាំ។ សូមបងហៅកងជំនួយសង្គ្រោះបន្ទាន់! ខ្ញុំមិនចាំលេខទូរស័ព្ទរបស់កងជំនួយទេ»។**

បន្ទាប់ពីទូរស័ព្ទហៅកងជំនួយរួច ប្រាក់មើលតាមកែវយឹតឃើញប្អូនប្រុសវាកំពុងលើកមួកបក់រវិចៗជាសញ្ញាហៅរកជំនួយ។ ឯឪពុកវាកំពុងតែវ៉ៃម៉ាស៊ីនទូក តែមិនបានសម្រេចសោះ។ អស្ចារ្យណាស់ ពិតជាដូចទេពនិមិត្តមែន តែ៥នាទីប៉ុណ្ណោះ អូបរបស់កងជំនួយសង្គ្រោះ បើកទៅជិតដល់កន្លែងកើតហេតុនោះភ្លាម។ ប្រាក់និយាយនៅពេលដែលម្តាយវាកំពុងតែបន់ស្រន់៖ **«ប្រសើរណាស់ ព្រះអើយ! ពុកនិងប្អូនខ្ញុំផុតពីគ្រោះថ្នាក់ហើយ។ នេះមកពីគុណប្រយោជន៍របស់កែវយឹតនិងទូរស័ព្ទនេះតែម្តង»។**

(ដកស្រង់ចេញពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី៥ បោះពុម្ពឆ្នាំ២០០០)

ជំពូកទី១២

អត្ថបទស្តាប់៖ រឿង ទឹកចិត្តមេមាន់

កសិករម្នាក់បានចិញ្ចឹមមេមាន់មួយនិងមេទាមួយឱ្យនៅក្នុងទ្រុងជាមួយគ្នា។ ក្រោយមក មេមាន់ញាស់បានកូនបួន។ ចំណែកមេទាញាស់បានកូនមួយ ក៏ស្លាប់ចោលកូនទៅ។ មេមាន់ឃើញកូនទាកំព្រាក៏យកមកចិញ្ចឹមបីបាច់ដូចកូនបង្កើតដែរ។ រាល់ថ្ងៃ មេមាន់បណ្តើរកូនទាំងអស់រកចំណីគ្រប់ទីកន្លែង។

ថ្ងៃមួយ កូនមាន់តូចជាងគេឆ្ងល់នឹងទង្វើរបស់មេក៏សួរ៖ **«ម៉ែ! ហេតុអ្វីបានជាម៉ែមើលថែកូនទា?»។** មេមាន់ឆ្លើយ៖ **«ពីព្រោះវាកំព្រាអត់មេ ហើយវានៅតូចណាស់។ វាត្រូវការការថែទាំដូចកូនដែរ ម៉ែចិញ្ចឹមវា ព្រោះវាក៏មានសិទ្ធរស់រានមានជីវិតដូចក្មេងទូទៅដែរ។ បើម៉ែមិនយកវាមកចិញ្ចឹមទេ តើវារស់ដូចម្តេច?»។** កូនមាន់សួរមេវាទៀត៖ **«ម៉ែគិតចិញ្ចឹមវារហូតឬ?»។** មេមាន់ឆ្លើយ៖ **«ទេ! ដល់វាគ្រប់អាយុម៉ែឱ្យវាទៅរៀនជាមួយកូន ហើយដល់ពេលវាចេះចិញ្ចឹមខ្លួនបាន ម៉ែឈប់ជួយវាហើយ»។** **«យី! ម៉ែខ្ញុំចិត្តល្អណាស់»** កូនមាន់លាន់មាត់។

ជំពូកទី១៣

អត្ថបទស្តាប់៖ ត្បូងពណ៌ស្វាយមួយគ្រាប់

ខេត្តរតនគិរីសម្បូរទៅដោយសម្បត្តិធម្មជាតិដ៏មានតម្លៃគួរកត់សម្គាល់ ដូចជានៅស្រុកបកែវ ស្រុកលំផាត់និងស្រុកកូនមុំ។

តាំងពីខែតុលា ឆ្នាំ២០០០ នៅភូមិអូរខ្វេះ ស្ថិតនៅឃុំត្រពាំងក្រហម ស្រុកកូនមុំ គេជីកបានត្បូងធម្មជាតិពណ៌ស្វាយមួយគ្រាប់ទម្ងន់ប្រហែល៥គីឡូក្រាម។ គេបានលក់ត្បូងនេះទៅឱ្យកុងសៃទិញត្បូងម្នាក់នៅក្នុងខេត្តរតនគិរី តែពុំដឹងលក់ក្នុងតម្លៃប៉ុន្មានទេ។

ប្រធានមន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្តរតនគិរី បានឱ្យដឹងថា ត្បូងពណ៌ស្វាយមួយគ្រាប់នេះ មិនមែនប្រភេទត្បូងធម្មតានោះទេ គឺជាកែវណាមហ្វានពណ៌ស្វាយ។ កែវណាមហ្វាននេះជាត្បូងប្រភេទខ្ចី។ ថ្មកែវណាមហ្វានមានពណ៌ស្វាយល្អណាស់ ពេលគេជីកបានពីក្នុងដីភ្លាមៗ។ តែក្រោយមក វាប្រែពណ៌រាងស្លេកមិនសូវល្អដូចពេលគេជីកបានភ្លាមទេ។

ជំពូកទី១៤

អត្ថបទស្តាប់៖ រឿង ស្រីកណ្តុរឈ្លោច

កាលពីដើម មានបុរសម្នាក់មានប្រពន្ធ។ សព្វថ្ងៃ បុរសនោះតែងទៅកាប់ចម្ការ លុះកាប់ចម្ការទៅដល់ដើមជ្រៃមួយ មានស្តេចកណ្តុរសនៅនឹងដើមជ្រៃនោះ។ ស្តេចកណ្តុរសមានសេចក្តីកិតក័យ ហើយក៏អង្វរបុរសដែលកាប់ព្រៃធ្វើចម្ការនោះថា **«សុំឱ្យបុរសទុកដើមជ្រៃមួយនេះ ខ្ញុំនឹងឱ្យរង្វាន់ក្នុងមួយថ្ងៃមាស១ដុំ»។** បុរសក៏ទុកដើមជ្រៃឱ្យ។ ស្តេចកណ្តុរស បានយកមកប្រគល់ឱ្យបុរសនោះរាល់ថ្ងៃ។ បុរសបានមាសហើយក៏យកទៅប្រគល់ឱ្យប្រពន្ធតែរាល់ថ្ងៃ។ ប្រពន្ធសួរថា **«អ្នកបានមាសមកពីណា?»។** ប្តីថា **«នាងកុំចង់ដឹងអីចេះតែទុកទៅ»។** ប្រពន្ធថា **«បើមិនប្រាប់ខ្ញុំ ខ្ញុំនឹងទៅប្តឹងរាជការចៅថែ ឬនឹងទៅទូលស្តេចថា អ្នកលួចព្រះរាជទ្រព្យ »។** បុរសនោះ ឮប្រពន្ធថាដូច្នោះ ក៏ភ័យហើយបានថ្លែងប្រាប់ទៅប្រពន្ធ តាមដំណើរដែលបានមាសពីស្តេចកណ្តុរសនោះ។ នាងប្រពន្ធបានដឹងតាមដំណើរ ហើយក៏ប្រាប់ទៅប្តីវិញថា **«អ្នកនេះហៅពេញជាឆោតចាញ់ប្រាជ្ញាសត្វ បើអ្នកកាប់ដើមជ្រៃនោះឱ្យរំលែ ហើយពុះបំបែកយកមាសពីក្នុងដើមជ្រៃនោះនឹងបានច្រើន ព្រោះស្តេចកណ្តុរសវាយកមាសពីក្នុងដើមជ្រៃនោះ»។** បុរសនោះបានឮសម្តីប្រពន្ធហើយជឿ។ លុះព្រឹកឡើងទៅកាប់រំលែទៅ ហើយក៏មើលពុំឃើញមានមាសអ្វីបន្តិចសោះ។ ស្តេចកណ្តុរសក៏រត់ចោលដើមជ្រៃនោះទៅ។ រួចយប់ស្តេចកណ្តុរស នាំគ្នាទៅលួចយកមាសពីផ្ទះបុរសនោះអស់មកវិញ។

(ចង់ស៊ី កុំតាមឃ្លាន)

(ប្រជុំរឿងព្រេងខ្មែរ ភាគទី២)

ជំពូកទី១៥

អត្ថបទស្តាប់៖ រឿង ដើមកំណើតសត្វផ្សោត

ជាយូរអង្វែងណាស់មកហើយ មានដើមពោធិ៍ធំមួយដើម ដែលមហាជនក្នុងភូមិធ្វើរូបសំណាកប្រុស ស្រីពីរ នាក់អង្គុយទន្ទឹមគ្នាក្នុងខ្នមក្រោមដើមពោធិ៍។ អ្នកផងទាំងពួងតែងតែមកបន់ស្រន់ ថ្វាយក្រយាបូជា សុំសេចក្តីសុខបាន ដូចបំណង គេចាត់ទុកថា **"ជាអ្នកតាម្ចាស់ស្រុក"** ហើយក៏មានរុក្ខជាតិទេវតាមួយដើមដុះនៅ លើដើមពោធិ៍នេះ។

ក្រោយមកមានស្ត្រីម្នាក់មកចាប់បដិសន្ធិ កើតជាកូនអ្នកស្រុកដែលចូលចិត្តរាប់អានរុក្ខជាតិនេះ។ លុះនាងធំ ពេញវ័យ នៅរដូវសែនព្រេនក្រយាបូជាដល់អ្នកតាម្ចាស់ស្រុក នាងទូលថាស មានបាយ សម្ល នំចំណី ទៅសែនជំនួស ឪពុកម្តាយ។ រុក្ខទេវតាក្រឡេកឃើញនាងភ្លាម ស្រាប់តែមានចិត្តអាណិតអាសូរនិងស្រឡាញ់នាង។ រុក្ខទេវតាចម្លែកក្នុង ចិត្តទ្រាំពុំបាន ក៏ហោះទៅទូលព្រះឥន្ទ្រាធិរាជតាមដំណើរ។ ព្រះឥន្ទ្រាធិរាជទ្រង់ ដោយញាណទិព្វឃើញថា **"នាងនោះ កាលពីជាតិមុន ជាប្រពន្ធរបស់រុក្ខទេវតា បានសាងប្រាថ្នាជាមួយគ្នាថា ទោះបីកើតជាតិណា ឬកពណា សូមឱ្យបានជួបគ្នា ជាប្តីប្រពន្ធគ្រប់ៗជាតិ"**

រុក្ខទេវតាគិតចុះគិតឡើង រហូតពេលរាត្រីស្ងាត់ ក៏សម្រេចចិត្តនិម្មិតខ្លួនជាពស់ថ្លាន់មួយយ៉ាងធំចូល ទៅរួតរឹតនាង។ លុះពេលនាងដឹងខ្លួន ក៏ភ្ញាក់ឡើងខំរើបម្រាស់យ៉ាងខ្លាំង ពស់ថ្លាន់និយាយលោងលោមនាង ថា **"រូបខ្ញុំគឺជាប្តីរបស់នាងរហូតមក "** តែមិនព្រមជឿសោះ ពស់ថ្លាន់បន្ថែមទៀតថា **"បើនាងមិនជឿទេ ខ្ញុំនឹង ប្រែរូបឱ្យនាងមើលឥឡូវនេះ"។** ភ្លាមនោះ ពស់ថ្លាន់ក៏ផ្លាស់រូបជាទេវតានៅចំពោះមុខនាង។ រុក្ខទេវតា និយាយប្រាប់នាងថា **"បើមិននិម្មិតជាសត្វពស់ថ្លាន់បែបនេះទេ ប្រាកដជាមិនបានជួបគ្នាឡើយ"។** បន្ទាប់ពី យល់ចិត្តគ្នាទៅវិញទៅមកហើយ រុក្ខទេវតាក៏ប្រែកាឡាជាពស់ថ្លាន់វិញប្រាប់នាងថា **"ពេលថ្ងៃបងមិនបាននៅជាមួយអូនទេ បងមកជួបអូននៅពេលយប់តែប៉ុណ្ណោះ"។** កូនស្រីបាននិយាយប្រាប់ឪពុកម្តាយអំពីរឿង គ្រប់យ៉ាងដែលនាងបានជួប ហើយនាងបន្តទៀតថា **"ពុកម៉ែ! ប្តីខ្ញុំហាមមិនឱ្យនិយាយការពិតប្រាប់អ្នកស្រុក ឡើយ គឺគ្រាន់តែថា គាត់ជាពស់ថ្លាន់ធម្មតាទៅបានហើយ។ រាល់ថ្ងៃ គាត់មកជួបកូនតែពេលយប់តែប៉ុណ្ណោះ"។** ឪពុកម្តាយ ស្តាប់កូនហើយ មិនដឹងធ្វើយ៉ាងដូចម្តេចក៏នៅស្ងៀម។ លុះពេលរាត្រីស្ងាត់ រុក្ខទេវតាក៏និម្មិតរូបជាទេវតាមកជួបនាងតាមសន្យា។ ពេលទៀបភ្លឺ ប្តីប្រាប់ប្រពន្ធឱ្យនាំឪពុកម្តាយទៅជីកយកកំណប់ ក្នុងដំបូកមួយ។

ចាប់ពីពេលនោះមក គ្រួសាររបស់នាងមានទ្រព្យសម្បត្តហូរហៀរឥតខ្វះ មានផ្ទះធំល្វឹងល្វើយមានអ្នកបម្រើ ឆ្វេងស្តាំ។ យូរៗទៅដំណឹងនេះក៏ឮសុសសាយដល់អ្នកស្រុកជិតឆ្ងាយ។ មិនយូរប៉ុន្មាន គ្រួសារមួយមានកូនក្រមុំម្នាក់ក៏សម្រេចចិត្តទៅចាប់ពស់ថ្លាន់ ដើម្បីយកមករៀបចំសែនព្រេនជាមួយកូនស្រីរបស់ខ្លួន។ អ្នកភូមិ ខ្លះលាន់មាត់ថា គ្រួសារនេះ ឆ្កួតអស់ហើយ អ្នកខ្លះស្រែករកពុទ្ធោ អ្នកខ្លះទៀតត្រូវស្រាបន្តិចបន្តួចក៏សប្បាយទៅ។

លុះដល់ពេលរាត្រី គេលើកពស់ថ្លាន់ ដាក់ក្នុងបន្ទប់ផ្សំដំណេកជាមួយកូនក្រមុំគ្រានោះ នាងភ័យខ្លាចខ្លាំងណាស់។ លុះពាក់កណ្តាលអាធ្រាត្រ ពស់ថ្លាន់ដែលកំពុងស្រែកឈ្លាននោះ ក៏ចាប់ផ្តើមរួតរឹតនាងទាំងរស់។ នាងខំស្រែកប្រាប់ឪពុកម្តាយ ប៉ុន្តែឪពុកម្តាយបែរជាស្តីបន្ទោសទៅវិញ។ មិនយូរប៉ុន្មាន ពស់ថ្លាន់ក៏លេបនាងបាត់ទៅ។ ស្ងាត់មាត់បន្តិច ម្តាយសង្ស័យក៏អុជភ្លើងចូលទៅមើល បាត់កូនស្រី ឃើញតែពស់ថ្លាន់ធំកំពឹង។ នាងជាម្តាយក៏ស្រែកទ្រហោយំ ផ្អើលពេញភូមិទាំងកណ្តាលអាធ្រាត្រ។ ឪពុកម្តាយចាប់ពស់ថ្លាន់ដោយយក កាំបិតមកវះបណ្តោយពោះ ទាញកូនទាំងសន្លប់ស្តូកស្តឹងចេញមក ហើយមានប្រលាក់រំអិលពស់ថ្លាន់ មានក្លិនឆ្អាបឆ្អេះ កខ្វក់ពេញទាំងខ្លួនប្រាណ។ ម្តាយយកទឹកក្តៅឧណ្ហៗមកជូតសម្អាតឱ្យកូន ទើបនាងដឹងខ្លួន នាងបើកភ្នែកឃើញបងប្អូន មីងមាឈរត្រៀបត្រា ហើយមើលមកខ្លួនឯងសុទ្ធតែរំអិលពស់ឆ្អាបគគ្រុកនឹកតូច ចិត្តក៏ស្ទុះក្រោកឡើងកញ្ជក់បានផ្តិលទឹកមួយ លើកគ្របក្បាលរត់សំដៅទៅមាត់ទន្លេដោយក្តីអាម៉ាស់។ ទៅដល់មាត់ទន្លេ នាងក៏ទម្លុះផ្តិលលោតទឹកសម្លាប់ខ្លួនទាំងចិត្តខ្លោចផ្សា។ មួយ

សន្ទុះក្រោយមក នាងក៏ក្លាយទៅ ជាសត្វផ្សោតញីមួយក្បាលហែលចុះឡើងចាប់ត្រីស៊ីធ្វើព្រងើយ។ ឪពុកម្តាយរត់តាមរកកូនមិនឃើញ នាំគ្នា អង្គុយយំសោកអាឡោះអាល័យនៅមាត់ទន្លេ។

ចាប់តាំងពីពេលនោះមក សត្វផ្សោតក៏កើតមានឡើង ត្រឹមនាងជាប្រពន្ធពស់ថ្លាន់នេះ។ វាបានកើត កូនពូនជាចៅ ដែលមានរូបរាងប្រហាក់ប្រហែលនឹងមនុស្សយើងដែរ គ្រាន់តែវាគ្មានដៃជើង ហើយក្បាល របស់ផ្សោតត្រងោលដូចទទូផ្តិលទឹកតែប៉ុណ្ណោះ។

(ការលោភលន់នាំឱ្យខ្លួនវិនាស)

(ដកស្រង់ចេញពីសៀវភៅរឿងព្រេងខ្មែរ ភាគ៤)

ជំពូកទី១៨

អត្ថបទស្តាប់ ៖ អ្នកបួសតាមពុទ្ធសាសនា

តាំងពីដូនតា	ខ្មែរជឿសាសនា	សមណគោតម
ព្រះអង្គនាំផ្លូវ	ដើរទៅឧត្តម	ប្រកាន់ក្រឹត្យក្រម
	ល្បីគ្រប់ទិសទី។	
ខ្មែរឱ្យកូនបួស	ជាព្រះសង្ឃព្រោះ	តាមប្រពៃណី
បួសដើម្បីសង	គុណលោកទាំងពីរ	និងតួនាទី
	ថៃពុទ្ធសាសនា។	
បើបានបួសហើយ	អ្នកកុំកន្តើយ	កុំឱ្យមុសា
គោរពព្រះធម៌	ព្រះពុទ្ធផងណា	រៀនសូត្រធម៌អាថ៌
	ព្រះត្រៃបិដក។	
លះបង់កិលេស	កាមគុណដែលឆេះ	ដូចព្យុះបោកបក់
កម្ចាត់មោហោ	ទោសោលោភៈ	កុំឱ្យរំលំរំក់
	ជាប់ក្នុងអាត្មា។	
កុំបួសលេងៗ	បួសធ្វើជាល្បែង	បួសនាំខូចការ
បាត់បង់ជំនឿ	ព្រះពុទ្ធសាសនា	បួសមិនជ្រះថ្លា
	បួសសន្សំទ្រព្យ។	

ជំពូកទី១៩

អត្ថបទស្តាប់ ៖ ទេសភាពមាត់សមុទ្រ

ប្រទេសកម្ពុជា សម្បូរមណីយដ្ឋានគួរជាទីមនោរម្យ។ កន្លែងកម្សាន្តទាំងនោះ ខ្លះកើតឡើងដោយសារធម្មជាតិ ខ្លះកើតឡើងដោយសារមនុស្សជាអ្នកបង្កើត។ ឆ្នេរសមុទ្រ ឬមាត់សមុទ្រជាកន្លែងកម្សាន្ត បែបធម្មជាតិមួយដែលគេនិយមចូលចិត្តគ្រប់ៗគ្នា។

នៅរៀងរាល់ចុងសប្តាហ៍នៃខែនីមួយៗ ឬនៅរាល់ថ្ងៃបុណ្យឈប់សម្រាកពីការងារ គេសង្កេតឃើញមានភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិទាំងនៅក្នុងតំបន់ ក្រៅតំបន់បាននាំគ្នាមកសម្រាកលំហែកាយនៅទីនេះ យ៉ាងច្រើនកុះករ។

ទេសភាពមាត់សមុទ្រ គួរឱ្យពិតពិលរមិលមើលពន់ពេក បានបង្ហាញពីទិដ្ឋភាពយ៉ាងស្រស់ត្រកាលគួរឱ្យចង់ទស្សនា។ បើក្រឡេកពីចម្ងាយ គេនឹងឃើញ ផ្ទៃទឹកដ៏ល្វឹងល្វើយលាតសន្ធឹងដល់ជើងមេឃ ។ គ្រាន់តែឈានជើងមកដល់មាត់សមុទ្រភ្លាម ខ្យល់អាកាសត្រជាក់និងភ្លីនប្លែកៗបានបក់ប៉ះមុខនិងច្រមុះអ្នកដែលមកកម្សាន្ត។ អ្នកទេសចរ

គ្រប់ៗរូបស្រូបយកខ្យល់បរិសុទ្ធ ដែលបានបក់មករំភើយៗពីឯនាយលំហសមុទ្រ ។ នៅតាមឆ្នេរសមុទ្រ ដែលមានខ្សាច់ម៉ដ្ដសក្បុស សំបកលៀស គ្រំ ខ្យង ខ្ចៅ មានពណ៌ប្លែកៗរាយពាសពេញ ដែលចាំងនឹងពន្លឺព្រះអាទិត្យដោយបញ្ចេញរស្មីភ្លឺផ្លេកៗគួរឱ្យចាប់អារម្មណ៍។ មានពេលខ្លះ ក្តាមសមុទ្រដែលកំពុងវារនៅលើខ្សាច់ ដោយមានការភ័យខ្លាចអ្នកដើរកម្សាន្ត បានលើកដងង្កៀប រួចរត់ទទឹងខ្លួនយ៉ាងលឿនសំដៅចូលរន្ធដែលនៅក្បែរខ្លួន។ សូរសំឡេរលកសមុទ្រលាន់ឮគ្រាំងៗ។ ទឹកសមុទ្រថ្លាខៀវឆ្លុះឃើញខ្សាច់ ជួនកាលគេឃើញ ត្រីហែលរលេចប្រជេញគ្នាទាំងហ្វូងៗ។ នៅលើផ្ទៃទឹកមិនឆ្ងាយប៉ុន្មានពីឆ្នេរ គេឃើញទូកក្តោងនេសាទអណ្តែតយឺតៗ។

អ្នកដែលមកកម្សាន្តនៅមាត់សមុទ្រ ពិតជាទទួលបាននូវអារម្មណ៍រីករាយស្រស់ថ្លា។ អ្នកខ្លះដើរកាត់ឆ្នេរខ្សាច់ យកជើងលេងទឹករលក អ្នកខ្លះអង្គុយនៅលើខ្សាច់ ក្នែកសម្លឹងទៅលំហសមុទ្រ អ្នកខ្លះមុជទឹកលេងជាមួយនឹងក្រុមគ្រួសារ។ បរិស្ថានពិតជាល្អប្រសើរណាស់ ទោះបីជាមានភ្ញៀវទេសចរណ៍មកកម្សាន្តយ៉ាងច្រើនកុះករក៏ដោយ គឺទីនោះមានអ្នកថែសម្អាតដោយបោសសំរាមជាក់ធុងជាប្រចាំ។

ផ្នែកទី៣
លំនាំនៃការបង្រៀន

សេចក្តីណែនាំ

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថាសិស្សបឋមសិក្សា មានមូលដ្ឋាននៃការអាននិងសរសេរ នៅមានកម្រិតទាបគួរឱ្យបារម្ភ។ ដើម្បីពង្រឹងគុណភាពនៃការអាននិងសរសេរឱ្យកាន់តែប្រសើរ គណៈកម្មការបានធ្វើការសម្របសម្រួល វិធីសាស្ត្រនិងកែលម្អឯកសារបង្រៀនភាសាខ្មែរថ្នាក់ទី៥ ថ្នាក់ទី៦របស់ក្រសួងអប់រំយុវជន និងកីឡា មកជាសៀវភៅពន្លឿនការសិក្សាថ្នាក់ឆ្នាំទី៣ ដើម្បីឱ្យសិស្សក្នុងកម្រិតនេះអាចអាន ភាសាខ្មែរឆាប់ចេះក្នុងទិសដៅឆ្លើយតបទៅនឹងកម្មវិធីពន្លឿនការសិក្សា។ សម្រាប់កម្រិតសិក្សាថ្នាក់ឆ្នាំទី៣នេះ ត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរពោលគឺ៖ ចេះអាន សរសេរបានច្បាស់លាស់។

សៀវភៅសម្រាប់បង្រៀន ភាសាខ្មែរកម្រិតសិក្សាថ្នាក់ឆ្នាំទី៣ នេះរៀបរៀងឡើង ដើម្បីសម្រួលដល់ការរៀននិងបង្រៀនភាសាខ្មែរដោយដកស្រង់ខ្លឹមសារ មួយចំនួននិងយកលំនាំសៀវភៅថ្នាក់ទី៥ និងថ្នាក់ទី៦ របស់ក្រសួងអប់រំយុវជន និងកីឡា មកធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មីៗ។ សៀវភៅនេះចាប់ផ្តើមពី ការរៀន**អំណាន មេសូត្រ និយាយ ស្តាប់ សំណេរ វេយ្យាករណ៍ បំណិន** ដើម្បីឱ្យសិស្សមានបំណិនរឹងមាំក្នុងការអាននិងសរសេរ។

ដើម្បីជាជំនួយដល់ការប្រើប្រាស់សៀវភៅពន្លឿនការសិក្សានេះ បានត្រឹមត្រូវគណៈកម្មការបានរៀបចំសេចក្តីណែនាំដោយផ្តោតលើ៖

១. ការប្រើប្រាស់សម្ភារៈ

២. លំនាំបង្រៀន

I. ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀនលោកគ្រូអ្នកគ្រូ គប្បីប្រើប្រាស់សម្ភារឧបទេស ពីព្រោះវាជាមធ្យោបាយមួយទាក់ទាញទឹកចិត្តសិស្សឱ្យចូលចិត្តរៀន មានការចងចាំតាមរយៈ ការលើកបង្ហាញនិងចង្អុល ធ្វើឱ្យសិស្សបានសប្បាយហើយថែមទាំងយល់មេរៀនបានច្បាស់លាស់ (យល់ន័យពាក្យល្បះនិងអត្ថបទ) ទៀតផង។

សម្ភារៈដែលចាំបាច់បំផុត សម្រាប់បង្រៀនអាននិងសរសេរគឺ មានរូបភាពនិងវត្ថុដាក់ស្តែងផ្សេងទៀតទៅតាមពាក្យ ល្បះ ឬអត្ថបទដែលត្រូវបង្រៀន។

II. លំនាំបង្រៀន

១. បំណិន

សកម្មភាពទី១៖ ទំនាក់ទំនង

- សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន
- សួរសំណួរបំផុសទាក់ទងនឹងចំណងជើង

សកម្មភាពទី២៖ ដាក់បញ្ហា

- ដាក់បញ្ហាផ្ទាល់មាត់ទាក់ទងនឹងបញ្ញត្តិ
- សួរឡើងវិញពីបញ្ហា
- សរសេរ ឬបិទបញ្ហាលើក្តារខៀនរួចឱ្យសិស្សអាន
- សួរកវត្ថុបំណងនៃបញ្ហា តើបញ្ហានេះចង់ឱ្យប្អូនធ្វើអ្វី?
- កែតម្រូវចម្លើយរបស់សិស្ស

សកម្មភាពទី៣៖ ការប៉ាន់ស្មាន

- ឱ្យសិស្សប៉ាន់ស្មាន
- សរសេរចម្លើយសិស្សដាក់លើក្តារខៀននៅជ្រុងម្ខាង

- សួរបញ្ជាក់ពីចម្លើយរបស់សិស្ស តើប្អូនដឹងថាការប៉ាន់ស្មានរបស់ប្អូនពិតជាត្រឹមត្រូវឬទេ? បើមិនទាន់ដឹងច្បាស់ទេ តើអ្នកត្រូវធ្វើដូចម្តេចទៀត? (ពិភាក្សាស្រាវជ្រាវ)

សកម្មភាពទី៤៖ ពិភាក្សាក្រុម

- បិទឧទាហរណ៍លើក្តារខៀន
- ឱ្យសិស្សស្វែងយល់ន័យពាក្យទាំងនោះ បើសិស្សមិនយល់គ្រូត្រូវពន្យល់ពាក្យនោះ
- ណែនាំរបៀបពិភាក្សា៖ តាមរយៈឧទាហរណ៍លើក្តារខៀនប្អូនត្រូវអាន សង្កេត តក់ត្រាទាញជាបញ្ញត្តិ
- ឱ្យសិស្សនិយាយការណែនាំពិភាក្សាឡើងវិញឱ្យបាន២ ឬ៣នាក់
- ចែកក្រុមពិភាក្សាដោយមានប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយ
- ឱ្យសិស្សឡើងយកសម្ភារៈ (ហ្វឺត ក្រដាស...)
- កំណត់រយៈពេល
- ដើរពិនិត្យតាមក្រុម ដើម្បីណែនាំបន្ថែមចំពោះការខ្វះចន្លោះរបស់សិស្សពេលពិភាក្សាក្រុម

សកម្មភាពទី៥៖ រាយការណ៍ក្រុម

- ឱ្យតំណាងក្រុមនីមួយៗយកកិច្ចការរបស់ខ្លួនមកបិទលើក្តារខៀន
- ឱ្យតំណាងក្រុមឡើងបកស្រាយ
- ឱ្យសិស្សនៃក្រុមដទៃទៀតស្តាប់ការបកស្រាយរបស់ក្រុម ហើយបើមានចំណុចណាដែលមិនច្បាស់ក្រុមនោះត្រូវសួរ រីឯក្រុមបកស្រាយត្រូវឆ្លើយ។ បើសិនជាមិនអាចឆ្លើយបាននោះ សិស្សឯទៀត ឬគ្រូត្រូវចូលរួមបកស្រាយទាល់តែបានច្បាស់
- សរសេរការបូកសរុបលើក្តារខៀន

សកម្មភាពទី៦៖ ផ្ទៀងផ្ទាត់ការប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ការប៉ាន់ស្មាន
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៧៖ សិក្សាបញ្ញត្តិ

- ចោទជាសំណួរដើម្បីបង្កើតបញ្ញត្តិ
- គ្រូសំយោគនិងកែលម្អចម្លើយរបស់សិស្ស (ករណីដែលការបូកសរុបមានខ្លឹមសារអាចទទួលយកបាន ហើយគ្រូអាចយកជាបញ្ញត្តិតែម្តង)
- ឱ្យសិស្សអានបញ្ញត្តិ

២. បង្រៀនអំណាន:

សកម្មភាពទី១៖ ចំផុសចំណាងដើម

- គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណងជើង
- សរសេរចំណងជើងដាក់នៅក្តារខៀន រួចឱ្យសិស្សអាន

សកម្មភាពទី២៖ ប៉ាន់ស្មានខ្លឹមសារ

- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសារមេរៀន តាមរយៈរូបភាពនិងចំណងជើង
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន។

សកម្មភាពទី៣៖ អំណានស្ងាត់លើកទី១

- ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ ដើម្បីរកពាក្យពិបាកអាននិងពិបាកយល់ន័យ

- ឱ្យសិស្សសរសេរពាក្យទាំងនោះនៅលើក្តារខៀន (បើមានអត្ថបទនៅលើក្តារខៀន ឬបំណ្ណអត្ថបទគ្រូគប្បីឱ្យសិស្សឡើងគូសពីក្រោមពាក្យទាំងនោះ)

សកម្មភាពទី៤៖ ការអានពាក្យពិបាកនិងពន្យល់ពាក្យ

- ឱ្យសិស្សដែលចេះអាន អានពាក្យពិបាកឱ្យសិស្សឯទៀតស្តាប់និងថាតាម (បើសិស្សទាំងអស់គ្នាមិនចេះអានពាក្យណាមួយគ្រូដឹកនាំសិស្សអាន)
- ហៅសិស្សខ្សោយឱ្យអានពាក្យពិបាកឡើងវិញ
- ដឹកនាំសិស្សឱ្យយល់ន័យពាក្យពិបាកដោយ ប្រើរូបភាព កាយវិការ លើកឧទាហរណ៍ ប្រៀបធ្រៀបសំណួរបំផុស ឬប្រើបទានុក្រម

សកម្មភាពទី៥៖ អំណានស្ងាត់លើកទី២

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅដោយប្រាប់ថា ពួកគេនឹងឆ្លើយសំណួរទាំងនេះនៅពេលអានអត្ថបទរួច
- ឱ្យសិស្សម្នាក់ៗអានអត្ថបទដោយស្ងៀមស្ងាត់ ដើម្បីស្វែងយល់ខ្លឹមសាររបស់អត្ថបទ
- ឱ្យសិស្សឆ្លើយសំណួរម្តងមួយៗ បើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរនោះឡើងវិញ ដើម្បីយល់និងអាចឆ្លើយបាន។
- សម្របសម្រួលចម្លើយសិស្ស

សកម្មភាពទី៦៖ អំណានឮ

- ឱ្យសិស្សពូកែម្នាក់អានអត្ថបទជាគំរូ ឬគ្រូអានជាគំរូដោយឱ្យសិស្សទាំងអស់ស្តាប់
- ឱ្យសិស្សចូលក្រុម អានបណ្តាក់ក្នុងក្រុម ដើម្បីជួយសិស្សខ្សោយ
- ឱ្យសិស្សអានបណ្តាក់ជាបុគ្គលនិងជាក្រុមតូចៗ
- ដើរសម្របសម្រួលការងារក្រុម
- លើកសរសើរក្រុមដែលអានបានល្អ

សកម្មភាពទី៧៖ ផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៨៖ សំយោគខ្លឹមសារ

- សួរសំណួរក្តោបខ្លឹមសារអត្ថបទ ឬបិទសំណួរលើក្តារខៀន
- ឱ្យសិស្សផ្តល់ចម្លើយជាបុគ្គល ឬជាក្រុម (កំណត់រយៈពេល)
- សំយោគខ្លឹមសារ រួចសរសេរលើក្តារខៀនក្រោមពន្យល់ពាក្យ
- ឱ្យសិស្សអានខ្លឹមសារសរុប

៣. បង្រៀនមេសូត្រ

សកម្មភាពទី១៖ បំផុសចំណាងដើង

- គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណាងដើង
- សរសេរចំណាងដើងដាក់នៅក្តារខៀន រួចឱ្យសិស្សអាន

សកម្មភាពទី២៖ ប៉ាន់ស្មានខ្លឹមសារ

- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសារមេរៀន តាមរយៈរូបភាពនិងចំណាងដើង
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន

សកម្មភាពទី៣៖ អំណានស្ងាត់លើកទី១

- ឱ្យសិស្សសូត្រមេសូត្រដោយស្ងៀមស្ងាត់ ដើម្បីរកពាក្យពិបាកអាននិងពិបាកយល់ន័យ
- ឱ្យសិស្សសរសេរពាក្យទាំងនោះនៅលើក្តារខៀន (បើមានអត្ថបទនៅលើក្តារខៀន ឬបំណ្ណអត្ថបទគ្រូគប្បីឱ្យសិស្សឡើងគូសពីក្រោមពាក្យទាំងនោះ)

សកម្មភាពទី៤៖ ការអានពាក្យពិបាកនិងពន្យល់ពាក្យ

- ឱ្យសិស្សដែលចេះអាន អានពាក្យពិបាកឱ្យសិស្សឯទៀតស្តាប់និងថាតាម (បើសិស្សទាំងអស់គ្នាមិនចេះអានពាក្យណាមួយគ្រូដឹកនាំសិស្សអាន)
- ហៅសិស្សខ្សោយឱ្យអានពាក្យពិបាកឡើងវិញ
- ដឹកនាំសិស្សឱ្យយល់ន័យពាក្យពិបាកដោយ ប្រើរូបភាព កាយវិការ លើកឧទាហរណ៍ ប្រៀបធ្រៀបសំណួរបំផុស ឬប្រើបទានុក្រម។

សកម្មភាពទី៥៖ អំណានស្ងាត់លើកទី២

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅដោយប្រាប់ថា ពួកគេនឹងឆ្លើយសំណួរទាំងនេះនៅពេលអានអត្ថបទរួច
- ឱ្យសិស្សម្នាក់ៗអាន ឬសូត្រអត្ថបទកំណាព្យដោយស្ងៀមស្ងាត់ ដើម្បីស្វែងយល់ខ្លឹមសាររបស់អត្ថបទ
- ឱ្យសិស្សឆ្លើយសំណួរម្តងមួយៗបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរនោះឡើងវិញ ដើម្បីយល់និងអាចឆ្លើយបាន
- សម្របសម្រួលចម្លើយសិស្ស

សកម្មភាពទី៦៖ អំណានឮ

- ឱ្យសិស្សពូកែម្នាក់សូត្រ មេសូត្រជាគំរូ ឬគ្រូសូត្រជាគំរូដោយឱ្យសិស្សទាំងអស់សូត្រតាមខ្សឹបៗ
- ឱ្យសិស្សចូលក្រុមសូត្របណ្តាក់ក្នុងក្រុមដើម្បីជួយសិស្សខ្សោយ
- ឱ្យសិស្សសូត្របណ្តាក់ជាបុគ្គលនិងជាក្រុមតូចៗ
- ដើរសម្របសម្រួលការងារក្រុម
- លើកសរសើរក្រុមដែលសូត្របានល្អ

សកម្មភាពទី៧៖ ផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៨៖ សំយោគខ្លឹមសារ

- សួរសំណួរក្តោបខ្លឹមសារអត្ថបទ ឬបិទសំណួរលើក្តាខៀន
- ឱ្យសិស្សផ្តល់ចម្លើយជាបុគ្គល ឬជាក្រុម (កំណត់រយៈពេល)
- សំយោគខ្លឹមសាររួចសរសេរលើក្តារខៀនក្រោមពន្យល់ពាក្យ
- ឱ្យសិស្សអានខ្លឹមសារសរុប

៤. បង្រៀនស្តាប់

សកម្មភាពទី១៖ បំផុសចំណាងដើង

- សួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណាងដើង
- សរសេរចំណាងដើងដាក់នៅក្តារខៀន រួចឱ្យសិស្សអាន

សកម្មភាពទី២៖ ប៉ាន់ស្មានខ្លឹមសារ

- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសាររឿង តាមរយៈរូបភាពនិងចំណងជើង
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន

សកម្មភាពទី៣៖ និទានរឿង

- ឱ្យសិស្សអានសំណួរ ដើម្បីត្រៀមឆ្លើយនៅពេលគ្រូនិទានចប់
- និទានរឿង១ទៅ២ចប់ឱ្យសិស្សស្តាប់ព្រមទាំងបង្ហាញរូបភាពម្តងមួយផ្ទាំងៗតាមសាច់រឿង
- សរសេរពាក្យពិបាកមួយចំនួននៅក្នុងអត្ថបទដែលគ្រូគិតថាសិស្សមិនទាន់យល់ន័យ
- ដឹកនាំសិស្សអាននិងពន្យល់ន័យដោយប្រើរូបភាព រកន័យដូច រកន័យផ្ទុយ សំណួរបំផុស...

សកម្មភាពទី៤៖ សួរសំណួរ

- ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស បើសិស្សឆ្លើយសំណួរណាមួយមិនបានគ្រូត្រូវនិទានរឿងត្រង់ផ្នែកនោះឡើងវិញ ដើម្បីឱ្យសិស្សស្តាប់និងអាចឆ្លើយបាន
- សួរសំណួរថ្មីបន្ថែមផ្សារភ្ជាប់បទពិសោធដែលសិស្សរៀនរួច ទៅនឹងបទពិសោធជាក់ស្តែងដែលសិស្សជួបប្រទះក្នុងការរស់នៅ

សកម្មភាពទី៥៖ ធ្វើឆ្លាត់ចម្លើយប៉ាន់ស្មាន

- ដឹកនាំសិស្សធ្វើឆ្លាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសាររឿង
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៦៖ សំយោគខ្លឹមសារ

- សួរសំណួរក្តោបខ្លឹមសាររឿង ឬបិទសំណួរលើក្តាខៀន
- ឱ្យសិស្សផ្តល់ចម្លើយជាបុគ្គល ឬជាក្រុម (កំណត់រយៈពេល)
- សំយោគខ្លឹមសារួចសរសេរលើក្តារខៀនក្រោមពន្យល់ពាក្យ
- ឱ្យសិស្សអានខ្លឹមសារសេរុប

៥. បង្រៀនឥយ្យា

សកម្មភាពទី១៖ ទំនាក់ទំនងមេរៀន

- សួរសំណួរបំផុសដើម្បីស្ទាបស្ទង់ចំណេះដឹងសិស្សដែលមានស្រាប់ដោយឱ្យសិស្សនិយាយ ឆ្លើយ ឬបង្ហាញពីអ្វីដែលពួកគេធ្លាប់ដឹងរួចមកហើយទាក់ទងនឹងមេរៀនថ្មី
- សរសេរចំណងជើងមេរៀននៅលើក្តាខៀន
- សួរសំណួរបំផុសទាក់ទងនឹងចំណងជើង
- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសារតាមរយៈចំណងជើងនិងរូបភាព
- សរសេរចម្លើយប៉ាន់ស្មាននៅក្តារខៀន

សកម្មភាពទី២៖ សន្ទនាលើកទី១

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្ស
- ជ្រើសរើសសិស្សតាមចំនួនតួអង្គមកដើរតួ ដោយឱ្យសិស្សទាំងនោះដើរតួជាតួអង្គតាមខ្លឹមសារនៃបទសន្ទនា និងស្វែងយល់អត្ថបទគំរូ។ សិស្សឯទៀតតាមដានស្តាប់ទាំងខ្លឹមសារនិងការលើកដាក់សំឡេង
- សួរសំណួរលម្អិតអត្ថបទ (សំណួរក្នុងសៀវភៅសិស្ស) ដើម្បីស្ទាបស្ទង់ការយល់ដឹងរបស់សិស្ស
- សួរសំណួរទាក់ទងនឹងសំនួន ឬពាក្យចាំបាច់ដែលត្រូវសន្ទនា
- ធ្វើឆ្លាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ

សកម្មភាពទី៣៖ សន្ទនាលើកទី២

- ចែកសិស្សជាក្រុមតូចៗ (សមាជិកក្រុមអ្រាចប្រែប្រួលទៅតាមប្រធានបទ) រួចឱ្យក្រុមនីមួយៗហ្វឹកហាត់សន្ទនាតាមអត្ថបទគំរូក្នុងសៀវភៅដោយចាត់គ្នាពីរ ឬបីនាក់ម្តង(តាមខ្លឹមសារនៃបទសន្ទនា) រហូតចេះចាំស្ទាត់គ្រប់ៗគ្នាដោយជួយគ្នានៅក្នុងក្រុម
- ដើរសម្របសម្រួលនិងកែលម្អតាមក្រុម

សកម្មភាពទី៣៖ សន្ទនាលើកទី៣(ល្បែងដើរតួ)

- ឱ្យសិស្សរៀបចំការសន្ទនាដោយប្រើប្រាស់ប្រយោគផ្ទាល់ខ្លួនតាមក្រុម
- ឱ្យសិស្សក្នុងក្រុមនីមួយៗសាកល្បងសន្ទនានៅនឹងកន្លែងរៀងៗខ្លួន
- បិទ ឬគូសតារាងវាយតម្លៃលើក្តារខៀនរួចពន្យល់ពីរបៀបវាយតម្លៃ

ល.រ.	លក្ខខណ្ឌនៃការវាយតម្លៃ	ខ្សោយ	មធ្យម	ល្អ	ល្អណាស់
១	កាយវិការ				
២	ការលើកដាក់សំឡេង				
៣	ខ្លឹមសារ				
៤	ការបញ្ចេញសំឡេង				

- ឱ្យសិស្សឯទៀតគូសតារាងក្នុងសៀវភៅរបស់ខ្លួន
- ឱ្យក្រុមនីមួយៗឡើងសន្ទនាដោយមានគ្នា(តាមខ្លឹមសារនៃបទសន្ទនា)
- ឱ្យសិស្សទាំងអស់ចូលរួមកែលម្អដោយប្រើតារាងវាយតម្លៃខាងលើ នៅពេលក្រុមនីមួយៗសន្ទនាចប់
- ឱ្យសិស្សជ្រើសរើសក្រុមដែលសម្តែងបានល្អជាងគេ
- លើកសរសើរក្រុមដែលសម្តែងបានល្អ រួចឱ្យសិស្សទះដៃអបអរសាទរ

សម្គាល់៖ តារាងលក្ខខណ្ឌនៃការវាយតម្លៃអាចប្រែប្រួលទៅតាមខ្លឹមសារនៃប្រធានបទ

៦. បង្រៀនវេយ្យាករណ៍

បញ្ជាក់៖ សម្រាប់ការបង្រៀនវេយ្យាករណ៍សូមយកលំនាំតាមការបង្រៀនបំណិន

៧. បង្រៀនសំណេរ

ក. បែបបំពេញល្បះ ឬតែងល្បះតាមរូបភាព

សកម្មភាពទី១៖ បង្ហាញរូបភាព ឬល្បះ

- លើករូបភាពបង្ហាញ ឬបិទនៅលើក្តារខៀនរួចសួរ៖ តើនេះជារូបភាពអ្វី? អ្នកឃើញមានអ្វីខ្លះ? ឱ្យសិស្សអានល្បះទី១ រួចសួរ៖ តើអ្នកយល់ល្បះនេះឬទេ? តើអ្នកធ្វើដូចម្តេចដើម្បីយល់ល្បះនេះ? (ចម្លើយ៖ ត្រូវបំពេញពាក្យក្នុងចន្លោះល្បះ)។ តើអ្នកបំពេញយ៉ាងដូចម្តេច? (ត្រូវអានពាក្យក្នុងប្រអប់មុននឹងបំពេញ) តើអ្នកអានដើម្បីអ្វី? ដើម្បីដឹងថាត្រូវជ្រើសរើសយកពាក្យណាមួយមកបំពេញឱ្យត្រូវន័យនៃល្បះនិងរូបភាពនីមួយៗនោះ។

សកម្មភាពទី២៖ តែង ឬបំពេញល្បះ

- ចម្លងលំហាត់ដាក់លើក្តារខៀន រួចឱ្យសិស្ស២ ឬ៣នាក់អាន ឯសិស្សដទៃទៀតតាមដានស្តាប់ដោយយកចិត្តទុកដាក់។
- ណែនាំសិស្សបន្ថែមពីរបៀបធ្វើលំហាត់បំពេញល្បះនឹងពាក្យ រួចឱ្យសិស្សនិយាយឡើងវិញពីលំហាត់
- ឱ្យសិស្សសាកល្បងបំពេញ និងអានល្បះដែលបំពេញហើយនោះ
- កែលម្អចំណុចចន្លោះខាត

- ឱ្យសិស្សអានលំណែនាំលំហាត់រួចគ្រូសួរ៖ តើក្នុងលំហាត់នេះចង់ឱ្យប្អូនធ្វើអ្វី? (តែងល្បះតាមរូបភាព)។ តើនេះជារូបភាពអ្វី? តើពួកគេកំពុងធ្វើអ្វី? ចូរអ្នកហាត់តែងល្បះដោយមាត់ទទេរទាក់ទងនឹងរូបភាពទី១សាកមើល។ ឱ្យសិស្សដទៃជួយកែលម្អ។

ខ. បែបសំណេរកថាខណ្ឌ

សកម្មភាពទី១៖ ចំណាក់ចំនងមេរៀន

- សួរសំណួរណាដែលទាក់ទងទៅនឹងប្រធានបទដែលយកមកបង្រៀន

សកម្មភាពទី២៖ ប្រមូលគំនិត

- ឱ្យសិស្សអានប្រធានបទ អានសំណួរ សង្កេតរូបភាព
- ឱ្យសិស្សផ្តល់ព័ត៌មានដែលទាក់ទងនឹងប្រធានបទ តាមរយៈសំណួរ រូបភាព ...
- សរសេរចម្លើយរបស់សិស្សជាកន្សោមពាក្យលើក្តារខៀន

សកម្មភាពទី៣៖ សំណេរព្រាង

- ឱ្យសិស្សអានឡើងវិញនូវព័ត៌មាន ឬគំនិតសំខាន់ៗដែលទាក់ទងនឹងប្រធានបទ
- ដឹកនាំសិស្សលុបព័ត៌មាន ឬគំនិតដែលមិនទាក់ទងនឹងប្រធានបទ
- ឱ្យសិស្សរៀបព័ត៌មាន ឬគំនិតទាំងនោះតាមលំដាប់លំដោយ
- ឱ្យសិស្សនិយាយពង្រីកគំនិតនីមួយៗឱ្យទៅជាល្បះពេញលេញ
- សរសេរតាមការនិយាយរបស់សិស្សលើក្តារខៀន
- ដឹកនាំសិស្សភ្ជាប់ល្បះនីមួយៗឱ្យទៅជាទម្រង់កថាខណ្ឌ

សកម្មភាពទី៤៖ កែលម្អសំណេរព្រាង

- ឱ្យសិស្សពិនិត្យសំណេរព្រាងឱ្យបានត្រឹមត្រូវលើ៖
  - លំដាប់លំដោយនៃគំនិត
  - ទម្រង់ល្បះ
  - អក្ខាវិរុទ្ធ។
- ជើរពិនិត្យសកម្មភាពសិស្ស

សកម្មភាពទី៥៖ សរសេរសម្រេច

- ឱ្យសិស្សសរសេរឡើងវិញដោយយកចិត្តទុកដាក់តាមសំណេរព្រាង

៨. បង្រៀនសរសេរតាមអាន

ក. សរសេរតាមអានចម្លង (១ម៉ោង)

សកម្មភាពទី១៖ បង្ហាញពាក្យ

- សរសេរ ឬបិទពាក្យមួយចំនួននៅលើក្តារខៀន

សកម្មភាពទី២៖ អានពាក្យ

- អានពាក្យម្តងមួយៗឱ្យច្បាស់ៗហើយឱ្យសិស្ស ២-៣នាក់ ឡើងចង្អុលពាក្យនីមួយៗរួចអានតាម
- ចង្អុលពាក្យទី១ និងអានម្តងទៀត
- ឱ្យសិស្សធ្វើអក្ខរវិញ្ញាសពាក្យនោះ រួចឱ្យសិស្សសរសេរនៅលើក្តារឆ្នួនទាំងអស់គ្នា
- ត្រួតពិនិត្យនិងឱ្យសិស្សដែលសរសេរខុសកែឱ្យត្រូវឡើងវិញ
- ចង្អុលពាក្យទី២ ទី៣ ...រហូតគ្រប់ពាក្យ ហើយធ្វើតាមលំនាំការបង្រៀនពាក្យទី១ដែរ

សកម្មភាពទី៣៖ សរសេរពាក្យក្នុងសៀវភៅ

- បិទវាំននក្តារខៀន
- ហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ
- ហៅពាក្យឡើងវិញឱ្យសិស្សផ្ទៀងផ្ទាត់
- ទុកពេលឱ្យសិស្សត្រួតពិនិត្យនិងកែកំហុស
- ឱ្យសិស្សប្តូរគ្នាកែដោយផ្ទៀងផ្ទាត់ជាមួយពាក្យនៅលើក្តារខៀន(បើការាំងនន)
- ប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ

ខ. សរសេរតាមអានរៀបចំ (១ម៉ោង)

សកម្មភាពទី១៖ បច្ចាញ្ញអត្ថបទ

- ចម្លង ឬបិទពាក្យ ឃ្លា ល្បះ ឬអត្ថបទដាក់លើក្តារខៀន
- អានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម
- អានអត្ថបទដោយយឺតៗច្បាស់ៗ រួចឱ្យសិស្ស២ ឬ ៣នាក់អានឡើងវិញ

សកម្មភាពទី២៖ អានពាក្យពិបាកក្នុងអត្ថបទ

- អានពាក្យនេះម្តងមួយៗ ឱ្យច្បាស់ៗឱ្យសិស្សចង្អុលពាក្យ និងអានតាម ២-៣នាក់
- អានពាក្យទាំងនោះដោយចង្អុលផង រួចឱ្យសិស្សធ្វើអក្ខរាវិញ្ញាសនិងឱ្យសរសេរលើក្តារឆ្លួនទាំងអស់គ្នា
- ពិនិត្យនិងឱ្យសិស្សដែលសរសេរខុសកែឱ្យបានត្រូវឡើងវិញ
- បន្តទៅពាក្យទី២ ទី៣រហូតដល់ចប់ដោយធ្វើតាមលំនាំបង្រៀនដូចពាក្យទី១

សកម្មភាពទី៣៖ សរសេរអត្ថបទជាក់ក្នុងសៀវភៅ

- លាក់អត្ថបទ រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅមួយឃ្លាម្តងៗ រហូតដល់ចប់
- អានអត្ថបទឡើងវិញឱ្យសិស្សស្តាប់និងផ្ទៀងផ្ទាត់ឡើងវិញ
- រួចទុកពេលឱ្យសិស្សពិនិត្យ និងកែកំហុសរៀងៗខ្លួន
- ឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្តារខៀន
- ប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ

គ. សរសេរតាមអានត្រួតពិនិត្យ (១ម៉ោង)

សកម្មភាពទី១៖ អាន...

- អានពាក្យ កន្សោមពាក្យ កថាខណ្ឌ ឬអត្ថបទខ្លីៗដែលតម្រូវឱ្យសិស្សសរសេរ
- ឱ្យសិស្សទាំងអស់ស្តាប់ ដោយអានឱ្យឮនិងច្បាស់ៗ

សកម្មភាពទី២៖ សរសេរក្នុងសៀវភៅ

- អាន (ហៅ) ពាក្យ កន្សោមពាក្យ ឬឃ្លាខ្លីៗ បីដងឱ្យសិស្សសរសេរតាម ម្តងមួយៗ រហូតដល់ចប់
- អានឱ្យសិស្ស២នាក់ថាតាមក្រោយពីគ្រូអាន សិស្សទាំងអស់សរសេរ ដោយសិស្សម្នាក់ថាបន្ទាប់ពីគ្រូអាន ហើយម្នាក់ទៀតថាបន្ទាប់ពីខ្លួនសរសេររួច។
- អានឱ្យសិស្សស្តាប់ឡើងវិញដោយយឺតៗនិងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវពាក្យឬកន្សោមពាក្យដែលគេសរសេរលើងឬខុស។
- ទុកពេលសមល្មមឱ្យសិស្សកែនិងបំពេញបន្ថែម
- ឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្តារខៀន ឬសៀវភៅពុម្ព
- ប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ

ចំណាំ : ចំពោះការសរសេរតាមអានត្រួតពិនិត្យ លោកគ្រូ អ្នកគ្រូអាចអនុវត្តទៅតាមលទ្ធភាពដែលអាចធ្វើបាន។

ផ្នែកទី៤
សណាកប័ត្រជំពូកនិងមេរៀន

ជំពូកទី១

វិជនផ្ដើម

រយៈពេល	15ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ការប្រើវចនានុក្រម
មេរៀនទី2	បំណិន៖ ការប្រៀបធៀបតួអង្គ
មេរៀនទី3	ស្ដាប់៖ រឿង ចចកនិងកំពឹស
មេរៀនទី4	វេយ្យាករណ៍៖ គុណនាមប្រក្រតី
មេរៀនទី5	អំណាន៖ សម្ដេចព្រះសង្ឃរាជ ជួន ណាត
មេរៀនទី6	និយាយ៖ ការពណ៌នាអំពីជនគំរូ
មេរៀនទី7	អំណាន៖ វីរបុរសក្រឡាហោមគង់
មេរៀនទី8	សំណេរ៖ ការពណ៌នាអំពីតួអង្គ

មេរៀនទី1	**បំណិន៖ ការប្រើវចនានុក្រម**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់វចនានុក្រមបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី2 ដល់ទី4 រូបភាពទំព័រទី2 សៀវភៅវចនានុក្រមពិត
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
ចម្លើយនៃសំណួរ	
កំណែលំហាត់	**លំហាត់ទី1៖** ក. (គុ) គឺជាថ្នាក់ពាក្យ។ - ដែលគ្រប់គ្រាន់ ដែលពេញគ្រប់គ្រាន់ ពេញលេញ សម្បូរ ដែលឆ្អែត គឺជាន័យរបស់មេពាក្យ។ ខ. (ន) គឺជាថ្នាក់ពាក្យ។ - ការចម្អែតអាត្មា(ស៊ី) គឺជាន័យរបស់មេពាក្យ។ គ. (ន) គឺជាថ្នាក់ពាក្យ។ - សេចក្ដីអធិប្បាយដោយផ្សេងៗ ការអធិប្បាយ សម្រួលសេចក្ដី គឺជាន័យរបស់មេពាក្យ។ ឃ. (គុ) គឺជាថ្នាក់ពាក្យ។ - ដែលស្អាតឥតសៅហ្មង ឥតមោះមៃ គឺជាន័យរបស់មេពាក្យ។ ង. (គុ) គឺជាថ្នាក់ពាក្យ។

	- ប្រសើរ លើសលែង ថ្លៃថ្លា គឺជានិយមរបស់មេពាក្យ។ **លំហាត់ទី2៖** គង្គា (ន) ឈ្មោះទន្លេធំមួយ ឬមួយទៀតគេប្រើក្លាយមកហៅចំពោះទឹកតែម្តង។ មាតា (ន) ម្តាយ ម៉ែ។ មេត្តា (ន) សេចក្តីរាប់រក សេចក្តីប្រណី សេចក្តីរាប់អានគ្នា។ សោមនស្ស (ន) សេចក្តីសប្បាយចិត្ត សេចក្តីរីករាយសប្បាយ អំណរ។ ឧបការី (ន) អ្នកទំនុកបំរុង អ្នកផ្គត់ផ្គង់ ឬផ្ទុងផ្តើម។ ឧបត្ថម្ភ (កិ) ទំនុកបម្រុង ទ្រទ្រង់ គាំទ្រ ពឹងផ្អែក។

មេរៀនទី2	**បំណិន៖ ការប្រៀបធៀបតួអង្គ**
រយៈពេល	2ម៉
វត្ថុបំណង	ប្រៀបធៀបតួអង្គបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី5 ដល់ទី6
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់៖** ប្រៀបធៀបតួអង្គនិននិងគំនិត - និនជាក្មេងដែលមិនយកចិត្តទុកដាក់នឹងការងារជាមួយឪពុកទេ ហើយតែងដោះសាថា រវល់រៀនសូត្រ ឬធ្វើនេះធ្វើនោះជានិច្ច។ ប៉ុន្តែគេគេចទៅដើរលេងជាមួយមិត្តភក្តិ។ - គំនិតជាក្មេងល្អ ឆ្លៀតពេលទំនេរពីការសិក្សាគេតែងជួយឪពុកមាហើយយល់ច្បាស់ពីរូបមន្តក្នុងការលាយលំកនិងរបៀបជ្រលក់អំបោះ ។ ដូច្នេះនៅពេលអត់ពីឪពុកមាទៅ គេក៏អាចបន្តរបរជ្រលក់អំបោះនេះបានដែរ។

មេរៀនទី3	**ការស្តាប់៖ រឿង ចចកនិងកំពឹស**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ភាពឆ្លាតរបស់សត្វកំពឹសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី7 ដល់ទី8 រូបភាពទំព័រទី7
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ក្នុងរឿងនេះមានតួអង្គ ចចក កំពឹស ត្រីក្រាញ់ ទន្សាយ។ 2. រឿងនេះកើតឡើងនៅរដូវប្រាំង កន្លែងកូនថ្កុកមួយ។ 3. ដើម្បីជួយហ្វូងមច្ឆជាតិ ទន្សាយបានបេះស្លឹកឈើមានស្នាមដង្កូវរារលើមកប្រកាស៖ «ព្រះឥន្ទ្រនឹងកាច់ជើងត្រុំ ប្រមុំជើងអក កាប់ក្បាលចចក ដកក្តុកជំរីសារ កាប់ក្បាលសត្វ ខ្លាឱ្យជ្រៅជាងគេ វះពោះសត្វកេ កាត់កពោះថ្លាន់»។ 4. ភាពឆេវឆាវរបស់ចចកមិនធ្វើឱ្យសម្រេចដល់គោលដៅទេ ព្រោះត្រូវបរាជ័យដោយសារការតស៊ូព្យាយាម របស់ត្រី និងភាពឆ្លាតវៃរបស់ទន្សាយ។ 5. រឿងនេះអប់រំយើងឱ្យចេះប្រើប្រាជ្ញាក្នុងការដោះស្រាយបញ្ហា កុំមានចិត្តឆេវឆាវអាង

	កម្លាំងបាយ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ក្លាហាន ខ. ឆ្លាតវៃ គ. ឆោតល្ងង់ ឃ. ឆ្លាតវាងវៃ **លំហាត់ទី2៖** - ចចកជាសត្វឆោតល្ងង់មានភាពឆេវឆាវអាងកម្លាំង - ត្រីក្រាញ់ជាសត្វក្លាហានមានការតស៊ូព្យាយាម ដើម្បីទៅឱ្យទន្សាយជួយកាត់ក្តី។ **លំហាត់ទី3៖** (សិស្សនិទានរឿងតាមភាពជាក់ស្តែង)

មេរៀនទី4	**វេយ្យាករណ៍៖ គុណនាមប្រក្រតី**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់គុណនាមប្រក្រតីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី9 ដល់ទី10
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ខ. ស្លូត ឃ. ឧស្សាហ៍ **លំហាត់ទី2៖** ក. ប្រៃ ខ. ស្គម គ. ផ្នើម ឃ. ខ្មៅ **លំហាត់ទី3៖** ក. ស ខ. ធំៗ គ. ស និងវែង ឃ. ពូកែ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. ទីក្រុងភ្នំពេញមានអគារខ្ពស់ៗ។ ខ. ទីនេះមានមនុស្សច្រើន។ គ. ដើរវាក្តៅរុក្ខជាតិស្វិតស្រពោន។

មេរៀនទី5	**អំណាន៖ សម្តេចព្រះសង្ឃរាជ ជួន ណាត**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីប្រវត្តិសម្តេចព្រះសង្ឃរាជ ជួន ណាតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី11 ដល់ទី12 រូបភាព៖ សម្តេចព្រះសង្ឃរាជ ជួន ណាត
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. សម្តេចព្រះសង្ឃរាជ ជួន ណាតប្រសូតនៅថ្ងៃ ១១រោច ខែផល្គុន ឆ្នាំវក ត្រូវនឹងថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៨៨៣។ 2. សម្តេចព្រះសង្ឃរាជ ជួន ណាតប្រសូតនៅភូមិកំរៀង ឃុំ រកាកោះ ស្រុកគងពីសី ខេត្ត កំពង់ស្ពឺ។ 3. សម្តេចព្រះសង្ឃរាជ ជួន ណាតមានស្នាព្រះហស្តធំៗជាច្រើនទាំងខាងផ្លូវលោក ផ្លូវ

	ធម៌។ លោកបានចូលរួមមានកសាងសាលារៀន មន្ទីរពេទ្យ ស្ពាន ថ្នល់ ទំនប់ទឹក វចនានុក្រមខ្មែរ ចម្រៀងបទនគរាជ (ចម្រៀងគោរពទង់ជាតិសព្វថ្ងៃ)។ ខាងផ្លូវធម៌ លោកបាននិពន្ធសៀវភៅធម៌នានា ប្រែគម្ពីរព្រះត្រៃបិដក កសាងវត្តអារាម។ល។ 4. ស្នាព្រះហស្តដែលល្បីល្បាញជាងគេគឺ វចនានុក្រមខ្មែរនិងចម្រៀងបទនគរាជ។ 5. ខិតខំរៀនសូត្រ រក្សាតម្លៃមរតកខ្មែរឱ្យបានគង់វង្ស និងរីកចម្រើនថែមទៀត។
កំណែលំហាត់	**លំហាត់ទី1៖** ក. ៤កថាខណ្ឌ ខ. ស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជជួន ណាត គ. សម្តេចព្រះសង្ឃរាជជួន ណាតមានស្នាព្រះហស្តទាំងផ្លូវលោកនិងផ្លូវធម៌។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) ល្អ ធំៗ

មេរៀនទី6	**ការនិយាយ៖ ការពណ៌នាអំពីជនគំរូ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់អំពីសកម្មភាពជនគំរូបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី13
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. កែវនិងកននិយាយគ្នាពីភាពរីកចម្រើននៃភូមិរបស់ពួកគេ។ 2. បានជាភូមិរបស់កនមានការរីកចម្រើន ព្រោះមេភូមិរបស់គេធាប់យល់ការងារ ចេះរៀបចំផែនការដើម្បីអភិវឌ្ឍភូមិ ចេះធ្វើឱ្យប្រជាជនជឿជាក់និងចូលរួមសហការ។ 3. ប្រធានភូមិរបស់កនជាមនុស្សដែលមានការឈ្លាសវៃ ស្មោះត្រង់ មិនកេងប្រវ័ញ្ចផលប្រយោជន៍ប្រជាជន។ ម៉្យាងទៀតគាត់លះបង់ពេលវេលានិងកម្លាំងកាយចិត្ត ដើម្បីជួយប្រជាជន។
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)

មេរៀនទី7	**អំណាន៖ វីរបុរសក្រឡាហោមគង់**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីវីរភាពរបស់ក្រឡាហោមគង់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី14 ដល់ទី15 រូបភាពទំព័រទី14
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ប្រទេសកម្ពុជាបានបាត់វីរបុរសក្រឡាហោមគង់ដោយពួកអាណានិគមបារាំងចាប់យកទៅធ្វើទាសករណកម្មដោយសម្ងាត់។ 2. បានជាវីរបុរសក្រឡាហោមគង់សុខចិត្តពលីជីវិតព្រោះ ដើម្បីរើបម្រះចេញពីនឹមត្រួតត្រារបស់បារាំង។

	3. នៅដើម្បីមចុងក្រោយវីរបុរសរូបនេះបាននឹកដល់គុណឪពុកម្តាយ ព្រះសង្ឃ ប្រជាជនខ្មែរ និងនឹកដល់កម្ពុជាមាតុភូមិជាទីស្នេហារបស់លោក។ 4. ក្រឡាហោមគង់ជាមនុស្សស្នេហាជាតិ មានចិត្តអង់អាចក្លាហាន តស៊ូប្រឆាំងនឹងបរទេសឈ្លានពាន។ 5. ខ្ញុំស្រឡាញ់ អាណិតវីរបុរសក្រឡាហោមគង់ព្រោះ គាត់ជាមន្ត្រីស្នេហាជាតិនិងបានធ្វើពលិកម្មយ៉ាងធំធេងដើម្បីជាតិមាតុភូមិ។ 6. អត្ថបទនេះ អប់រំឱ្យមានទឹកចិត្តស្នេហាជាតិ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ទារុណកម្ម (ន) អំពើអាក្រក់ អំពើសាហាវយង់ឃ្នង។ ខ. ពលិកម្ម (ន) ការលះបង់កម្លាំងកាយចិត្ត។ គ. វីរបុរស (ន) បុរសអង់អាច។ ឃ. វីរភាព (ន) ភាពអង់អាច ដំណើរអង់អាច។ **លំហាត់ទី2៖** ក. ការរើបម្រះចេញពីនឹមគ្រួតគ្រារបស់បារាំង។ ខ. ការធ្វើទារុណកម្មលើក្រឡាហោមគង់

មេរៀនទី 8	**បំនិន៖ វេរចនសព្ទនិងបជិសព្ទ**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់វេរចនសព្ទនិងបជិសព្ទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី16 ដល់ទី17
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ខ. ធ្វើតាម **លំហាត់ទី2៖** គ. សម្លាប់ **លំហាត់ទី3៖** ក. លំអាន **លំហាត់ទី4៖** គ. ថ្លៃថ្លា **លំហាត់ទី5៖** ខ. ពិសា **លំហាត់ទី6៖** ខ. រស់ **លំហាត់ទី7៖** ក. បែកបាក់

មេរៀនទី 9	**សំណេរ៖ ការពណ៌នាអំពីតួអង្គ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាពីវីរភាពរបស់តួអង្គនៅក្នុងរឿងណាមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី18 ដល់ទី19
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23

កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) ពណ៌នាអំពីវីរភាពរបស់តួអង្គត្រីក្រាញ់នៅក្នុងរឿងចចកនិងកំពឹសៗ គម្រោងតែង 1. សេចក្តីផ្តើម ឈ្មោះតួអង្គនិងឈ្មោះរឿង 2. តួសេចក្តី - រូបសម្បត្តិ រូបរាង សម្បុរ មុខរបរ (ប្រសិនបើកមាន) - ចរិយាសម្បត្តិ ស្លូត កាច ព្យាយាម ... (តាមសាច់រឿងបញ្ជាក់) - សកម្មភាព (តាមសាច់រឿងបញ្ជាក់) 3. សេចក្តីបញ្ចប់ ចំណាប់អារម្មណ៍របស់អ្នកសរសេរ

ជំពូកទី២

សម្បត្តិអក្សរសិល្ប៍

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ការឆ្លើយនឹងសំណួរដោយផ្អែកលើអំណៈអំណាង
មេរៀនទី2	អំណាន៖ រឿង ភ្នំប្រុស ភ្នំស្រី
មេរៀនទី3	ស្តាប់៖ រឿង ក្រពើនិងអ្នកបរទេះ
មេរៀនទី4	វេយ្យាករណ៍៖ គុណនាមកំណត់
មេរៀនទី5	បំណិន៖ សទិសសព្ទ
មេរៀនទី6	និយាយ៖ ការនិទានរឿងឡើងវិញ
មេរៀនទី7	សំណេរ៖ ការតាក់តែងរឿងខ្លី

មេរៀនទី1	**បំណិន៖ ការឆ្លើយនឹងសំណួរដោយផ្អែកលើអំណៈអំណាង**
រយៈពេល	2ម៉
វត្ថុបំណង	ឆ្លើយនឹងសំណួរដោយផ្អែកលើអំណៈអំណាងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី21 ដល់ទី22
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** យី! សត្វនេះអីក៏អាក្រក់ម្ល៉េះ! នរណាឱ្យឯងមកលេងលើផ្កានេះ ហើយធ្វើឱ្យផ្កាប្រឡាក់ប្រឡូសយ៉ាងនេះ។ ចូរឯងដើរចេញទៅ! **លំហាត់ទី2៖** **ចម្លើយ៖** កូនមេអំបៅជាកូនសត្វដែលភ្លេចកំណើតខ្លួន មានអំណត។ **អំណៈអំណាង៖** យី! សត្វនេះអីក៏អាក្រក់ម្ល៉េះ! នរណាឱ្យឯងមកលេងលើផ្កានេះហើយធ្វើឱ្យផ្កាប្រឡាក់ប្រឡូសយ៉ាងនេះ។ ចូរឯងដើរចេញទៅ!

មេរៀនទី2	**អំណាន៖ រឿង ភ្នំប្រុស ភ្នំស្រី**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីប្រវត្តិនៃការកកើតភ្នំប្រុស ភ្នំស្រីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី23 ដល់ទី24

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រជ្ជកាលស្តេចស្រីព្រះនាមស្រីអយុធ្យាគឺ ស្រីៗទៅដណ្តឹងប្រុសធ្វើប្តី។ 2. បានជាស្រីៗមានគំនិតរើបម្រះដោយសារស្រីៗមានរូបឆោមពុំស្អាត ពិបាករកប្តីណាស់ ព្រោះពួកប្រុសៗពុំយកធ្វើជាប្រពន្ធ។ 3. ដើម្បីរើបម្រះស្រីៗប្រើមធ្យោបាយបបួលប្រុសៗភ្នាល់គ្នាដោយលើកដីពូនជាភ្នំ។ 4. បានជាពួកស្រីៗភ្នាល់ឈ្នះប្រុសៗ ដោយសារពួកស្រីៗមានឧបាយកលនាំគ្នាបង្ហូតគោមមួយយ៉ាងខ្ពស់នៅជ្រុងឦសានភ្នំ។ 5. ភ្នំប្រុសភ្នំស្រីបច្ចុប្បន្នស្ថិតនៅក្នុងខេត្តកំពង់ចាម។
កំណែលំហាត់	**លំហាត់ទី1៖** ក. ខកចិត្តនិងខ្មាសអៀន ព្រោះចាញ់កលស្រីៗ។ ខ. ត្រូវចេះប្រើប្រាជ្ញារួមផ្សំ ទើបទទួលបានជោគជ័យ។ **លំហាត់ទី2៖** **ចម្លើយ៖** ស្រីៗឈ្នះប្រុសៗដោយវិធីប្រើឧបាយកល។ **អំណៈអំណាង៖** ពួកប្រុសៗមើលទៅលើឃើញគោមស្រីៗបង្ហូត ស្មានថា ផ្តាយព្រឹករះក៏បបួលគ្នាឈប់ធ្វើការនាំគ្នានិទ្រាលក់គ្មានសល់ម្នាក់។

មេរៀនទី3	**ការស្តាប់៖ រឿង ក្រពើនិងអ្នកបរទេះ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់សកម្មភាពរមិលគុណរបស់តួអង្គក្រពើបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី25 ដល់ទី26 រូបភាពទំព័រទី25
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ក្រពើរស់នៅក្នុងបឹងធំ។ 2. បានជាក្រពើសុំដោយសារបរទេះតា ព្រោះទឹកបឹងនោះរីងស្ងួតអស់ ហើយក្រពើរស់នៅពុំបាន។ 3. ពេលទៅដល់បឹងមានទឹកក្រពើចង់បានគោតាមួយស៊ី។ 4. តាមិនយល់ព្រមទេហើយគាត់ក៏ឱ្យទន្សាយជួយរកយុត្តិធម៌។ 5. បានជាទន្សាយឱ្យតាចងក្រពើម្តងទៀត ព្រោះក្រពើជាសត្វរមិលគុណ ដូចនេះទន្សាយចង់ធ្វើបាបក្រពើវិញ។ 6. សត្វរមិលគុណនេះទទួលលទ្ធផលគឺស្លាប់។ 7. ក្នុងរឿងនេះ ខ្ញុំស្រឡាញ់តួអង្គទន្សាយ ព្រោះជាសត្វមានប្រាជ្ញាឈ្លាសវៃ។
កំណែលំហាត់	**លំហាត់ទី1៖** ក. កិតក័យ ព្រោះខ្លាចក្រពើស៊ី ខ. ត្រូវចេះដឹងគុណអ្នកដែលបានជួយយើង

លំហាត់ទី2៖ (ចម្លើយជាក់ស្តែង)

មានសត្វក្រពើមួយអាស្រ័យនៅបឹងធំ។ រដូវប្រាំងទឹកបឹងរីងស្ងួតអស់ ក្រពើនោះនៅពុំបាន ទើបវារឡើងលើគោករកទីមានទឹក។ មានតាចាស់ម្នាក់បររទេះមកបានជួបនឹងក្រពើនៅកណ្តាលផ្លូវ។ ក្រពើក៏សុំដោយសារទៅរកកន្លែងមានទឹក។ ក្រពើខ្លាចធ្លាក់ ទើបឱ្យតាចងខ្លួនភ្ជាប់នឹងទូកររទេះ។ លុះដល់បឹងមួយមានទឹកតាស្រាយឱ្យក្រពើទៅនៅក្នុងបឹងនោះ។ ក្រពើជាសត្វមិនដឹងគុណ ក៏និយាយទៅតា «តាឯងចងយើងនឹងទូកររទេះ យើងមានសេចក្តីទុក្ខវេទនាណាស់ ដូចនេះតាឯងត្រូវឱ្យគោយើងមួយស៊ី ទើបតាឯងរួចទោសបើមិនឱ្យគោដល់យើងទេ យើងនឹងស៊ីតាឯងឥឡូវនេះ»។ តាកិតភ័យណាស់ទើបអង្វរ៖ «នែក្រពើ! អញខំធ្វើគុណនឹងឯង បែរជាឯងចង់ស៊ីសាច់អញទៅវិញ។ ដូចនេះអញមិនសុខចិត្តទេ អញនឹងទៅរកចៅក្រមឱ្យជួយ វិនិច្ឆ័យរឿងនេះសិន»។ ក្រពើតប៖ «អើតាឯងទៅរកចៅក្រមណា ក៏ទៅឱ្យឆាប់ចុះ យើងនឹងចាំឯងនៅទីនេះ»។ តាដើរចេញទៅក៏ជួបនឹងទន្សាយ។ ទន្សាយសួរ៖ «អើតា! ទៅណាមកណាមានទឹកមុខសោកសៅម្ល៉េះ តាមានការអីដែរ»។ តាក៏និយាយរឿងខ្លួនគាត់និងក្រពើប្រាប់ទន្សាយ។ ទន្សាយបានស្តាប់ក៏ពោល៖ «អើសត្វក្រពើនោះជាសត្វមិលគុណតា បើដូចនេះខ្ញុំទទួលធ្វើជាចៅក្រមជម្រះក្តីឱ្យ តាកុំភ័យ»។ តាក៏នាំទន្សាយទៅកន្លែងកើតហេតុ។ ដល់ហើយទន្សាយនិយាយនឹងក្រពើ៖ «ម៉េចចៅក្រពើក្រែងចៅឯង ដោយសារមកជាមួយតា ឥឡូវបានដល់ទីសមគួរនឹងអាស្រ័យនៅហើយម្តេចចៅគិតវេរឃ្នើសគុណដល់គាត់ទៅវិញ?»។ ក្រពើឆ្លើយ៖ «អើបងសុភា គាត់ឱ្យខ្ញុំដោយសារមកមែន ប៉ុន្តែគាត់ចងខ្ញុំខ្លាំងពេករកតែរើខ្លួនដកដង្ហើមមិនបាន ហេតុនេះបានជាខ្ញុំខឹងទើបឱ្យគាត់ប្រគល់គោមួយមកឱ្យខ្ញុំស៊ីវិញ»។ ទន្សាយសួរតា៖ «មើល៍តា! តាឯងម៉េចក៏ចងគេខ្លាំងម្ល៉េះ?»។ តាឆ្លើយ៖ «ទេ ខ្ញុំមិនបានចងតឹងទេ ចងល្មមតែជាប់កុំឱ្យតែធ្លាក់តែប៉ុណ្ណោះ»។ ទន្សាយថា៖ «អើខាងដើមចោទថាចងតឹងខ្លាំង ខាងចម្លើយថាចងល្មម បើដូចនេះត្រូវចៅក្រពើឯងលូនឡើងមកលើទូកររទេះវិញ ឱ្យតាគាត់ចងម្តងទៀត យើងនឹងមើលឱ្យដឹងថា តឹង ឬក៏ធូរទើបយើងកាត់សេចក្តីនេះឱ្យយុត្តិធម៌បាន»។ ក្រពើជាសត្វខ្លៅក៏វារឡើងលើទូកររទេះ តាក៏ចងដូចមុន។ ទន្សាយសួរ៖ម៉េចបងក្រពើតាគាត់ចងរឹតយ៉ាងនេះឬ?»។ ក្រពើឆ្លើយ៖ «ទេបើចងប៉ុននេះ ខ្ញុំទៅខឹងអី។ ទន្សាយប្រាប់តា៖ «ចូរតារឹតទ្វេឡើងថែមទៀតឱ្យគេសុខចិត្ត»។ តារឹតចំណងឡើងទៀត។ ទន្សាយសួរ៖ «ម៉េចម្តងនេះតឹងដូចកាលមុនហើយ ឬនៅ?»។ ក្រពើឆ្លើយ៖ «នៅពុំទាន់ស្មើមុនទេ»។ ទន្សាយបង្គាប់ឱ្យតាកាប់ឈើមកធ្វើជាកូនកំព្រាតបន្ថែមទៀត។ក្រពើតឹងខ្លួនស្ទើរដកដង្ហើមមិនបានក៏ប្រាប់៖ «បងសុភា កាលពីមុនគាត់ចងតឹងយ៉ាងនេះឯង។ សូមបងធ្វើសាក្សីផងចុះ តើអ្នកណាខុស អ្នកណាត្រូវ?»។ ទន្សាយឃើញដូចនេះក៏បង្គាប់តា៖ «តាចាំអ្វីទៀត ពូថៅធំក្នុងរទេះនោះមិនយកមកពុះក្បាលវាទៅទុកវាឱ្យរស់ធ្វើអ្វី ខ្មោចអាសត្វអកតញ្ញូពុំដឹងគុណគេធ្វើមកលើខ្លួន»។ តាចាស់ក៏ស្ទុះទៅយកពូថៅធំមកសំពងក្បាលក្រពើនោះ ក្រពើក៏មរណៈនាពេលនោះឯង។

មេរៀនទី4	**វេយ្យាករណ៍៖ គុណនាមកំណត់**
រយៈពេល	1ម៉

វត្ថុបំណង	កំណត់គុណនាមកំណត់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី27 ដល់ទី28
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. នេះ ខ. ខ្ញុំ គាត់ គ. នេះ ឃ. ម្នាក់ៗ ង. គ្មាន... ណាម្នាក់ ច. ឯង អ្វីខ្លះ **លំហាត់ទី2៖** ក. នីមួយៗ ខ. នេះ នោះ គ. គ្មាន ណា ឃ. យើង ង. គ្មាន ណា ច. ម្នាក់ៗ

មេរៀនទី5	**បំណិន ៖ សទិសសព្ទ (ពាក្យសូរដូច)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សទិសសព្ទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី29
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. កេរ្តិ៍ (ន) សេចក្តីសរសើរ ការល្បី ការលេចឮខ្ចរខ្ចាយ។ កេរ (ន) ដំណែលជាសម្បាច់របស់ដូនតា ឬមាតាបិតាជាដើម។ ខ. ពី (និ) អំពី ខាង ឯ។ ឧ. មកពីណា? សម្តីចេញពីមាត់ ពីក្រោម...។ ពីរ (បរិ) មួយគួបគ្នា គឺមួយនឹងមួយ(២)។ **លំហាត់ទី2៖** (១) ព្រៀប (២) ប្រៀប (៣) ព្រាប **លំហាត់ទី3៖** ប្រៀប (កិ) ធៀបប្រដូច ផ្ទឹមប្រដូចគ្នា ប្រដូចដោយធៀបគ្នា។ ឧ. ចាញ់ប្រៀបគេ។ ព្រៀប (គុ) ដែលពេញកំពុងរកកលហៀរ។ ឧ. ទឹកជនព្រៀបច្រាំង។ ព្រាប (ន) ឈ្មោះបក្សីមួយប្រភេទរូបរាងស្រដៀងនឹងលលកតែសម្បុរផ្សេងគ្នា។ ឧ. ព្រាបយំ។

មេរៀនទី6	**ការនិយាយ ៖ ការនិទានរឿងឡើងវិញ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ការនិទានរឿងឡើងវិញបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី30 ដល់ទី31
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. រវាងរឿងដែលបានអាននិងរឿងដែលអ្នកបាននិទានឡើងវិញមានភាពខុសគ្នាត្រង់៖ រឿងបានអានគឺ អានតាមសៀវភៅ ឯរឿងដែលនិទានឡើងវិញគឺការនិទានដោយសង្ខេបយកតែចំណុចសំខាន់។ 2. រឿងដែលនិទានឡើងវិញមិនបានរក្សាខ្លឹមសារដើមគ្រប់គ្រាន់ទេ ព្រោះអ្នកនិទានអាច

	ចាប់យកតែព្រឹត្តិការណ៍សំខាន់ៗមកនិទានហើយអាចកាត់ចោលផ្នែកដែលមិនចាំបាច់។ 3. មុនពេលនិយាយយើងអាចយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចជា៖ តួអង្គ កាលអាកាសរឿង ចំណុចសំខាន់ៗ ឬព្រឹត្តិការណ៍សំខាន់ៗ។
កំណែលំហាត់	**លំហាត់ទី1៖** និទានរឿងភ្នំប្រុសភ្នំស្រីឡើងវិញដោយផ្អែកលើ៖ ក. តួអង្គ៖ ពួកប្រុសៗ ពួកស្រីៗ ស្តេចស្រីអយុធ្យា ខ. កាលអាកាស៖ ○ ពេលវេលា - កាលពីព្រេងនាយ - ក្នុងរជ្ជកាលស្តេចស្រីអយុធ្យា - លុះមកដល់រាជ្យស្តេចក្រោយៗ - តាំងពីព្រលប់រហូតមកដល់ផ្តាយព្រឹករះ ○ ទីកន្លែង - ជ្រុងឥសានភ្នំ គ. ព្រឹត្តិការណ៍៖ - ក្នុងរជ្ជកាលស្តេចស្រីអយុធ្យាស្រីៗដណ្តឹងប្រុសធ្វើប្តី - លុះមកដល់រាជ្យស្តេចក្រោយៗស្រីៗមានគំនិតរើបម្រះពីប្រពៃណីស្រីដណ្តឹងប្រុស - ស្រីៗបបួលប្រុសៗភ្នាល់លើកដីពូនភ្នំ - ស្រីៗប្រើឧបាយកលបង្ហូតគោមនៅជ្រុង សានភ្នំបន្លំជាផ្តាយព្រឹករះ - ប្រុសៗចាញ់ក៏សុខចិត្តស្តីដណ្តឹងស្រីៗធ្វើជាភរិយារហូតដល់សព្វថ្ងៃ **លំហាត់ទី2៖**(ចម្លើយជាក់ស្តែង) និទានរឿងណាមួយឱ្យប្អូនរបស់អ្នកស្តាប់ដោយអនុវត្តតាមលំណែនាំខាងក្រោម៖ ក. តួអង្គ៖…… ខ. កាលអាកាស៖…… ○ ពេលវេលា…… ○ ទីកន្លែង…… គ. ព្រឹត្តិការណ៍៖…… …… ……

មេរៀនទី7	**សំណេរ ៖ ការតាក់តែងរឿងខ្លី**
រយៈពេល	2ម៉
វត្ថុបំណង	តែងរឿងខ្លីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី32
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23

កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) មុននឹងសរសេរអ្នកត្រូវកំណត់៖ 1. តួអង្គ៖…… 2. កាលអាកាសរឿង៖ o កាល:…… o អាកាស 3. ព្រឹត្តិការណ៍រឿង៖ - …… - ……

ជំពូកទី៣

កំណាព្យខ្មែរ

រយៈពេល	12ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ពាក្យចួន
មេរៀនទី2	អំណាន៖ មេសូត្រ៖ លម្អបីប្រការ
មេរៀនទី3	វេយ្យាករណ៍៖ គុណនាមកម្មសិទ្ធ
មេរៀនទី4	បំណិន៖ គំនិតសំខាន់របស់អត្ថបទ
មេរៀនទី5	អំណាន៖ កំណាព្យខ្មែរ
មេរៀនទី6	អំណាន៖ មេសូត្រ៖ ឆ្លុតបីប្រការ

មេរៀនទី1	**បំណិន៖ ពាក្យចួន**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពាក្យចួនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី34ដល់ទី35
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ចួនក្នុងវគ្គទី1៖ ឆោត ជួន ស្នោត , កោះ ជួន ចន្លោះ របោះ ចួនក្នុងវគ្គទី2៖ ចម្ការ ជួន រក្សា , ម្តង ជួន ផង ឆ្លង ចួនឆ្លងវគ្គ ៖ របង ជួន ម្តង ផង ឆ្លង។ **លំហាត់ទី2៖** (១) ពន់ (២)ធីតា (៣)សិក្សា (៤)លោក (៥)វាង (៦)ពុះពារ

មេរៀនទី2	**អំណាន៖ មេសូត្រ៖ លម្អបីប្រការ (បទពាក្យប្រាំពីរ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីលម្អបីប្រការរបស់មនុស្សគ្រប់រូបបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី36ដល់ទី37 រូបភាពទំព័រ36
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ20
ចម្លើយនៃសំណួរ	1. លម្អបីប្រការមាន៖ លម្អរូបរាង លម្អចរិយាសម្បត្តិ និងលម្អដោយចំណេះវិជ្ជា។ 2. ឫកពា ដែលគេចាត់ទុកថាជាឫកពាសមរម្យគឺឫកពាដែលចេះគោរព ចាស់ទុំ និង ចេះស្តាប់ហេតុផល។ 3. ឫកពា ដែលគេចាត់ទុកថាជាឫកពាច្រឡើសបើស គឺឫកពាដែល មិនចេះគោរពចាស់ទុំ

	និងមិនចេះស្តាប់ហេតុផល។ 4. បានជាអ្នកនិពន្ធប្រៀបធៀប **"ចរិយា"** ទៅនឹងគ្រឿងអលង្ការព្រោះ ចរិយាជាគ្រឿងលម្អមួយដ៏ប្រពៃសំរាប់មនុស្សយើង។ 5. ដើម្បីក្លាយជាមនុស្សថ្លៃថ្នូរក្នុងសង្គមយើងត្រូវ៖ - រៀបចំឫកពាអោយបានល្អ - ចេះគោរពអ្នកដ៏ទៃ - ចេះអត់អោន - យកចិត្តទុកដាក់លើការរៀនសូត្រ...។ 6. បើយើងជ្រើសរើសមិត្ត បុគ្គលនោះត្រូវមានលក្ខណៈដូចតទៅ៖ - ជាមនុស្សមានឫកពាល្អ ចេះគោរពអ្នកដទៃ ចេះអត់អោន ខំប្រឹងប្រែងរៀនសូត្រ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចរិយា (ន) ការប្រព្រឹត្តិ។ ខ. បវរ (គុ) ប្រសើរ លើសលែង ថ្លៃថ្លា។ គ. ប្រមាណ (ន) ការស្មង់ ការស្មាន។ ឃ. អលង្កា (ន) គ្រឿងលម្អប្រាណ។ **លំហាត់ទី2៖** ដុស (កិ) ខាត់ រំលីង ពួត ជម្រះដោយសាប៊ូ ។ ឧ. ដុសក្អែល ។ ដុះ (កិ) ចាប់កើត កកើត មានពន្លក។ ឧ. ពោតនេះដុះល្អណាស់។ សព្វ (គុ) ទាំងអស់ ទាំងមូល ទាំងពួង។ឧ. ចេះសព្វ ។ សព្វ (កិ) ពេញ គាប់ ស្មោះស្ម័គ្រ ឥតខុស ឥតទាស់។ ឧ. ទ្រង់សព្វព្រះរាជហឫទ័យ។ សប់ (កិ) ស្រូបដោយស្នប់ ទាញរុញដៃស្នប់រឿយៗអោយមានខ្យល់។ ឧ. សប់ទឹក សប់ស្នប់។ សព (ន) រូបបុគ្គលដែលស្លាប់ ។ ឧ. សាកសព។

មេរៀនទី3	**វេយ្យាករណ៍៖ គុណនាមកម្មសិទ្ធ**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់គុណនាមកម្មសិទ្ធបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី38 ដល់ទី39
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ខ. ប្អូនឯងរៀនដិះកង់ទៅសាលារៀន។ ឃ. ឆ្កែខ្ញុំចេះជាងឆ្កែគាត់។ ង. ម្តាយយើងជាមាតាដ៏ល្អ។ ច. លុយនាងនៅក្នុងកាបូប។ **លំហាត់ទី2៖** ក. នាង ខ. ខ្ញុំ គ. ខ្ញុំ ឯង ឃ. ខ្ញុំ ង. យើង

	លំហាត់ទី3៖ (ចម្លើយជាក់ស្តែង) - ជីតាខ្ញុំមានអាយុ៦០ឆ្នាំហើយ។ - បងឯង ស្លៀកខោពណ៌ខ្មៅ។ - ផ្ទះគាត់នៅឆ្ងាយ ជាងផ្ទះខ្ញុំ។ - ថ្នាក់រៀនយើងស្អាតណាស់។ - សៀវភៅរបស់វា នៅលើតុ។ - ឆ្កែគេ កាចជាងឆ្កែខ្ញុំ។

មេរៀនទី4	**បំណិន៖ គំនិតសំខាន់របស់អត្ថបទ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីគំនិតសំខាន់របស់អត្ថបទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី40
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់៖** សារៈសំខាន់នៃបឹងទន្លេសាប។

មេរៀនទី5	**អំណាន៖ កំណាព្យខ្មែរ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីឈ្មោះបុព្វកវីនិងប្រភេទកំណាព្យបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី41 ដល់ទី42 រូបភាពទំព័រ41
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. បុព្វកវីខ្មែរមានឈ្មោះ៖ បណ្ឌិតជ័យនន្ទ សុតន្តប្រិយជាឥន្ទ្រ ក្រមង៉ុយ កិក្ខុសោម សន្ធរម៉ុក ព្រះរាជសម្ភារនូកន។ 2. កំណាព្យខ្មែរយើងមានបទ៖ បទកាកគតិ បទព្រហ្មគីតិ បទពំនោល បទភុជង្គលីលា បទពាក្យប្រាំពីរ បទពាក្យប្រាំបី បទពាក្យប្រាំបួន បទទ្វេមាត្រជាដើម។ 3. រឿងដែលតាក់តែងជាកំណាព្យមាន៖ រឿងរាមកេរ្តិ៍ ទុំទាវ និងល្បើករឿងផ្សេងៗ មានច្បាប់ល្បើកថ្មី ល្បើកអក ល្បើកជុចនិងត្រី... ។ 4. ចំពោះកំណាព្យខ្មែរ ខ្ញុំមានចំណាប់អារម្មណ៍ថាកំណាព្យខ្មែរសុទ្ធតែពីរោះរណ្តំណែងណងប្លែកៗគ្នាគួរឱ្យចូលចិត្ត។ 5. អប់រំឱ្យយើងត្រូវយកចិត្តទុកដាក់រៀនសូត្រកំណាព្យខ្មែរឱ្យចេះចាំគ្រប់ៗគ្នានិងត្រូវចេះ លើកតម្កើងនិងថែរក្សាកេរមរតកនេះឱ្យបានគង់វង្ស។
កំណែលំហាត់	**លំហាត់ទី1៖** ក. កំណាព្យ (ន) ពាក្យកាព្យ។ ខ. សក្តីភាព (ន) ដំណើរជាសាក្សី។ គ. កេរមរតក (ន) ដំណែល សម្បត្តិបន្សល់ទុកពីដូនតា។

	ឃ. គង់វង្ស (គុ) គង់ពូជវង្សនៅមិនសូន្យ។ **លំហាត់ទី2៖** គ. ខ្មែរយើងមានបុព្វកវីល្បីល្បាញ និងមរតកកំណាព្យបទផ្សេងៗ ជាច្រើន **លំហាត់ទី3៖** បទ (ន) លំនាំនៃសំឡេងដែលសូត្រឬច្រៀង។ ឧ.បទចម្រៀង។ បត់ (កិ) ត្រឡប់តាមទំនង តាមផ្លូវដដែលមកវិញ។ ឧ. បត់សំពត់។ បត់ (គុ) ដែលបត់ពង់ពេន។ ឧ. ផ្លូវបត់បែន។ ចិត (កិ) កាត់ជាចំណិត។ ឧ. ចិតបន្លែ។ ចិត្ត (ន) ធម្មជាតិសម្រាប់បន្សំអារម្មណ៍ សម្រាប់គិតគឺវិញ្ញាណ។ ឧ. ចិត្តល្អ ចិត្តអាក្រក់។

មេរៀនទី6	**អំណាន៖ មេសូត្រ៖ ឆ្គតបីប្រការ (បទកាកគតិ)**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីអំពើឆ្គតបីប្រការរបស់មនុស្សបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី43 ដល់ទី44 រូបភាពទំព័រ43
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ20
ចម្លើយនៃសំណួរ	1. កំណាព្យនេះជាបទកាកគតិ។ មាន៣ វគ្គ។ មួយវគ្គមាន៧ឃ្លា។ មួយឃ្លាមាន៤ព្យាង្គ។ 2. គេចាត់ទុកអំពើឆ្គត៣យ៉ាងគឺ ឆ្គតនឹងស្រា ឆ្គតនឹងស្រី ឆ្គតនឹងល្បែង។ 3. អំពើឆ្គតទាំងនោះធ្វើឱ្យយើងភ្លេចភ្លាំងស្មារតី ភ្លេចក្តីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្ត្រសួស្តី ភ្លេចសីលទាន ភ្លេចញាណវុឌ្ឍី ភ្លេចច្បាប់ប្រក្រតី ។ 4. អំពើឆ្គតទាំងនេះផ្តល់ផលវិបាកដូចតទៅ៖ - ខាតបង់ពេលវេលា ទ្រព្យសម្បត្តិ ធ្វើអោយគ្រួសារនិងសង្គមស្អប់ខ្ពើម 5. ខ្ញុំមិនពេញចិត្តនឹងអំពើឆ្គតទាំងនេះទេ ព្រោះធ្វើអោយយើងខាតបង់ ពេលវេលា និងធ្វើឱ្យគ្រួសារនិងសង្គមស្អប់ខ្ពើម។
កំណែលំហាត់	**លំហាត់ទី1៖** ក. សេព (កិ) ប្រើប្រាស់ បរិភោគ ផឹក រួមបវេណី។ ខ. រៀរ (កិ) លើកលែង តម ឈប់រំខាន។ គ. គាប់ (គុ) ត្រូវ ឥតទាស់ ឥតខុស។ ឃ. សួស្តី (ន) សេចក្តីសុខស្រួល សេចក្តីចម្រើន។ **លំហាត់ទី2៖** គ. ត្រូវរៀរចាកអំពើឆ្គតទាំងបីមាន ស្រី ស្រា និងល្បែងស៊ីសង។ **លំហាត់ទី3៖** នឹង (ន) ប្រាកដជា គង់ គង់តែ។ ឧ. ស្អែកនឹងទៅផ្ទះអ្នក។ នឹង (គុ) ស្ងៀមមិនកម្រើក។ ឧ. អង្គុយនឹងថ្កល់។ នឹង (ធ) ដោយ ជាមួយ ដោយសារ។ ឧ. ជួសសម្លនឹងវែក។ និង (និ) សម្រាប់និយាយតពាក្យ រឺល្បះពីមួយទៅមួយ។ ឧ. គោនិងក្របី។

ហ្នឹង (វិ.ស) នុះ ។ ឧ. ហ្នឹងហើយ នុះហើយ។
វារ (កិ) លូនដោយប្រវា។ ឧ. ក្មេងតូចទើបចេះវារ។
វា (បុ.ស) គេ ; ពាក្យសម្រាប់និយាយជំនួសឈ្មោះមនុស្សក្មេងជាង ឬមនុស្សថ្នាក់
តូចទាបជាង ឬសត្វ ; វត្ថុ ; ធម្មជាតិ ...ផ្សេងៗ។ ឧ. កូនខ្ញុំវាឈឺ ;
កូនគោវាយំរកមេវា ; ការ៉ុងវាតូចច្រកអង្គរមិនអស់។
វៀរ (កិ) លើកលែង ; តម ; ឈប់ខាន ; អត់មិនធ្វើ។ ឧ. វៀរចាកទុច្ចរិត

លំហាត់ទី4៖

ត្រូវវៀរចាកអំពើឆ្គតទាំងបីមាន ស្រី ស្រា និងល្បែងស៊ីសង។

ជំពូកទី៤

ប្រយោជន៍នៃសារព័ត៌មាន

រយៈពេល	10ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល
មេរៀនទី2	ស្តាប់៖ បទសម្ភាស
មេរៀនទី3	អំណាន៖ បំណងរបស់ខ្ញុំ
មេរៀនទី4	និយាយ៖ ការសម្ភាស
មេរៀនទី5	សំណេរ៖ ការសរសេរអត្ថបទសារព័ត៌មាន

មេរៀនទី1	**អំណាន៖ ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល**
រយៈពេល	2ម៉
វត្ថុបំណង	ពណ៌នាពីពិធីបុណ្យច្រត់ព្រះនង្គ័លបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី46 ដល់ទី47 រូបភាពច្រត់ព្រះនង្គ័ល
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លឆ្នាំ២០១២ ធ្វើនៅទីលានព្រះស្រែ វាលព្រះមេរុ ក្បែរព្រះបរមរាជវាំង ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចអគ្គមហាពញាចក្រីកិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិនរួមទាំងព្រះរាជវង្សានុវង្ស ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។ 2. ព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំនេះ បានប្រព្រឹត្តទៅតាមកម្មវិធីនិងតាមប្រពៃណីដូចបណ្តាឆ្នាំមុនៗដែរ ប៉ុន្តែសម្រាប់ឆ្នាំនេះ គឺព្រះអង្គម្ចាស់ នរោត្តម ចក្រាវុឌ្ឍ ជាស្តេចមាយ និងអ្នកអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ ចាន់ស៊ីតាជាព្រះមេហួ។ ព្រះរាជពិធីនេះ បានប្រព្រឹត្តទៅចំនួនបីជុំនៃវាលព្រះស្រែ។ បន្ទាប់មក មានការផ្សងប្រផ្នូលដោយគោ១នឹម ត្រូវបានគេលែងឱ្យបរិភោគអាហារចំនួន៧មុខ។ 3. គេរៀបចំអាហារ សម្រាប់គោឧសភរាជផ្សងប្រផ្នូលមានដូចជា ស្រូវ ពោត សណ្តែក ល្ង ស្មៅ ទឹក និងស្រា។ 4. ជាលទ្ធផលនៃកិច្ចផ្សងប្រផ្នូលតាមបវេណី បានបញ្ជាក់ថា គោឧសភរាជបានបរិភោគពោតច្រើនជាងគេ ដែលជាប្រផ្នូលទាយថាឆ្នាំនេះ ពោតទទួលបានផលល្អប្រសើរ។ បន្ទាប់មកគឺសណ្តែក ដែលប្រផ្នូលទាយថា ដំណាំសណ្តែកឆ្នាំនេះក៏ទទួលផលបានល្អផងដែរ។

	ចុងក្រោយ គោឧសភរាជបានបរិភោគស្មៅបន្តិចបន្តួច ដែលតាមប្រផ្នូលទាយថា ឆ្នាំនេះ សត្វពាហនៈ សំខាន់ គោ ក្របី ដែលជាកម្លាំងអូសទាញប្រឈមនឹងជំងឺបន្តិចបន្តួច ប៉ុន្តែអ្វីជាការកត់សម្គាល់នោះគឺ គោឧសភរាជមិនបានបរិភោគស្រូវនោះទេ។ 5. អត្ថបទនេះនិយាយពីព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល។
កំណែលំហាត់	**លំហាត់ទី1៖** ក. គោឧសភរាជ (ន) ស្តេចគោ។ ខ. ផ្សង (កិ) សម្បូងសង្រ្គែង សុំអោយបានសម្រេចដូចបំណង។ គ. ប្រផ្នូល (ន) ហេតុភេទដោយដឹងដោយបូល ឬផ្សង។ ឃ. បវេណី (ន) ទំនៀម ប្រពៃណី។ ង. វប្បមង្គល (ន) មង្គលសាបព្រោះ។ **លំហាត់ទី2៖** ក. រៀងរាល់ឆ្នាំ ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លបានប្រារព្ធនៅវាលព្រះស្រែ។ ខ. នៅពេលបញ្ចប់ពិធីភ្ជួរព្រះស្រែ មានពិធីផ្សងប្រផ្នូល។ គ. អាហារផ្សងសម្រាប់គោឧសភរាជមានប្រាំពីរមុខមុខគឺ ស្រូវ ពោត សណ្តែក ល្ង ស្មៅ ទឹក និងស្រា។ ឃ. ព្រះរាជពិធីនេះ ប្រារព្ធនៅដូវវស្សា។ **លំហាត់ទី3៖** ក. ផ្សងប្រផ្នូលតាមរយៈគោឧសភរាជពីការបង្កបង្កើនផល ខ. ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ជារាជបវេណីម្យ៉ាងរបស់ព្រះមហាក្សត្រ

មេរៀនទី2	**ការស្តាប់៖ បទសម្ភាស**
រយៈពេល	2ម៉ោ
វត្ថុបំណង	សម្ភាសនរណាម្នាក់ពីគ្រោះថ្នាក់ធ្ងីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី49ដល់ទី50 រូបភាពទំព័រ49
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. អ្នកកាសែតសម្ភាសមីងចន្ថា 2. បានជាអ្នកកាសែតសម្ភាសគាត់ឋ ព្រោះគាត់និងកូនប្រុសគាត់រង គ្រោះថ្នាក់ចរាចរណ៍។ 3. អ្នកកាសែតសួរអ្នកមីងអំពី មូលហេតុនៃគ្រោះថ្នាក់ ពីរបួស និងពីហេតុការណ៍នៃគ្រោះថ្នាក់។ 4. អ្នកកាសែតជម្រាបសួរ មុននឹងសួរព័ត៌មាន។ 5. នៅពេលបញ្ចប់កិច្ចសម្ភាស អ្នកកាសែតថ្លែងអំណរគុណ។
កំណែលំហាត់	**លំហាត់ទី1៖** ក. - ប្រើសំណួរឱ្យបានច្បាស់ - ប្រើពាក្យគួរសមដូចជា សួស្តី ជម្រាបសួរ ជម្រាបលា អរគុណ...

	- ប្រើទឹកមុខនិងកាយវិការទន់ភ្លន់ ខ. - ឆ្លើយសំណួរឱ្យបានចំៗច្បាស់ៗ - បង្ហាញភាពរាក់ទាក់ក្នុងការផ្តល់ព័ត៌មាន - ប្រើពាក្យគួរសមដូចជា មិនអីទេ ខ្ញុំរីករាយណាស់ ... **លំហាត់ទី2៖** បទសម្ភាស សុកត្រា : ខ្ញុំចង់សួរ លោកតាអំពីប្រវត្តិលោកតាក្រមង៉ុយ។ តើលោកតាក្រមង៉ុយកើតនៅឆ្នាំណានិងមានស្រុកកំណើតនៅខេត្តណា? សុកត្រា : តើលោកតាក្រមង៉ុយមានស្នាដៃអ្វីខ្លះ? សុកត្រា : បាទអរគុណលោកតា ។ ក្រៅពីនេះតើលោកតាក្រមង៉ុយ មានស្នាដៃអ្វីផ្សេងទៀតទេលោកតា?

មេរៀនទី3	**អំណាន៖ បំណងរបស់ខ្ញុំ**
រយៈពេល	2ម៉ោ
វត្ថុបំណង	កំណត់គោលបំណងទៅអនាគតបានត្រឹមត្រូវ។
សម្ភារៈបង្ហាត់	ស.ស. ទំព័រទី51 ដល់ទី52 រូបភាពទំព័រ51
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. មនុស្សម្នាក់ៗមានបំណងប្រាថ្នាផ្សេងៗគ្នា ព្រោះមនុស្សម្នាក់ៗមានចិត្តនិងអត្តចរិកផ្សេងៗគ្នា។ 2. កុមារក្នុងអត្ថបទ មានបំណងប្រាថ្នាចង់ក្លាយជាអ្នកសរសេរសារព័ត៌មានមួយរូបដ៏ល្បី។ 3. អ្នកសារព័ត៌មានត្រូវត្រាច់ចរគ្រប់ច្រកល្ហក ធ្វើដំណើរគ្រប់តំបន់ ទោះបីជួបការលំបាក ឬប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ។ 4. (ចម្លើយជាក់ស្តែង) 5. ដើម្បីឱ្យគោលបំណងបានសម្រេចដោគជ័យត្រូវខិតខំព្យាយាមសិក្សារៀនសូត្រ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ពាណិជ្ជករ (ន) អ្នកលក់ដូរ អ្នកជំនួញ ឈ្មួញ។ ខ. កសិដ្ឋាន (ន) កន្លែងចិញ្ចឹមសត្វ។ គ. បំភ្លៃ (កិ) បញ្ចូលថែម។ ឃ. សន្និសីទ (ន) ប្រជុំគ្នាដដែកពិភាក្សាអំពីបញ្ហាផ្សេងៗ។ ង. ក្រមសីលធម៌ (ន) ច្បាប់វិនិយ។ ច. ព័ត៌មាន (ន) ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន។ **លំហាត់ទី2៖** ខ. ពុះពារចូល

<table>
<tr><td>មេរៀនទី4</td><td>និយាយ៖ ការសម្ភាស</td></tr>
<tr><td>រយៈពេល</td><td>2ម៉ោ</td></tr>
<tr><td>វត្ថុបំណង</td><td>សម្ភាសពីកិច្ចការងារអ្វីមួយបានត្រឹមត្រូវ។</td></tr>
<tr><td>សម្ភារឧបទេស</td><td>ស.ស. ទំព័រទី53 ដល់ទី54</td></tr>
<tr><td>ដំណើរការបង្រៀន</td><td>មើលលំនាំនៃការបង្រៀនទំព័រ22</td></tr>
<tr><td>ចម្លើយនៃសំណួរ</td><td>1. អង្គការអាជ្រាអប់រំពីការប៉ះពាល់នៃថ្នាំជក់ ដល់យុទ្ធជននៅខេត្តព្រះវិហារ។
2. មានបំណងបង្ហាញពីផលប៉ះពាល់នៃថ្នាំជក់។
3. គឺដើម្បីឱ្យយុទ្ធជនដែល ជាអ្នកការពារទឹកដីចេះថែរក្សាសុខភាពឱ្យរឹងមាំដោយមិនជក់បារី។</td></tr>
<tr><td>កំណែលំហាត់</td><td>លំហាត់ទី1៖
<table>
<tr><td>ប្រធានបទនៃការសម្ភាស</td><td>អង្គការអាជ្រាអប់រំការប៉ះពាល់នៃថ្នាំជក់ដល់យុទ្ធជន</td></tr>
<tr><td>គោលបំណងនៃការសម្ភាស</td><td>ផលប៉ះពាល់នៃថ្នាំជក់</td></tr>
<tr><td>ទីកន្លែងសម្ភាស</td><td>ខេត្តព្រះវិហារ</td></tr>
<tr><td>អ្នកសម្ភាស</td><td>អ្នកកាសែត</td></tr>
<tr><td>អ្នកទទួលការសម្ភាស</td><td>តំណាងអង្គការ</td></tr>
</table>
លំហាត់ទី2៖
ក. អ្នកសម្ភាសត្រូវ
- សួរសំណួរងាយៗ
- ប្រើពាក្យគួរសមនិងឥរិយាបថសមរម្យ
- ណែនាំខ្លួននិងប្រាប់ពីគោលបំណងនៃការសម្ភាស
- ថ្លែងអំណរគុណចំពោះអ្នកដែលផ្តល់ឱ្យខ្លួនបានសម្ភាស
ខ. អ្នកដែលត្រូវគេសម្ភាស
- ឆ្លើយឱ្យចំសំណួរ
- មានឥរិយាបថសមរម្យ
លំហាត់ទី3៖ (ចម្លើយជាក់ស្តែង)</td></tr>
</table>

<table>
<tr><td>មេរៀនទី5</td><td>សំណេរ៖ ការសរសេរអត្ថបទសារព័ត៌មាន</td></tr>
<tr><td>រយៈពេល</td><td>2ម៉ោ</td></tr>
<tr><td>វត្ថុបំណង</td><td>សរសេរអត្ថបទសារពត៌មានបានត្រឹមត្រូវ។</td></tr>
<tr><td>សម្ភារឧបទេស</td><td>ស.ស. ទំព័រទី55 ដល់ទី56</td></tr>
<tr><td>ដំណើរការបង្រៀន</td><td>មើលលំនាំនៃការបង្រៀនទំព័រ23</td></tr>
<tr><td>កំណែលំហាត់</td><td>លំហាត់៖(ចម្លើយជាក់ស្តែង)</td></tr>
</table>

ជំពូកទី៥

ស្មារតីទទួលខុសត្រូវ

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ការសង្ខេបព័ត៌មាន
មេរៀនទី2	អំណាន៖ រឿង ជីតាថាដូ
មេរៀនទី3	ស្តាប់៖ ភ្លៀងធ្លាក់និងខ្យល់ព្យុះនៅខេត្តកំពង់ស្ពឺ
មេរៀនទី4	វេយ្យាករណ៍៖ សព្វនាមបុរិស:
មេរៀនទី5	បំណិន៖ ព្រឹត្តិការណ៍ពិតនិងព្រឹត្តិការណ៍ប្រឌិត
មេរៀនទី6	អំណាន៖ សេចក្តីជូនដំណឹងអំពី " បាតុភូតអាកាសធាតុ "
មេរៀនទី7	សំណេរ៖ សេចក្តីជូនដំណឹង

មេរៀនទី1	**បំណិន៖ ការសង្ខេបព័ត៌មាន**
រយៈពេល	2ម៉
វត្ថុបំណង	សង្ខេបព័ត៌មានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី58 ដល់ទី61
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) **អត្ថបទទី1៖** ជំងឺម្យ៉ាងរាតត្បាតនៅខេត្តតាកែវ ខេត្តតាកែវ៖ ករណីផ្ទុះជំងឺរាតត្បាតម្យ៉ាងនៅស្រុកទ្រាំង ខេត្តតាកែវ ដែលគេនៅមិនទាន់ដឹងថា ជាប្រភេទជំងឺអ្វីនៅឡើយនោះ មានអ្នកភូមិជាច្រើនទៀតបានធ្លាក់ខ្លួនឈឺដូចៗគ្នា។ ក្រុមគ្រូពេទ្យផ្នែកកម្មវិធីឆ្លងនិងមន្ទីរសុខាភិបាលខេត្តតាកែវបានត្រួតពិនិត្យនិងធ្វើតេស្តឈាមអ្នកភូមិកំពុងមានជំងឺ ដើម្បីវិភាគរកប្រភេទមេរោគ ដែលបង្កឱ្យអ្នកភូមិឈឺបន្តបន្ទាប់គ្នានេះ។ ក្រុមគ្រូពេទ្យបានសន្និដ្ឋានជាដំហានដំបូងថា អាចមកពីមេរោគម្យ៉ាង ឈ្មោះ ឈីគុនហ្គុនយ៉ា ដែលឆ្លងតាមមូសខាំ។ ក្រុមគ្រូពេទ្យចម្រុះមកពីមន្ទីរសុខាភិបាលនិងអាជ្ញាធរមូលដ្ឋានបានចុះដល់ផ្ទះប្រជាពលរដ្ឋដែលកំពុងមានជំងឺចម្លែកនោះ។ តាមការសង្កេតផ្ទាល់ឃើញថា ពលរដ្ឋមានអាការៈក្តៅខ្លួន កន្ទួលនៅលើស្បែក និងឈឺតាមសន្លាក់ឆ្អឹងជា ដើម។ តាមការប៉ាន់ស្មានជាបឋមថា អាចជាជំងឺឈ្មោះ ឈីគុនហ្គុនយ៉ា ដែលបណ្តាលមកពីមូសខាំជំងឺនេះ គឺប្រហាក់ប្រហែលនឹងជំងឺគ្រុនឈាមដែរ។ **អត្ថបទទី2៖** ការផ្សព្វផ្សាយពីភូមិ ឃុំ មានសុវត្ថិភាពនិងច្បាប់ចរាចរណ៍ផ្លូវគោក ខេត្តបន្ទាយមានជ័យ៖ នៅវិទ្យាល័យសុខ អាន ប៉ោយចារ ស្ថិតក្នុងឃុំប៉ោយចារ ស្រុក

	ភ្នំស្រុក កាលពីព្រឹកថ្ងៃទី៧ ឧសភា ឆ្នាំ២០១២ កន្លងទៅនេះ កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកភ្នំស្រុក បានធ្វើការប្រជុំផ្សព្វផ្សាយពីការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងច្បាប់ចរាចរណ៍ផ្លូវគោក ដោយមានការចូលរួមពីលោកគ្រូ-អ្នកគ្រូនិងសិស្សានុសិស្សចំនួន៧៤៥នាក់។ ក្នុងខ្លឹមសារនៃកិច្ចប្រជុំនេះ សមត្ថកិច្ចបានផ្សព្វ ផ្សាយពីលក្ខណៈសម្បត្តិ៥យ៉ាង របស់ភូមិ-ឃុំ មានសុវត្ថិភាពឱ្យពួកគាត់ចូលរួមសហការជាមួយសមត្ថកិច្ចនិងផ្តល់ព័ត៌មានរាល់បទល្មើសដែលគាត់បានជួបនិងបានដឹងមកសមត្ថកិច្ច។ ជាមួយគ្នានេះដែរ ក៏មានការផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ ដោយណែនាំ សិស្សានុសិស្សទាំងអស់ ពេលបើកបរម៉ូតូត្រូវតែពាក់មួកសុវត្ថិភាព និងត្រូវមានកញ្ចក់មើលក្រោយ។ ទន្ទឹមនោះ ពេលធ្វើដំណើរឆ្លងកាត់ថ្នល់ត្រូវមានការប្រុងប្រយ័ត្ន ព្រោះអាចបង្កឱ្យមានគ្រោះថ្នាក់ខ្លួនឯង ឬអ្នកដទៃ។

មេរៀនទី2	**អំណាន៖ រឿង ជីតាថាដូ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីភាពឈ្លាសវៃរបស់ជីតាថាដូបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី62 ដល់ទី63
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ជីតាថាដូប្រើថាដូឱ្យយកភ្លើងមកដុតវាលស្រែ ដើម្បីអោយអ្នកភូមិនាំគ្នារត់មកមើល។ 2. ថាដូមិនពេញចិត្តនឹងកិច្ចការនេះទេ ព្រោះវាមិនពេញចិត្តនិងការដុតស្រូវ។ 3. ការសម្រេចចិត្តរបស់លោកតាត្រឹមត្រូវ ព្រោះដើម្បីអោយអ្នកភូមិរួចផុតពីគ្រោះថ្នាក់។ 4. រឿងនេះផ្តល់គំនិតអប់រំឱ្យយើងចេះជួយគ្នាក្នុងគ្រាអាសន្ន។
កំណែលំហាត់	**លំហាត់ទី1៖** - សមុទ្រ សាគរ ជលសា - ភ្លើង ព្រះអគ្គី - ភ្នំ គិរី បព្វតា បរពត **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) សង្ខេបរឿង "ជីតាថាដូ" ថាដូនិងជីតារស់នៅលើចង្កេះភ្នំមួយនៃប្រទេសជប៉ុន។ នៅជុំវិញផ្ទះតាមល្បាក់ភ្នំមាន ស្រែរបស់អ្នកស្រុកជាច្រើន។ ដំបូងគេ ឃើញជីតាថាដូឈរ សម្លឹងទៅសមុទ្រ ហើយស្រាប់តែមានទឹកមុខស្លេកស្លាំង។ ភ្លាមនោះ គាត់ស្រែកយ៉ាងភ្លាត់សំឡេងទៅកាន់ថាដូ៖ "ចៅឯង រត់ឱ្យលឿនទៅយកមែកឈើ ដែលកំពុងឆេះនោះឱ្យតា! ឆាប់ឡើង!"។ វាយំនិងសួរបញ្ជាក់៖ "លោកតា!លោកតា កំពុងដុតស្រូវហើយណា!"។ ជីតាគ្រាន់តែងក់ក្បាលតែគាត់មិនចាប់អារម្មណ៍នឹងសម្តីថាដូឡើយ។ គ្រានោះ វាលស្រែដែលមានស្រូវពណ៌ក្រហមដូចកម្រាលព្រំប្រែជា មានពណ៌ខ្មៅគ្របដណ្តប់ដោយផ្សែងខ្មៅខ្ពុលខ្មាញ់ អណ្តែតទៅលើអាកាស។ ទិដ្ឋភាពនេះ ធ្វើឱ្យអ្នកភូមិនាំគ្នារត់ឡើងលើភ្នំ ដើម្បីពន្លត់ភ្លើង។ បុរសម្នាក់បានសួរទាំងកំហឹងទៅកាន់លោកតារបស់ថាដូ៖ "ហេតុអ្វីបានជាមានរឿងនេះ កើតឡើង?

	ប្រាប់មក!"។ លោកតាបានឆ្លើយ៖ "ខ្ញុំជាអ្នកជុត"។ បុរសនោះសួរបន្ត៖ "ហេតុអ្វី? "។ អ្នកស្រុកមើល តាមដៃគាត់ឃើញរលកដ៏ធំសម្បើមមួយ កំពុងបោះពួយយ៉ាងលឿនស្ទើរសំដៅមករកភូមិអ្នកស្រុក។ ពួកគេឈរទ្រឹងគ្មានកម្រើក ឬនិយាយស្តីអ្វីឡើយ។ ទីបំផុតទើបពួកគេយល់ពីមូលហេតុដែលនាំឱ្យលោកតាសម្រេចចិត្តជុតស្រូវ។

មេរៀនទី3	**ការស្តាប់៖ ភ្លៀងធ្លាក់និងខ្យល់ព្យុះនៅខេត្តកំពង់ស្ពឺ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីគ្រោះធម្មជាតិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី64 រូបភាពទំព័រ64
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ខ្យល់ព្យុះនៅ ឃុំរលាំងគ្រើល ស្រុកសំរោងទង កាលពីវេលាម៉ោង២និង១១នាទីរសៀលថ្ងៃទី១៣ ឧសភា ឆ្នាំ២០១២។ 2. ភូមិដែលរងការខូចខាតមាន ភូមិអង្គមេត្រី ភូមិកំណប់ ភូមិក្រាំងស្វាយ ភូមិព្រៃសាលា និងភូមិចំបក់ផ្អែម។ 3. ខ្យល់ព្យុះនេះ បណ្តាលឱ្យខូចខាតលំនៅដ្ឋាន ដើមឈើ មនុស្ស និងសត្វ។ 4. មានគ្រោះថ្នាក់ដល់មនុស្សតែមិនបណ្តាលអោយមានអ្នកស្លាប់ទេ។ 5. ទាំងថ្នាក់ស្រុក ថ្នាក់ខេត្ត និងក្រុមកាកបាទក្រហមបានចុះសួរសុខទុក្ខ និងធ្វើកំណត់ហេតុនៃការខូចខាតដោយសារខ្យល់ព្យុះ។
កំណែលំហាត់	**លំហាត់៖** ព្រឹត្តិការណ៍ ខ្យល់ព្យុះ កាលបរិច្ឆេទ ថ្ងៃទី១៣ ឧសភា ឆ្នាំ២០១២ ពេលវេលា ម៉ោង២និង១១នាទី ទីកន្លែង ឃុំរលាំងគ្រើល ស្រុកសំរោងទង ផលប៉ះពាល់ ខូចខាត លំនៅដ្ឋាន ដើមឈើ មនុស្សនិងសត្វ។ អ្នកចុះពិនិត្យ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងក្រុមកាកបាទក្រហម

មេរៀនទី4	**វេយ្យាករណ៍៖ សព្វនាមបុរិស:**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សព្វនាមបុរិស:បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី65 ដល់ទី66 រូបភាពទំព័រ 65
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18

កំណែលំហាត់	**លំហាត់ទី1៖** យើង ពួកយើង ពួកគេ **លំហាត់ទី2៖** ក. ខ្ញុំ ខ. ពួកយើង គ. គាត់ យើង ឃ. គេ ង. ឯង ខ្ញុំ **លំហាត់ទី3៖**(ចម្លើយជាក់ស្តែង)

មេរៀនទី5	**បំណិន៖ ព្រឹត្តិការណ៍ពិតនិងព្រឹត្តិការណ៍ប្រឌិត**
រយៈពេល	2ម៉
វត្ថុបំណង	ញែកព្រឹត្តិការណ៍ពិត និងព្រឹត្តិការណ៍ប្រឌិតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី67 ដល់ទី68
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ព្រឹត្តិការណ៍ប្រឌិត **លំហាត់ទី2៖** ព្រឹត្តិការណ៍ពិត

មេរៀនទី6	**អំណាន៖ សេចក្តីជូនដំណឹងអំពី " បាតុភូតអាកាសធាតុ "**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ដំណឹងអំពីបាតុភូតអាកាសធាតុបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី69 ដល់ទី70
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ក្រសួងធនធានទឹកនិងឧតុនិយម អ្នកចេញសេចក្តីជូនដំណឹង។ គេប្រកាសពី បាតុភូតអាកាសធាតុ។ 2. ថ្ងៃទី ១៩ ២០ និង២១ ខែមករា ឆ្នាំ២០១០ សម្ពាធទាបមួយបាននឹងកំពុងស្ថិតនៅលើសមុទ្រចិនខាងត្បូង។ សម្ពាធនេះ កំពុងធ្វើដំណើរមកទិសខាងលិចក្នុងល្បឿន១៥ គីឡូម៉ែត្រក្នុងមួយម៉ោង។ ល្បឿនអតិបរមាក្បែរចំណុចកណ្តាលនៃវិសម្ពាធទាប នេះមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា បង្កឱ្យផ្ទៃមេឃ មានពពកច្រើន ខ្យល់បក់ប្រែប្រួលមានល្បឿនពី ១៨-២៥គីឡូម៉ែត្រ ក្នុងមួយម៉ោង។ 3. ខេត្តដែលរងឥទ្ធិពលអាកាសធាតុរតនគិរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី កំពង់ចាម ស្វាយរៀង និងព្រៃវែង។ 4. សេចក្តីជូនដំណឹងនេះ ធ្វើឡើងក្នុងគោលបំណងឱ្យប្រជាជនមានការការពារនិងប្រុងប្រយ័ត្ន។ 5. អ្នកដែលត្រូវអានសេចក្តីជូនដំណឹងនេះ គឺអាជ្ញាធរដែនដីនិងប្រជាពលរដ្ឋទាំងអស់ដែលរស់នៅតាមបណ្តាខេត្តមួយចំនួននិងអ្នកដំណើរតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស។ 6. សេចក្តីជូនដំណឹងនេះ មានចំណុចសំខាន់ៗដូចជា ផ្តល់ដំណឹងពីបាតុភូតអាកាសធាតុ កំណត់ ម៉ោង ថ្ងៃ ខែ ឆ្នាំដែលមានបាតុភូត។
កំណែលំហាត់	**លំហាត់ទី1៖** ក. បាតុភូត (ន) ហេតុដែលកើតមានឡើងពិតប្រាកដជាក់ស្តែង។

	ខ. អាកាសធាតុ (ន) លំហមេឃមាន ទឹក ដី ភ្លើង ខ្យល់ អាកាស។ គ. ឥទ្ធិពល (ន) កម្លាំងនៃឫទ្ធិ។ ឃ. យថាហេតុ (កិ) តាមរឿងដែលកើតមានឡើង។ ង. ឧតុនិយម (ន) ការព្យាករណ៍អាកាសធាតុ។ **លំហាត់ទី2៖** សេចក្តីជូនដំណឹងខាងលើនេះ ជាអត្ថបទពិត។ ព្រោះមានថ្ងៃខែឆ្នាំ និងទីកន្លែងជាក់លាក់គឺម៉ោង៦ព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១០ សម្ពាធទាបមួយបាននឹងកំពុងស្ថិតនៅលើសមុទ្រចិនខាងត្បូង។ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ប្រទេសកម្ពុជានឹងទទួលឥទ្ធិពលពីសម្ពាធទាប។ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ វិសម្ពាធបានថយឥទ្ធិពល។

មេរៀនទី7	**សំណេរ៖ សេចក្តីជូនដំណឹង**
រយៈពេល	2ម៉ោ
វត្ថុបំណង	សរសេរសេចក្តីជូនដំណឹងអ្វីមួយទៅនរណាម្នាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី71 ដល់ទី72
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)។

ជំពូកទី៦

អតីតកាលរបស់យើង

រយៈពេល	12ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ បំភ្លេចមិនបាន
មេរៀនទី2	ស្តាប់៖ ខ្ញុំសាកល្បង
មេរៀនទី3	វេយ្យាករណ៍៖ សញ្ញារះមុខ ៉ ៊៖ ៎
មេរៀនទី4	អំណាន៖ ប្រាសាទព្រះវិហារ
មេរៀនទី5	អំណាន៖ ស្រមោលអតីតកាល
មេរៀនទី6	សំណេរ៖ កំណត់ត្រាប្រចាំថ្ងៃ

មេរៀនទី1	**អំណាន៖ បំភ្លេចមិនបាន**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីហេតុការណ៍ដែលមិនអាចបំភ្លេចបានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី74 ដល់ទី76 រូបភាពទំព័រ74-75
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. សុជាតាសរសេរកំណត់ត្រាពីរលើក 2. កំណត់ត្រាទី១ សុជាតាបានទៅមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក 3. កំណត់ត្រាទី១ នាងចាប់អារម្មណ៍លើ៖ - ធ្នឹងលលាដ៍ក្បាលមនុស្សដ៏ច្រើន - រណ្តៅធំៗដែលគេកប់សពរួម - រូបថតនិងឈ្មោះអ្នកដែលត្រូវគេបានសម្លាប់នៅទីនោះ - ឧបករណ៍ដែលពួកខ្មែរក្រហមសម្រាប់ធ្វើទារុណកម្ម 4. កំណត់ត្រាទី២ នាងបានទៅកម្សាន្តនៅខេត្តមណ្ឌលគិរី។ 5. កំណត់ត្រាទី២ នាងចាប់អារម្មណ៍លើ៖ - ទេសភាពប្លែក ភ្នំតូចធំ វាលស្មៅស្រស់ស្អាត - ជនជាតិភាគតិច ពួកគេស្លៀកសម្លៀកបំពាក់ជនជាតិភាគតិចដោយស្តាយកាផានៅពីក្រោយខ្នង។ - កូនផ្ទះតូចមួយមានកម្ពស់ជិតដប់ម៉ែត្រ ទុកសម្រាប់កូនកម្លោះជនជាតិភាគតិចមុនពេលរៀបការ

	6. (ចម្លើយជាក់ស្តែង)
កំណែលំហាត់	**លំហាត់ទី1៖** ក. ទារុណកម្ម (ន) អំពើកាច ព្រៃផ្សៃ ឃោរឃៅ។ ខ. ពូជសាសន៍ (ន) ជាតិសាសន៍ ជាតិកំណើត។ គ. រន្ធត់ (កិ) ភ័យស្លុត។ ឃ. ប្រល័យ (ន ឬកិ) សេចក្តីវិនាស មរណៈ។ ង. ខ្សឹកខ្សួល (កិ) យំអណ្តឹតអណ្តក ឆែតឆតតិចៗ ដែលមានកិរិយារអាក់រអួល ក្រស្រាក។ **លំហាត់ទី2៖** ក. សម្រាកពីការសិក្សា ខ. គ្រឿងប្រើប្រាស់ គ. លំហើយចិត្ត ឃ. មើល **លំហាត់ទី3៖** ក. ឆ្នឹងលលាដ៍ក្បាលមនុស្សជាច្រើនត្រូវគេរៀបតម្កល់ទុកធ្វើសក្ការបូជា។ គ. រណ្តៅកប់សពរួមដែលមានទំហំធំៗជាច្រើន។ ឃ. ឧបករណ៍សម្រាប់ធ្វើទារុណកម្មនិងសម្លាប់មនុស្សដូចជា ដង្កាប់ ពូថៅ ញញួរ ចបកាប់។ ង. រូបថតនិងឈ្មោះអ្នកដែលត្រូវគេយកទៅសម្លាប់។

មេរៀនទី2	**ស្តាប់៖ ខ្ញុំសាកល្បង**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីកំណត់ត្រាសកម្មភាពអ្វីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី 77 ដល់ទី 78
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ក្នុងកំណត់ត្រាទី១ គេសាកល្បងឆ្លងថ្នល់ បន្ទាប់ពីចុះពីលើរថយន្តឈ្នួលជិតផ្សារពោធិ៍ចិនតុង។ 2. ក្នុងកំណត់ត្រាទី២ គេសាកល្បងឡើងនិងចុះជណ្តើរយន្ត បន្ទាប់ពីសង្កេតមើលគេឡើងចុះជណ្តើរយន្ត ផ្សារទំនើបសូរិយា។ 3. ការសាកល្បងទាំងពីរលើកបានសម្រេច។ 4. គេមានអារម្មណ៍សប្បាយរីករាយណាស់ ក្រោយពេលសាកល្បងបានសម្រេច។
កំណែលំហាត់	**លំហាត់ទី1៖** ក. ម្តាយ ខ. ឪពុកម្តាយ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី3	**វេយ្យាករណ៍៖ សញ្ញារះមុខ**

រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញារះមុខបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី79
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. នោះ ខ. ពោះ គ. ដិះ ចង្កឹះ ឃ. ផេះ ង. ឆ្កែះ ច. ចម្រុះ ឆ. ជះ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) ត្រចះ ខែរះ ជិះ ពិរោះ ចេះ រិះ វះ ចុះ ចម្រុះ ផ្លែម្រះ បំបះ អំណឹះ

មេរៀនទី4	**អំណាន៖ ប្រាសាទព្រះវិហារ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីការដាក់បញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ ទី80ដល់ទី81 រូបភាពប្រាសាទព្រះវិហារ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ប្រាសាទព្រះវិហារស្ថិតនៅក្នុងខេត្តព្រះវិហារ។ 2. ប្រទេសកម្ពុជាទាមទារប្រាសាទព្រះវិហារពីថៃមកវិញថ្ងៃ១៥ ខែមិថុនា ឆ្នាំ១៩៦២ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រខ្មែរ «ព្រះបាទ នរោត្តម សីហនុ»។ 3. មានមោទនភាពណាស់ដោយបានកើតជាខ្មែរ ដែលមានបុព្វបុរសដ៏ខ្លាំងពូកែនិងបានបន្សល់ទុកស្នាដៃល្អឯកដល់កូនខ្មែរជំនាន់ក្រោយដែលល្បីល្បាញពេញពិភពលោក។ 4. ប្រាសាទនេះស្ថិតនៅ ចម្ងាយ108km ពីទីរួមខេត្ត។ 5. ដើម្បីថែរក្សាសម្បត្តិបេតិកភណ្ឌពិភពលោកឱ្យស្ថិតស្ថេរចីរកាលត្រូវ៖ ថែរក្សានិងការពារកុំឱ្យខ្មាំងសត្រូវកាន់កាប់បាន។
កំណែលំហាត់	**លំហាត់ទី1៖** ក. សតវត្ស (ន) កាលកំណត់មួយរយឆ្នាំ ខ. លេចធ្លោ (កិ.វិ) ចេញពីទីកំបាំង លឿនទៅមុខ ឬទៅលើ ដូចគេលោខ្លួនទៅមុខដោយជាក់ច្បាស់។ គ. បេតិកភណ្ឌ (ន) ទ្រព្យសម្បត្តិ ឬកេរ្តិ៍មត៌កដែលមានជាប់មកពីខាងឪពុក។ ឃ. វិនិច្ឆ័យ (ន) ការពិចារណាដោយល្អិត, ការពិនិត្យមើលឱ្យឃើញពិតការជំនុំជម្រះសេចក្តី, កាត់សេចក្តី, ជម្រះក្តី។ **លំហាត់ទី2៖** ក. ប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក ខ. ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨

មេរៀនទី5	**អំណាន៖ ស្រមោលអតីតកាល**
រយៈពេល	2ម៉ោ

វត្ថុបំណង	រៀបរាប់ពីហេតុការណ៍នៅក្នុងសម័យប៉ុលពតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី82ដល់ទំព័រ83
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រឿងនេះកើតឡើងនៅសម័យប៉ុលពត។ 2. កងឈ្លបសម្លាប់មនុស្សអស់៣នាក់ដោយសារផ្លែក្រូចថ្លុង។ 3. ការសម្លាប់របស់ពួកគេមិនយុត្តិធម៌ទាល់តែសោះ ព្រោះជាការបំពានលើសិទ្ធមនុស្ស។ 4. បានជាអ្នកនិពន្ធរួចខ្លួនពីការសម្លាប់របស់កងឈ្លប ព្រោះអ្នកនិពន្ធបានរត់គេចយករួចខ្លួនមិនគិតអ្វីទាំងអស់។ 5. សម័យកាលនោះ ជាសម័យដ៏សាហាវឃោរឃៅគ្មាននរណាធ្វើដូច។ 6. អប់រំឱ្យចេះស្រឡាញ់គ្នា អត់ឱនឱ្យគ្នា រួបរួមគ្នាកសាងប្រទេស កុំកាប់សម្លាប់គ្នាដូចសម័យខ្មែរក្រហមទៀត។
កំណែលំហាត់	**លំហាត់ទី1៖** ក. អតីតកាល (ន) កាលដែលកន្លងទៅ, ដែលហួសទៅហើយ។ ខ. តម្ពក់ (ន) ប្រដាប់ដែលធ្វើដោយដែក ឬឈើ ឬស្សីជាដើម មានចុងរាងខ្វែរ ឬខុបសម្រាប់ថ្ពក់ទាញអ្វីៗ។ គ. កងឈ្លប (ន) ក្រុម ឬពួកលបមើលដោយសម្ងាត់ , លបស្តាប់ដោយសម្ងាត់។ **លំហាត់ទី2៖** ឃ. អំពើព្រៃផ្សៃអស្ចារ្យរបស់បនប៉ុលពត គ្មាននរណាធ្វើដូច **លំហាត់ទី3៖** 1. ឃ 2. ក 3. ខ 4. គ

មេរៀនទី6	**សំណេរ៖ កំណត់ត្រាប្រចាំថ្ងៃ**
រយៈពេល	2ម៉ោ
វត្ថុបំណង	សរសេរកំណត់ត្រាប្រចាំថ្ងៃបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី84
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** 1. ខ 2. ង 3. ក 4. គ 5. ឃ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

ជំពូកទី៧

ទូរគមនាគមន៍នៅកម្ពុជា

រយៈពេល	14ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ការផ្តល់មូលហេតុដើម្បីគាំទ្រមតិដកស្រង់ចេញពីសំបុត្រ
មេរៀនទី2	វេយ្យាករណ៍៖ កម្រិតគុណនាម
មេរៀនទី3	ស្តាប់៖ សំបុត្រផ្ញាល់ខ្លួន
មេរៀនទី4	វេយ្យាករណ៍៖ ឈ្នាប់ ឬចំណងឈ្នាប់
មេរៀនទី5	អំណាន៖ រឿង កំណើតទូរស័ព្ទ
មេរៀនទី6	សំណេរ៖ សំបុត្រសួរសុខទុក្ខ
មេរៀនទី7	សំណេរ៖ សំបុត្រសូមអភ័យទោស

មេរៀនទី1	**បំណិន៖ ការផ្តល់មូលហេតុដើម្បីគាំទ្រមតិដកស្រង់ចេញពីសំបុត្រ**
រយៈពេល	2ម៉
វត្ថុបំណង	ផ្តល់ហេតុដើម្បីគាំទ្រមតិដកស្រង់ចេញពីសំបុត្រឬអត្ថបទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ ទី86ដល់ ទី88
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ការរងគ្រោះនេះ ធ្វើឱ្យគេន:បាត់បង់ជម្រកនិងទ្រព្យសម្បត្តិ។ **លំហាត់ទី2៖** គឺការសិក្សារបស់ខ្ញុំទទួលបានលទ្ធផលល្អជារៀងរាល់ខែ។

មេរៀនទី2	**វេយ្យាករណ៍៖ កម្រិតគុណនាម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់កម្រិតគុណនាមបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី89 ដល់ទី90
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** កម្រិតស្មើ ៖ ប្រហែល ដូច ស្មើ កម្រិតមិនស្មើ ៖ ជាង លើស កម្រិតផ្តាច់ ៖ ជាងគេ ជាងគេបំផុត ដាច់គេ **លំហាត់ទី2៖** ក. ដាច់គេ ខ. ជាង គ. ដូច ឃ. ជាងគេបំផុត ង. លឿនជាង

	លំហាត់ទី3៖ (ចម្លើយជាក់ស្តែង) សុខមានប្រាក់ច្រើនស្មើនឹងខ្ញុំដែរ។ ចម្ការរបស់សិទ្ធិធំជាងចម្ការខ្ញុំ។ អំសំមានអាយុច្រើនជាងគេបំផុត។ សុខរៀនពូកែជាងបូរិន។ ផ្ទះប្អូនខ្ញុំស្អាតជាច់គេនៅម្តុំនេះ។

មេរៀនទី3	**ការស្តាប់៖ សំបុត្រផ្ញើលខ្លួន**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីខ្លឹមសារសំបុត្រផ្ញើលខ្លួនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី91
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. និយាយអំពីអំពើល្អរបស់មិត្តសម្លាញ់ម្នាក់ ហើយចាត់ទុកគាត់ជាប្អូនបង្កើតរបស់ខ្លួន។ 2. សរសេរនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ។ 3. ចាត់ទុកមិត្តសម្លាញ់ជាប្អូនបង្កើតរបស់ខ្លួន។ 4. ព្រោះមិត្តភក្តិនោះធ្លាប់បានរួមសុខរួមទុក្ខជាមួយគ្នា។
កំណែលំហាត់	**លំហាត់ទី1៖** ខ. ទីកន្លែង កាលបរិច្ឆេទ **លំហាត់ទី2៖** គ. ការជូនពរនិងចុះហត្ថលេខា

មេរៀនទី4	**វេយ្យាករណ៍៖ ឈ្នាប់ ឬចំណងឈ្នាប់**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើឈ្នាប់ចងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី92 ដល់ទី93
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** និង ប៉ុន្តែ ចំណែកឯ តែ **លំហាត់ទី2៖** ក. រឺឯ ខ. និង គ. ប៉ុន្តែ ឃ. និង ង. ឯ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) សុភាពរៀនពូកែ ប៉ុន្តែនាងខ្ជិលធ្វើការផ្ទះ។ ម៉ានិតចូលចិត្តរាំ រឺឯឪណាចូលចិត្តហាត់ប្រាណ។ ថ្ងៃអាទិត្យ ម៉ាណានិងណារ៉ាទៅផ្សារទំនើប។

មេរៀនទី5	**អំណាន៖ រឿង កំណើតទូរស័ព្ទ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាពីប្រវត្តិទូរស័ព្ទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី94ដល់ទី95
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. អ្នកវិទ្យាសាស្ត្រដែលល្បីជាងគេនៅឆ្នាំ១៨៧៦ គឺលោក អាឡិចសាន់ដឺ ក្រាហាំបែល សញ្ជាតិអង់គ្លេស។ 2. លោក អាឡិចសាន់ដឺ ក្រាហាំបែលបានយកទូរស័ព្ទមកតាំងពិព័រណ៍នៅហ្វីឡាដែលហ្វី 3. លោក អាឡិចសាន់ដឺ បានពន្យល់ពីផលប្រយោជន៍របស់ទូរស័ព្ទនេះអាចនាំសំឡេងមនុស្សតាមខ្សែអគ្គិសនី។ មនុស្សដែលឈរនៅចុងម្ខាង អាចស្តាប់ឮអ្នកដែលនៅខាងចុងម្ខាងទៀត និយាយដូចគេឈរនិយាយក្បែរគ្នាដែរ។ 4. លោក អាឡិចសាន់ដឺជាមនុស្សឆ្នើមដែលអាចកែប្រែរបៀបរស់នៅរបស់មនុស្សក្នុងសង្គមបាន។ 5. ទូរទស្សន៍ កុំព្យូទ័រ ម៉ាស៊ីនថត ទូរទឹកកក...។ 6. ប្រើទូរស័ព្ទដើម្បីទំនាក់ទំនងការងារផ្សេងៗ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ពិព័រណ៍ (ន) ការដាក់តាំង , ការបង្ហាញឱ្យឃើញនូវវត្ថុផ្សេងៗដើម្បីឃោសនាផ្សាយ។ ខ. វិទ្យាសាស្ត្រ (ន) គម្ពីរ ឬក្បួនប្រាប់វិជ្ជាផ្សេងៗ។ គ. គណៈកម្មការ (ន) ជនមួយក្រុម ឬក្រុមជំនុំដែលចាត់តាំងឡើងដោយពិធីបោះឆ្នោត ឬដោយការជ្រើសតាំងសម្រាប់ឱ្យពិនិត្យកិច្ចការណាមួយជាច់មុខដោយឡែក។ ឃ. អធិរាជ (ន) ព្រះរាជាធំចម្បងជាងព្រះរាជាទាំងឡាយក្នុងប្រទេសជិតខាង, មហារាជ។ ង. ឧបករណ៍ (ន) គ្រឿងប្រកបផ្សំគ្នា, គ្រឿងប្រើប្រាស់។ **លំហាត់ទី2៖** ព្រះឱង្ការ ព្រះបន្ទូល ពុទ្ធដីកា ប្រសាសន៍ និយាយ **លំហាត់ទី3៖** និង រីឯ

មេរៀនទី6	**សំណេរ៖ សំបុត្រសួរសុខទុក្ខ**
រយៈពេល	2ម៉ោ
វត្ថុបំណង	សរសេរសំបុត្រសួរសុខទុក្ខបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី96 ដល់ទី97
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	សរសេរសំបុត្រសួរសុខទុក្ខឪពុកម្តាយ .....ថ្ងៃទី.....ខែ.....ឆ្នាំ..... 1. ក្បាលសំបុត្រ

	- ជូនចំពោះលោកឪពុកនិងអ្នកម្តាយ 2. តួសំបុត្រ - ដំបូងរៀបរាប់អំពីសុខទុក្ខផ្ទាល់ខ្លួន - បន្ទាប់មកសួរសុខទុក្ខលោកទាំងពីរ និងរៀបរាប់ពីការខិតខំរៀនសូត្រនិងការធ្វើការងារផ្សេងៗទៀតរបស់យើង។ 3. ការបញ្ចប់សំបុត្រ - ជាទីបញ្ចប់ កូនសូមជូនពរលោកអ្នកមានគុណទាំងពីរ សូមឱ្យ…… ……។ ពីកូនសម្លាញ់ សោភា

មេរៀនទី7	**សំណេរ៖ សំបុត្រសូមអភ័យទោស**
រយៈពេល	2ម៉ោ
វត្ថុបំណង	សរសេរសំបុត្រសូមអភ័យទោសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី98 ដល់ទី99
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	សំបុត្រសុំអភ័យទោស ……ថ្ងៃទី……ខែ……ឆ្នាំ…… មកដល់…… សុំទោសរតនា! ខ្ញុំមានការសោកស្តាយណាស់ដោយ …… រតនា! ទាំងអស់នេះជាកំហុសរបស់ខ្ញុំ មកពីខ្ញុំមិនបានដឹងទាល់តែសោះថា… សូមមិត្តមេត្តាអភ័យទោសឱ្យខ្ញុំផង ចំពោះ… ខ្ញុំសង្ឃឹមថា រតនាពិតជាយល់អំពីបញ្ហានេះ ហើយប្រាកដជា… ពីខ្ញុំមិត្តជាទីស្រឡាញ់ លក្ខណា

ជំពូកទី៨

ផលិតផលខ្មែរ

រយៈពេល	14ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ប្រធានបទនៃអត្ថបទ
មេរៀនទី2	អំណាន៖ ផលិតផលនៅប្រទេសកម្ពុជា
មេរៀនទី3	បំណិន៖ ការឃោសនា
មេរៀនទី4	អំណាន៖ ដំណឹងពិសេស
មេរៀនទី5	វេយ្យាករណ៍៖ ប្រធាននិងកិរិយាបង្គោល
មេរៀនទី6	អំណាន៖ បទបង្ហាញអំពីផលិតផលត្បូងខ្មែរ
មេរៀនទី7	សំណេរ៖ អត្ថបទឃោសនា

មេរៀនទី1	**បំណិន៖ ប្រធានបទនៃអត្ថបទ**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីប្រធានបទនៃអត្ថបទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី101ដល់ទី102
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** គ. មូលហេតុនៃការបាត់បង់ព្រៃឈើនៅកម្ពុជា **លំហាត់ទី2៖** ផលវិបាកនៃការបាត់បង់ព្រៃឈើនៅលើពិភពលោក។

មេរៀនទី2	**អំណាន៖ ផលិតផលនៅប្រទេសកម្ពុជា**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីផលិតផលនៅប្រទេសកម្ពុជាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី103 ដល់ទី104 រូបភាពទំព័រ103
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ផលលិតផលប្រចាំខេត្តសៀមរាបមានរូបប្រាសាទ រូបអប្សរា ផ្តិល រ៉ែក ចូផ្តា កាបូប។ 2. នៅខេត្តកំពង់ឆ្នាំងគេប្រើនផលិតសម្ភារៈអំពីឫស្សី ផ្តៅ រពាក់ និងដី។ 3. សម្ភារៈផលិតពីសូត្រនិងអំបោះមានសារុងសូត្រ ក្រមាសូត្រ ស្បៃ ផាមួង ហូល។ 4. ផលិតផលរបស់ខ្មែរធ្វើអំពីឈើ ស្បែក ប្រាក់ ស្ពាន់ ឬ ផ្តៅ រពាក់ ដី ឫស្សី សរសៃសូត្រ អំបោះ និងកក់។ល។

	5. ខ្ញុំចូលចិត្តផលិតផលរបស់ខ្មែរ ព្រោះមានគុណភាពល្អនិងមានលក្ខណៈធម្មជាតិ។ 6. ដើម្បីថែរក្សាផលិតផលរបស់ខ្មែរយើង យើងត្រូវលើកតម្កើង និងប្រើប្រាស់តែផលិតផលខ្មែរ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ជំនាញ (គុ) ដែលវាងវៃ, ប៉ិន, ប្រសព្វ, ស្ទាត់, ដែលចេះស្ទាត់ប្រាកដ។ ខ. ផលិតផល (ន) ផលដែលបានធ្វើសម្រេចហើយ។ គ. កែច្នៃ (កិ) លៃលកឱ្យបានស្រួល, ធ្វើឱ្យល្អឡើងវិញ, កែសម្រួល។ ឃ. អតិថិជន (ន) ភ្ញៀវ **លំហាត់ទី2៖** ក. ប្រទេសកម្ពុជា សម្បូរផលិតផល ដែលធ្វើពីឈើ ស្បែក ស្ពាន់ ឬ ឫស្សី ផ្តៅ រពាក់ ជី... ខ. ប្រភេទផ្សេងៗនៃផលិតផលខ្មែរ គ. ឈ្នាង អង្រុត មង អួន...

មេរៀនទី3	**បំណិន៖ ការឃោសនា**
រយៈពេល	2ម៉
វត្ថុបំណង	ឃោសនាព័ត៌មានឬដំណឹងអ្វីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី105ដល់ទី106
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** បញ្ជាក់គុណភាពនៃវត្ថុ៖ មានសម្លៀកបំពាក់គ្រប់ម៉ូត គ្រប់ពណ៌ ល្អលើសគេ អ្នកតុបតែងមានបទពិសោធធ្វើឱ្យកូនក្រមុំ កូនកំលោះទទួលបាននូវភាពស្រស់ស្អាតនិងមានការពេញចិត្តគ្រប់ៗគ្នា។ ការទាក់ទាញ៖ តម្លៃថោកសមរម្យ បញ្ចុះតម្លៃ២៥%។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី4	**អំណាន៖ ដំណឹងពិសេស**
រយៈពេល	2ម៉
វត្ថុបំណង	ផ្សព្វផ្សាយដំណឹងពិសេសពីការបញ្ចុះតម្លៃទំនិញបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី107 ដល់ទី108
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. អត្ថបទនេះឃោសនាលក់ហូល ផាមួង 2. ហាងនោះមានទីតាំងនៅសង្កាត់បឹងកេងកង២ ខណ្ឌចម្ការមន រាជធានីភ្នំពេញ 3. ខ្ញុំចូលចិត្តប្រើសម្ភារៈធ្វើពីសាច់សូត្រណាស់ ព្រោះសាច់សូត្រត្រជាក់ហើយភ្លឺរលោង មានគុណភាពល្អ មានគោមផ្លែកៗទាន់សម័យនិយម ហើយជាស្នាដៃរបស់ខ្មែរយើង។

កំណែលំហាត់	**លំហាត់ទី1៖** ក. សុទ្ធ (គុ) ដែលជ្រះ, ស្អាត, ផ្លូវផង់, ឥតមន្ទិល, ត្រឹមត្រូវ, ហ្មត់ហ្មង, ឥតលាយ។ ខ. គុណភាព (ន) ដំណើរដែលមានគុណ, របស់ដែលមានអានុភាពសក្តិសិទ្ធិ។ ឧ. ឱសថនេះមានគុណភាពវិសេសណាស់។ គ. និយម (កិ) កំណត់ , អនុលោមតាម។ ឃ. សិប្បករ (ន) ជាង , អ្នកធ្វើជាង។ **លំហាត់ទី2៖** គេហដ្ឋាន ទីលំនៅ ផ្ទះ គ្រឹះស្ថាន ទីស្នាក់អាស្រ័យ។ **លំហាត់ទី3៖** ក. - ផ្ទៃសំពត់មានគោមប្លែកៗ ទាន់សម័យនិងត្រូវគ្រប់រឹយ - តម្លៃថោកសមរម្យ - បញ្ចុះតម្លៃជូន10% ខ. ការយោសនាលក់ហូល ផាមួង

មេរៀនទី5	**វេយ្យាករណ៍៖ ប្រធានបទនិងកិរិយាបង្គោល**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់ប្រធាននិងកិរិយាបង្គោលបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី109 ដល់ទី110
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. ផលិត ខ. ធ្លាក់ គ. លក់ ឃ. ចែកចាយ **លំហាត់ទី2៖** ប្រធាន | កិរិយាបង្គោល | កិរិយាជំនួយ ខ្ញុំ | មាន | នាង | អាន | ចូលចិត្ត សារី | បង្រៀន | ជួយ នាង | និទាន | លោកគ្រូអ្នកគ្រូ | សសើរ | **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) សុភីចង់អានសៀវភៅរឿង។ បូណាចូលចិត្តគូរគំនូរ។

មេរៀនទី6	**អំណាន៖ បទបង្ហាញអំពីផលិតផលក្បាងខ្មែរ**
រយៈពេល	2ម៉

វត្ថុបំណង	រៀបរាប់ពីផលិតផលត្បូងខ្មែរ (រមណីយដ្ឋានផ្អោក) បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី111 ដល់ទី112
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រមណីយដ្ឋានផ្អោកស្ថិតនៅស្រុកគិរីវង់ ខេត្តតាកែវ។ 2. រមណីយដ្ឋានផ្អោកមានលក់ផលិតផលត្បូងខ្មែរ។ 3. ប្រជាជននៅតំបន់នោះប្រកបរបរធ្វើស្រែចម្ការនិងដីករុករកត្បូង។ 4. ប្រជាជននៅតំបន់នោះប៉ិនប្រសប់លើផ្នែកច្នៃត្បូង 5. ខ្ញុំស្រឡាញ់ត្បូងខ្មែរណាស់ ព្រោះមានគុណភាពល្អ។
កំណែលំហាត់	**លំហាត់ទី1៖** ក. រមណីយដ្ឋាន (ន) ទីតំបន់ដែលគួរឱ្យរីករាយ, គួរឱ្យសប្បាយ។ ខ. ប៉ិន (គុ) ប្រសប់, ស្ទាត់, ពូកែ, ជំនាញ។ គ. គាំទ្រ (កិ) ទំនុកបម្រុង, ជួយឧបត្ថម, ជួយគាំពារ។ ឃ. តម្កើង (កិ) ធ្វើឱ្យថ្កើង, ដាក់តម្កល់លើទីខ្ពស់។ **លំហាត់ទី2៖** និង ឯ **លំហាត់ទី3៖** - នៅតាមតូបតូចៗដំបូលប្រក់ស្លឹកមានទូកញ្ចក់យ៉ាងស្អាតដាក់តាំងលក់ត្បូងខ្មែរព្រោងព្រាតគ្រប់ម៉ូតចម្រុះពណ៌ ជះពន្លឺផ្លេកៗមិនចាញ់ត្បូងនាំចូលពីប្រទេសក្រៅឡើយឯតម្លៃទៀតសោតក៏ថោកសមរម្យ។ - ភ្ញៀវដែលបានមកកម្សាន្តទីនេះ តែងនិយមគាំទ្រនិងកោតសរសើរពីគុណភាពនៃត្បូងនិងស្នាដៃច្នៃត្បូងរបស់ប្រជាជនខ្មែរយើងថាពិតជាល្អមែន។ **លំហាត់ទី4៖** ខ. លើកកម្ពស់ពីផលិតផលត្បូងខ្មែរ

មេរៀនទី7	**សំណេរ៖ អត្ថបទឃោសនា**
រយៈពេល	2ម៉ោ
វត្ថុបំណង	សរសេរអត្ថបទឃោសនាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី113
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) ដំណឹងថ្មី ហាងលក់អង្ករផ្តោម្លិះ "អង្ករខ្មែរ" មានកិត្តិយស សូមជម្រាបជូនដំណឹង ដល់អស់លោក លោកស្រីថា ហាងយើងខ្ញុំមានលក់អង្ករគ្រប់ប្រភេទ ជាពិសេសអង្ករផ្តោម្លិះ ដែលមានគុណភាពខ្ពស់ អង្ករសុទ្ធល្អ គ្មានជាតិគីមី ជាអង្ករធម្មជាតិសុទ្ធសាទ ហើយមានតម្លៃសមរម្យ។ ហាងយើងខ្ញុំមានទីតាំងនៅខាងកើតផ្សារស្ទឹងមានជ័យ។ ក្នុងឱកាសបុណ្យចូលឆ្នាំខាងមុខនេះ យើងខ្ញុំមានការថែមជូនប៊ីចេងមួយកញ្ចប់ក្នុងមួយបាវ។ ទូរស័ព្ទលេខ ០៧៨ ៦៦០០២៧

ជំពូកទី៩

ពេលវេលាជាមាសប្រាក់

រយៈពេល	7ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ មេសូត្រ៖ តម្លៃនៃពេលវេលា
មេរៀនទី2	ស្តាប់៖ វិជ្ជាជាឃ្លាំងទ្រព្យ
មេរៀនទី3	វេយ្យាករណ៍៖ សញ្ញាចុចពីរ (ៈ)
មេរៀនទី4	សំណេរ៖ ការតែងកំណាព្យបទពាក្យប្រាំពីរ

មេរៀនទី1	**អំណាន៖ តម្លៃនៃពេលវេលា**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីតម្លៃនៃពេលវេលាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី115 ដល់ទី116 រូបភាពទំព័រ 115
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ខ្ញុំត្រូវប្រឹងប្រែងរៀនសូត្រនៅវ័យក្មេង។ 2. ខ្ញុំមិនគួរខ្ជះខ្ជាយពេលវេលាទេ ពីព្រោះពេលវេលាមានតម្លៃ។ 3. ការលេងដោយឥតប្រយោជន៍ធ្វើឱ្យខ្ញុំទទួលផលអាក្រក់ដូចជា បាត់បង់ទ្រព្យសម្បត្តិ កិត្តិយសគ្រួសារ និងត្រូវបានគេតិះដៀល។ 4. ខ្ញុំខិតខំរៀន ខ្ញុំនឹងទទួលបាន ចំណេះដឹង ទ្រព្យសម្បត្តិ និងកិត្តិយស។ 5. គេចាត់ទុកពេលវេលាស្មើនឹងមាសប្រាក់។ 6. ដើម្បីឱ្យពេលវេលាមានតម្លៃខ្ញុំត្រូវ ប្រើប្រាស់ពេលវេលាឱ្យមានតម្លៃសម្រាប់ខ្លួនឯង និងសង្គមជាតិ។
កំណែលំហាត់	**លំហាត់ទី1៖** ក. សង្វាត (កិ) ខំប្រឹងខ្លាំង , ខ្មីឃ្មាត , ស្រវាស្រទេញ។ ខ. ហ៊ឺហា (គុ) ដែលឡួយឆាយ , ទាន់សម័យ។ គ. ហិនហោច (គុ) ដែលវិនាស , សាបសូន្យ។ ឃ. និន្ទា (ន) ការរិះគន់ , ដំណើរតិះដៀល។ **លំហាត់ទី2៖** ផ្សា (គុ) ដែលឈឺចាប់ពេតអោលរាលឆៀបៗដោយសារបួស។ ខ. ខ្ញុំផ្សារបួសណាស់។ ផ្សារ (ន) ទីប្រជុំលក់ ទិញរបស់ផ្សេងៗ។ ខ. ខ្ញុំទៅផ្សារ។

	ផ្សារ (កិ) ភ្ជាប់ដោយទឹកអន្សារ។ ឧ. គេផ្សារដៃក។ វែ (គុ) ដែលយល់។ ឧ. កញ្ញាមានភាពវៃឆ្លាតណាស់។ វ័យ (ន) អាយុ។ ឧ. ឆ្នាំនេះខ្ញុំមានវ័យ១៥ឆ្នាំ។ **លំហាត់ទី3៖** គ. ឥទ្ធិពលនៃការខ្ជះខ្ជាយពេលវេលា

មេរៀនទី2	**ស្តាប់៖ វិជ្ជាជាឃ្លាំងទ្រព្យ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីតម្លៃនៃវិជ្ជាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី117 ដល់ទី117 រូបភាពទំព័រ 117
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. វិជ្ជាជាឃ្លាំងទ្រព្យ 2. បើគ្មានចំណេះដឹងខ្ញុំនឹងមានការវិបាកដូចជា គេមើលងាយតពង្សផៅ គ្មានទ្រព្យសម្បត្តិ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ៣ក្យប្រាំពីរ **លំហាត់ទី2៖** គ. ៥វគ្គ **លំហាត់ទី3៖** ខ. តម្លៃនៃចំណេះវិជ្ជា

មេរៀនទី3	**វេយ្យាករណ៍៖ សញ្ញាចុចពីរ(:)**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាចុចពីរ (◌ः)បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី118
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** សារៈសំខាន់ លក្ខណៈ លោកៈ រយៈ សក្ការៈ **លំហាត់ទី2៖** ក. សក្ការៈ ខ. ឋានៈ គ. រយៈ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) លោកគ្រូខ្ញុំច្រើននិយាយពាក្យសច្ចៈ។ ខ្ញុំចូលចិត្តនារីខ្មែរ ព្រោះនាងមានលក្ខណៈសុភាពរាបសា។

មេរៀនទី4	**សំណេរ៖ តែងកំណាព្យបទពាក្យប្រាំពីរ**
រយៈពេល	2ម៉ោ
វត្ថុបំណង	តែងកំណាព្យបទពាក្យប្រាំពីរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី119 ដល់ទី120
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖**

(២)ប៉ុន្មាន (៣)ស្ងៀម (៤)ទីមទាម (៥)ភ្លាម ទំនេរ (៦)ប្រឹង (៧)ពឹង (៨)រិះរែ (៩)គ្នេរ (១០)ជ្រៃ

លំហាត់ទី2៖

(១)ល្អ (២)ច្រវាត់ (៣)ព្រហ្ម (៤)ងំ (៥)មាស (៦)មី (៧)រី

លំហាត់ទី3៖ (ចម្លើយជាក់ស្តែង)

សម្បត្តិកម្ពុជា

កម្ពុជាតូចពិតសម្បត្តិមាន មានគ្រប់ធនធានសម្បូរផល
ផលរ៉ៃព្រឹក្សាសុទ្ធតែផ្តល់ សត្វតូចរចល់ក្នុងព្រៃឈើ។
ឈើធំក្នុំខ្ពស់ជ្រោះជាមេ មេគង្គទន្លេនាំល្បាប់លើ
លើសលប់វាលស្រែចម្ការធ្វើ ធ្វើផលផ្តល់លើអស់លើសដី។

ជំពូកទី១០

ប្រយោជន៍នៃវិទ្យាសាស្ត្រ

រយៈពេល	9ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	ស្តាប់៖ រឿង ចៅប្រាក់ភ្នែកបី
មេរៀនទី2	វេយ្យាករណ៍៖ សញ្ញាឧទាន (!)
មេរៀនទី3	អំណាន៖ ប្រដាប់ជំនួយត្រចៀក
មេរៀនទី4	និយាយ៖ ការផ្តល់ការណែនាំផ្ទាល់មាត់
មេរៀនទី5	សំណេរ៖ ការណែនាំច្រើនដំហាន


មេរៀនទី1	**ស្តាប់៖ រឿង ចៅប្រាក់ភ្នែកបី**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសារប្រយោជន៍នៃវិទ្យាសាស្ត្រដែលអាចកែប្រែ សភាពការណ៍បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី122 រូបភាពទំព័រទី122
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. គ្រួសារចៅប្រាក់មានសមាជិកបួននាក់។ 2. ពេលធ្វើដំណើរចៅព្រឹងនិងឪពុកជួបនឹងរឿងទូកខូចម៉ាស៊ីន។ 3. ហេតុការណ៍នោះកើតឡើងនៅក្នុងសមុទ្រ នៅពេលធ្វើដំណើរទៅស្ងួចត្រី។ 4. ចៅប្រាក់ជួយឪពុកនិងប្អូនបានដោយសារ កែវយឹតនិងទូរស័ព្ទ។ 5. កែវយឹតមានសារប្រយោជន៍ដូចជា អាចមើលវត្ថុ ឬសកម្មភាពអ្វីមួយដែលនៅឆ្ងាយ បានដោយងាយ។ 6. ទូរស័ព្ទមានប្រយោជន៍ដូចជា ទទួលបានព័ត៌មានលឿនហើយដោះស្រាយបញ្ហាទាន់ពេលវេលា។
កំណែលំហាត់	**លំហាត់ទី1៖** 5=ក 1= ខ 3=គ 2=ឃ 4=ង **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី2	**វេយ្យាករណ៍៖ សញ្ញាឧទាន (!)**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាឧទានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី123

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. ឱ! កូនអើយកូន! ហេតុអ្វីបានធ្វើយ៉ាងដូច្នេះ? ខ. អើ! មែនហើយ! ខ្ញុំក៏ចង់ទៅដែរ។ គ. ក្បាច់ចម្លាក់នៅជញ្ជាំងថ្មប្រាសាទអង្គរវត្តនៅតែមានភាពរស់រវើកគួរឱ្យអស្ចារ្យមែនហ្ន៎! **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) ក. អៃយ៉ា! កុំព្យូទ័រនេះទំនើបមែន! ខ. ពុទ្ធោ! គួរឱ្យខ្លាចណាស់! គ. យី! ថ្នាក់រៀនឯងស្អាតណាស់! ឃ. អុញនំ! ខូចអស់!

មេរៀនទី3	**អំណាន៖ ប្រដាប់ជំនួយត្រចៀក**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសារប្រយោជន៍នៃប្រដាប់ជំនួយត្រចៀកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី124 ដល់ទី125
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. អង់ជេឡាមានបញ្ហាត្រចៀក។ 2. ឪពុកម្តាយអង់ជេឡានាំអង់ជេឡាទៅមន្ទីរពេទ្យ ដើម្បីពិនិត្យរកបញ្ហាត្រចៀករបស់នាង។ 3. ដើម្បីជំនួយត្រចៀក អង់ជេឡាប្រើប្រដាប់ជំនួយត្រចៀក។ 4. ប្រដាប់ជំនួយត្រចៀកមានសារប្រយោជន៍ ជួយអ្នកមានត្រចៀកធ្ងន់ឱ្យមានភាពងាយស្រួលក្នុងការទំនាក់ទំនងគ្នា។
កំណែលំហាត់	**លំហាត់ទី1៖** ក. វេជ្ជបណ្ឌិត (ន) ពេទ្យ។ ខ. ទិព្វ (គុ) ដែលជារបស់ទេវតា។ គ. បារម្ភ (ន) ដំណើរនឹកចង់ឬនឹកព្រួយជាមុន។ **លំហាត់ទី2៖** យី! ប្រដាប់ជំនួយត្រចៀកជាវត្ថុអស្ចារ្យណាស់សម្រាប់អ្នកមានត្រចៀកធ្ងន់។ **លំហាត់ទី3៖** គ. ប្រដាប់ជំនួយត្រចៀក

មេរៀនទី4	**និយាយ៖ ការផ្តល់ការណែនាំផ្ទាល់មាត់**
រយៈពេល	2ម៉ោ
វត្ថុបំណង	ផ្តល់ការណែនាំផ្ទាល់មាត់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី126 ដល់ទី127 រូបភាពទំព័រ127

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ឱពុកគន្ធាដាំត្រសក់។ 2. ដើម្បីដាំត្រសក់គេត្រូវ - ភ្ជួរ ឬកាប់ដីហាលឱ្យស្ងួត - ជ្រើសរើសគ្រាប់ពូជហើយហាលឱ្យស្ងួត - ធ្វើរងនិងកាប់រណ្តៅ - ដាក់គ្រាប់ពូជក្នុងរណ្តៅ - ស្រោចទឹក 3. ដើម្បីឱ្យត្រសក់មានផ្លែច្រើន គេត្រូវ - ដកដើមត្រសក់អន់ៗចេញ - ជ្រុំដីជុំវិញគល់ ដាក់ដី ដោតមែកឈើក្រៀមៗ - ស្រោចទឹកពីរដងក្នុងមួយថ្ងៃ(រដូវប្រាំង) 4. ដើម្បីផ្តល់ការណែនាំយើងត្រូវប្រើពាក្យ ដំបូង បន្ទាប់មក បន្ទាប់មកទៀត បន្ទាប់ពី ចុងក្រោយ។
កំណែលំហាត់	**លំហាត់ទី1៖**  ②  ⑤  ①  ③  ④  ⑥ **លំហាត់ទី2៖**(ចម្លើយជាក់ស្តែង)
មេរៀនទី5	**សំណេរ៖ ការណែនាំច្រើនដំហាន**

រយៈពេល	2ម៉
វត្ថុបំណង	សរសេរការណែនាំអំពីរបៀបធ្វើអ្វីមួយ ឬប្រើអ្វីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី128 ដល់ទី129
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) របៀបដាំឪឡឹក ឪឡឹកជាដំណាំផ្តល់ផលជាបន្លែផងហើយក៏ជាផ្លែឈើផងដែរ។ ដំណាំនេះ ផ្តល់ផលក្រោយពេលដាំរយៈពេល ៦០ - ៩០ថ្ងៃ។ ដំបូង យើងត្រូវភ្ជួរ ឬកាប់ដី។ ការភ្ជួរដីត្រូវធ្វើពីរដំណាក់កាល។ ដំណាក់កាលទី១៖ ភ្ជួរ ឬកាប់ដីនិងសម្អាតស្មៅឱ្យស្អាត រួចហាលចោល១សប្តាហ៍។ ដំណាក់កាលទី២៖ បាចជីកំប៉ុស ឬលាមកសត្វ រួចភ្ជួរត្រឡប់លុបជីនោះដោយបំបែកដីនិងកៀរដីឱ្យស្មើ។ បន្ទាប់មក យើងជីករណ្តៅទំហំ៣០ ស.ម × ៤០ ស.ម និង ជម្រៅ១៥-២០ស.ម ដោយទុកចន្លោះពីរណ្តៅមួយទៅរណ្តៅមួយប្រវែង ១.៥មទៅ២ម អាស្រ័យទៅតាមពូជឪឡឹកហើយដាក់ជីក្នុងរណ្តៅនីមួយៗមុននឹងយកកូន ឬគ្រាប់ឪឡឹកទៅដាំ។ បន្ទាប់មកទៀត ត្រូវធ្វើស្មៅនិងជ្រុំគល់។ ចុងក្រោយ ស្រោចទឹកឱ្យសើមល្មមរាល់ព្រឹកនិងល្ងាច (រដូវប្រាំង)

ជំពូកទី១១

អ្នកមានគុណ

រយៈពេល	10ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ មេសូត្រ៖ កតញ្ញូប្រាំប្រការ
មេរៀនទី2	សំណេរ៖ ពណ៌នាអំពីមនុស្ស
មេរៀនទី3	បំណិន៖ ការកត់ត្រាគំនិតសំខាន់ៗនៅក្នុងកំណាព្យ
មេរៀនទី4	វេយ្យាករណ៍៖ គុណនាមចំនួន
មេរៀនទី5	អំណាន៖ រឿង បងប្រុស

មេរៀនទី1	**អំណាន៖ មេសូត្រ៖ កតញ្ញូប្រាំប្រការ (បទពាក្យប្រាំពីរ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រតិបត្តិនូវកតញ្ញូប្រាំប្រការបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី131 ដល់ទី 132 រូបភាពទំព័រទី131
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ20
ចម្លើយនៃសំណួរ	1. កូនត្រូវមានកតញ្ញូប្រាំប្រការចំពោះឪពុក ម្តាយ។ 2. ដើម្បីសងគុណម្តាយ ឪពុកខ្ញុំបាន ជួយរំលែកការងារ មើលថែពេលលោកមានជំងឺ គោរពពាក្យទូន្មានរបស់លោក។ (ចម្លើយអាចមានផ្សេងទៀត) 3. អត្ថបទកំណាព្យនេះនិយាយពីការតបស្នងសងគុណមាតាបិតា។ 4. អត្ថបទនេះមានគំនិតអប់រំឱ្យមនុស្សគ្រប់រូបចេះសងគុណឪពុក ម្តាយ។ 5. កំណាព្យនេះក្នុងមួយវគ្គៗមាន៤ឃ្លា។
កំណែលំហាត់	**លំហាត់ទី1៖** ក. ធុរៈ (ន) ដំណើរដំពាក់ដោយកិច្ចការណាមួយ។ ខ. ស្រាន្ត (គុ) ដែលលំបាក ដែលនឿយហត់ ដែលអស់កម្លាំង។ គ. ញាតិ (ន) អ្នកដែលរួមខ្សែរលោហិតនឹងគ្នាខាងមាតាឬបិតា។ ឃ. សង្ខារ (ន) អាយុ។ **លំហាត់ទី2៖** ក. វាចា ⇨ សម្តី ខ. សព ⇨ ខ្មោច គ. បុត្រ ⇨ កូន ឃ. វន្ទា ⇨ សំពះ ង. មាតា ⇨ម្តាយ បិតា ⇨ ឪពុក

	លំហាត់ទី3៖ ក. ៥វគ្គ ខ. ការតមស្នងសងគុណមាតាបិតា **លំហាត់ទី4៖** ចួនក្នុងវគ្គ ពុក ចួន ចុក ធានា ចួន ការពារ រងារ គុណ ចួន ពុន ភ្លន់ សៅ ចួន ក្តៅ ឪ ញាតិ ចួន ទៀត សណ្តាន ចួន ថ្កាន បាន វេលា ចួន ភ្ញា វន្ទា មាតា ចួន សង្វារ លោកកិយ ចួន ប្រពៃណី បុត្រី ចួនឆ្លងវគ្គ ក្តៅ ចួន សៅ ស្រាន្ត ចួន សន្តាន គ្នា ចួន វេលា ភក្តី ចួន លោកកិយ

មេរៀនទី2	**សំណេរ៖ ពណ៌នាអំពីមនុស្ស**
រយៈពេល	2ម៉
វត្ថុបំណង	ពណ៌នាអំពីមនុស្សបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី133 ដល់ទី134
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖**(ចម្លើយជាក់ស្តែង) ពណ៌នាអំពីមនុស្ស បងស្រីខ្ញុំឈ្មោះ ចរិយា។ គាត់មានអាយុ ២៥ឆ្នាំ។ គាត់ជាជាងថ្នៃម៉ូតសម្លៀកបំពាក់ខ្មែរ។ សព្វថ្ងៃបងស្រីខ្ញុំរស់នៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។ បងស្រីរបស់ខ្ញុំមានមាឌតូចល្មម កម្ពស់ប្រហែល១.៦៥ម សម្បុរស្រឡម សក់វែងប្រាសស្មាខ្មៅរលោងប្រៀបដូចនឹងរោមក្អែក ចំណែងមុខវិញមានរាងពងក្រពើសាច់ម៉ដ្ឋរលោង ចិញ្ចើមខ្មៅរាងកោងដូចដងធ្នូ សមទៅនឹងច្រមុះស្រួចនិងបបូរមាត់មិនស្តើងមិន ក្រាស់មើលទៅស្រស់ណាស់គួរឱ្យស្រឡាញ់។ មិនតែប៉ុណ្ណោះទេ បងស្រីខ្ញុំមានដៃជើងតូចៗស្រឡូន សមនឹងដងខ្លួនហើយរឹងមាំសម្រាប់អាជីពរបស់គាត់។ បងស្រីខ្ញុំ ជាមនុស្សរួសរាយរាក់ទាក់ហើយមានចិត្តល្អហើយមានចរិតស្លូតបូតចំពោះមនុស្សទូទៅ មានការអធ្យាស្រ័យ និងជួយរំលែកទុក្ខអ្នកដទៃទៅតាមលទ្ធភាពរបស់គាត់។គាត់មានការព្យាយាមនិងទទួលខុសត្រូវចំពោះការងារដែលគាត់ធ្វើ។ បងស្រីរបស់ខ្ញុំពូកែថ្នៃម៉ូតសម្លៀកបំពាក់ខ្មែរណាស់។ គ្រប់ស្នាដៃរបស់គាត់តែងតែមានការកោតសរសើរពី

	ភ្ញៀវដែលជាអតិថិជន។ ដោយសារតែបងស្រីគាត់មានចរិតស្លូតបូតនិងរួសរាយរាក់ទាក់ពីកំណើតនោះ និងមានភាពទទួលសុខត្រូវខ្ពស់ចំពោះការងារ ធ្វើឱ្យអាជីពរបស់គាត់មានឈ្មោះ បោះសំឡេងពេញទីក្រុងតាខ្មៅនិងកន្លែងផ្សេងៗទៀត។ បច្ចុប្បន្ន ហាងកាត់ដេរបស់គាត់មានភ្ញៀវចេញចូលឥតអាក់ធ្វើឱ្យជីវភាពរបស់គាត់ធូរធារ។ សព្វថ្ងៃអ្នកជិតខាង អតិថិជនចូលចិត្តរាប់អានបងស្រីខ្ញុំណាស់។ ជាពិសេសមនុស្សក្នុងគ្រួសារគាត់មានការគោរពនិងស្រឡាញ់បងស្រីគ្រប់ៗគ្នា។ ព្រោះគាត់ជាមនុស្សរួសរាយរាក់ទាក់ អធ្យាស្រ័យ តែម៉ត់ចត់។

មេរៀនទី3	**បំណិន៖ ការកត់ត្រាគំនិតសំខាន់ៗនៅក្នុងកំណាព្យ**
រយៈពេល	2ម៉
វត្ថុបំណង	កត់ត្រាគំនិតសំខាន់ៗនៅក្នុងកំណាព្យបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី135ដល់ទី136 រូបភាពទំព័រទី 135
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** ម្តាយធ្វើអ្វីៗត្រូវគិតដល់កូនក្នុងផ្ទៃ

មេរៀនទី4	**វេយ្យាករណ៍៖ គុណនាមចំនួន**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់គុណនាមចំនួនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី137 ដល់ទី138
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** **លំហាត់ទី2៖** ក. - ឪពុកសំដាំដូងចំនួនដប់ប្រាំបីដើម។ - សុភាពចិញ្ចឹមឆ្កែពីរ។ ខ. - នារីជាកូនទី២។ នាងរៀនជាប់លេខ២។ - គ្រួសារខ្ញុំហូបបាយពេលល្ងាចនៅម៉ោងប្រាំពីរគត់។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

គុណនាមចំនួនរាប់	គុណនាមចំនួនរៀប
ដប់ពីរ មួយឡូត៍ មួយរយ បីពាន់ ប្រាំមួយ សាមសិប ពីរម៉ឺន	ទីប្រាំ ថ្នាក់ទីបី ជាន់ទីពីរ ទីហាសិប ទីប្រាំ ម៉ោងប្រាំមួយ យប់ទីបី

	- បងខ្ញុំមានកូនចំនួនបីនាក់។ - ម្តាយណារីមានអាយុ៥០ឆ្នាំ។ - ខ្ញុំអង្គុយនៅតុទីបី។ - បន្ទប់រៀនឯងនៅជាន់ពីរ។

មេរៀនទី5	**អំណាន៖ រឿង បងប្រុស**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីសន្តានចិត្តរបស់បងប្រុសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី139 ដល់ទី140
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. និតនិងនួនត្រូវជាបងប្អូននឹងគ្នា។ 2. ដើម្បីឱ្យនួនបានបន្តការសិក្សា និតបានទៅខ្ចីប្រាក់ឥណទានពីធនាគារភូមិធ្វើដើមទុន ចិញ្ចឹមជ្រូក ត្រី។ 3. បានជានិតតស៊ូចិញ្ចឹមប្អូន ព្រោះនិតជាបងរបស់នួនហើយក៏ជាមនុស្សមានការទទួលខុសត្រូវឆាកជីវិតរបស់ខ្លួន។ 4. ខ្ញុំពេញចិត្តតួអង្គនិត ព្រោះនិតមានការទទួលខុសត្រូវខ្ពស់ហើយមានចិត្តតស៊ូនិងព្យាយាមពុះពារគ្រប់ឧបសគ្គ។ 5. រឿងនេះអប់រំឱ្យមនុស្សចេះតស៊ូពុះពារគ្រប់ឧបសគ្គ ដើម្បីអនាគត។
កំណែលំហាត់	**លំហាត់ទី1៖** ក. បច្ចេកទេស (ន) ចំណេះពិសេសជាចំណែកមួយជាច់មុខផ្សេងគ្នា។ ខ. ឥណទាន (ន) ប្រាក់ ឬអ្វីៗសម្រាប់ឱ្យគេខ្ចី។ គ. ឧបត្ថម្ភ (កិ) ផ្តល់ឱ្យ ផ្គត់ផ្គង់ ទំនុកបម្រុង។ ឃ. ធនាគារ (ន) ឃ្លាំងដាក់ប្រាក់ ឃ្លាំងដាក់ទ្រព្យ។ ង. អង្គការ (ន) កម្មការដែលរដ្ឋ ឬក្រុមរាជការណាមួយបង្កើតឡើងដើម្បីភាពរីកចម្រើន។ **លំហាត់ទី2៖** គ. និតអាចរកប្រាក់ឧបត្ថម្ភការសិក្សារបស់នួន ដោយមិនជួបការលំបាកដូចមុនទៀតឡើយ **លំហាត់ទី3៖** ក. សិក្សា ស្វាធ្យាយ ខ. យប់ ដេក គេង សម្រាន្ត គ. ផ្គត់ផ្គង់ ទំនុកបម្រុង ផ្តល់ឱ្យ ឃ. ថវិកា លុយ

ជំពូកទី១២

ក្តីសង្ឃឹមរបស់កុមារ

រយៈពេល	11ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ការសង្ខេបរឿង
មេរៀនទី2	អំណាន៖ រឿង បងប្អូនពីរនាក់
មេរៀនទី3	ស្តាប់៖ រឿង ទឹកចិត្តមេមាន់
មេរៀនទី4	អំណាន៖ រឿង អ្នកគ្រូរបស់គុណ
មេរៀនទី5	វេយ្យាករណ៍៖ គុណនាមសំណួរ
មេរៀនទី6	សំណេរ៖ សំណេរបាយការណ៍ស្តីពីអំណានរឿងសម្រាប់អ្នកស្តាប់

មេរៀនទី1	**បំណិន៖ ការសង្ខេបរឿង**
រយៈពេល	2ម៉
វត្ថុបំណង	សង្ខេបរឿងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី142 ដល់ទី144
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** មានស្ត្រីមេម៉ាយម្នាក់មានកូនស្រីបីនាក់។ កូនស្រីបងចូលចិត្តដើរលេងជាមួយមិត្តភក្តិ។ កូនស្រីបន្ទាប់មិនសូវចូលចិត្តការរៀនសូត្រទេ។ រីឯកូនស្រីពៅជាក្មេងស្លូតបូតចេះគិតគូរដល់គ្រួសារនិងខិតខំរៀនសូត្រ។ ថ្ងៃមួយពេលម្តាយមិននៅកូនទី១និងកូនទី២បានឈ្លោះប្រកែកគ្នាទោះបីប្អូនពៅឃាត់យ៉ាងណាក៏មិនស្តាប់។ ពេលបានដឹងរឿង ម្តាយក៏ហៅកូនទាំងបីនាក់មកជុំគ្នា។ ម្តាយប្រាប់កូនម្នាក់ៗឱ្យរៀបរាប់អំពីការងារមានប្រយោជន៍ដែលគេបានធ្វើនៅ ថ្ងៃនេះ។ គាត់ឱ្យកូនទាំងពីរទៅនៅជាមួយបងប្អូននៅឯទីក្រុង ធ្វើការជាមួយគេហើយទុកកូនពៅឱ្យនៅជាមួយ ព្រោះនាងខំរៀន នឹងជួយការងារផ្ទះ។ កូនស្រីទាំងពីរដឹងខ្លួនខុសក៏សន្យាថានឹងកែខ្លួនហើយសុំឱ្យនាងបានរៀនតទៅទៀត។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) និតនិងនួនជាបងប្អូនបង្កើតនឹងគ្នា។ តាំងពីអ្នកមានគុណបានចែកឋានទៅជីវភាពគ្រួសារ គេជួបការលំបាកខ្លាំង។ និតជាបងសម្រេចចិត្តផ្អាកការរៀនសូត្រមួយរយៈដោយទុកឱ្យប្អូនបានសិក្សាបន្តទៀត។ នួនខំរៀនណាស់ខកចិត្តឡើយ នួនតាំងចិត្តថានឹងខិតខំរៀនសូត្របានប្រឡងជាប់ ថ្នាក់ទី១២ឯនិតវិញពេលទំនេរពី ការងារស្រែចម្ការ

	គេបានចូលសិក្សានៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍។ ថ្ងៃមួយ និតនិងអ្នកភូមិខ្លះបាននាំគ្នាទៅខ្ចីប្រាក់ឥណទានពីធនាគារភូមិ យកមកធ្វើទុនក្នុងការចិញ្ចឹមជ្រូកនិងចិញ្ចឹមត្រី។ និតរៀនបច្ចេកទេសចិញ្ចឹមសត្វពីមជ្ឈមណ្ឌលសិក្សាសហគមន៍។ និតអាចរកប្រាក់ឧបត្ថម្ភការសិក្សារបស់នួនដោយមិនជួបការលំបាកដូចមុនទៀតឡើយ។ ក្រោយពីបញ្ចប់ការសិក្សា នួនបានចូលបម្រើការងារក្នុងក្រុមហ៊ុនមួយនៅរាជធានីភ្នំពេញ។ នួនសន្សំប្រាក់ខែបានមួយចំនួន។ គេបានយកប្រាក់ទាំងនោះទៅប្រគល់ជូនបងទាំងអស់ ដើម្បីឱ្យបងរៀបអាពាហ៍ពិពាហ៍។ ចាប់ពីពេលនោះមកគ្រួសារនេះរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល។

មេរៀនទី2	**អំណាន៖ រឿង បងប្អូនពីរនាក់**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់ភាពឆ្លាតវៃក្នុងការដោះស្រាយបញ្ហាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី145 ដល់ទី147 រូបភាពទំព័រ145
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ណាតច្រណែននឹងនាតដែលជាបងស្រីរបស់ខ្លួន។ នាតមិនស្អប់ណាតទេ។ 2. ពេលឃើញកូនមិនចេះស្រឡាញ់គ្នា ឪពុកម្តាយមានអារម្មណ៍ខ្វល់ខ្វាយណាស់។ 3. ដើម្បីឱ្យកូនចេះស្រឡាញ់គ្នាឪពុកម្តាយនាតបានទិញកូនឡានជំរមួយនិងសៀវភៅ រូបភាពអំពីឡានតូច ធំមួយសម្រាប់។ គាត់បានយករបស់ទាំងនោះ ទៅឱ្យនាតហើយប្រាប់នាតថាមិត្តភក្តិកូនឱ្យ។ 4. មធ្យោបាយនោះបានសម្រេចលទ្ធផលល្អណាស់។ 5. នៅចុងបញ្ចប់ណាតតែងតែនៅជិតនាតនិងនិយាយ ឬលេងជាមួយគ្នាយាងសប្បាយ។ 6. នាតជាក្មេងល្អណាស់ ព្រោះចេះស្រលាញ់ប្អូនមិនប្រកាន់ខឹងនឹងប្អូនដែលស្អប់ខ្លួនឡើយ។ 7. នៅក្នុងរឿងនេះ ខ្ញុំចូលចិត្តតួអង្គនាតនិងតួអង្គឪពុកម្តាយ ព្រោះពួកគេសុទ្ធតែមានសន្តានចិត្តល្អមានព្រហ្មវិហារធម៌ចំពោះកូននិងប្អូន។
កំណែលំហាត់	**លំហាត់ទី1៖** ក. ផ្គត់ផ្គង់ (គុ) ដែលទំនុកបម្រុងមិនឱ្យខ្វះ។ ខ. សប្តាហ៍ (គុ) ចំនួនប្រាំពីរថ្ងៃ។ គ. ម៉ឺងម៉ាត់ (គុ) ដែលតឹងតែង ប្រាកដប្រជា។ **លំហាត់ទី2៖** ក. កូនច្បង ≠ កូនពៅ ខ. ស្រលាញ់ ≠ ស្អប់ **លំហាត់ទី3៖** ក. ទំនុកបម្រុង

	ខ. អាទិត្យ គ. ប្រាកដប្រជា ឃ. ម្តាយឪពុក **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង)

មេរៀនទី3	**ស្តាប់៖ រឿង ទឹកចិត្តមេមាន់**
រយៈពេល	2ម៉ោ
វត្ថុបំណង	ចូលរួមបំពេញតួនាទីជាអ្នកផ្តល់សិទ្ធិពេញលេញដល់កុមារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី148 ដល់ទី149 រូបភាពទំព័រ148
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. កសិករចិញ្ចឹមមេមាន់មួយនិងមេទាមួយឱ្យនៅក្នុងទ្រុងជាមួយគ្នា។ 2. ក្រោយពេលមេទាងាប់ចោលកូនទៅមេមាន់ ឃើញកូនទាកំព្រាក៏យកមកចិញ្ចឹមបីបាច់ដូចកូនបង្កើតដែរ។ 3. កូនមាន់ដែលតូចជាងគេបានសួរទៅមេមាន់ថា៖ «ម៉ែ! ហេតុអ្វីបានជាម៉ែមើលថែកូនទា?» 4. មេមាន់ឆ្លើយប្រាប់កូនមេមាន់៖ " ពីព្រោះវាកំព្រាអត់មេ ហើយវានៅតូចណាស់។ វាត្រូវការ ការថែទាំដូចកូនដែរ ម៉ែចិញ្ចឹមវាព្រោះវាក៏មានសិទ្ធរស់ រានមានជីវិតដូចក្មេងទូទៅដែរ។ បើម៉ែមិនយកវាមកចិញ្ចឹមទេតើវារស់នៅដូចម្តេច? " ។ 5. មេមាន់ជាសត្វមានចិត្តល្អណាស់ចេះយកអាសាអ្នកដទៃ។
កំណែលំហាត់	**លំហាត់ទី1៖** (១)មាន់ (២)ទា (៣)ងាប់ (៤)កូន **លំហាត់ទី2៖** 3=ក. មេទាញាស់បានកូនមួយ។ 1=ខ. កសិករម្នាក់ចិញ្ចឹមមេមាន់មួយនិងមេទាមួយ។ 4=គ. មេទាងាប់ចោលកូន។ 2=ឃ. មេមាន់ញាស់បានកូនបួន។ 5=ង. មេមាន់ចិញ្ចឹមកូនទាដូចកូនបង្កើត។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) មានកសិករម្នាក់បានចិញ្ចឹមមេមាន់មួយនិងមេទាមួយឱ្យនៅក្នុងទ្រុងជាមួយគ្នា។ ក្រោយមកមេមាន់ញាស់បានកូនបួន។ ចំណែកមេទាញាស់បានកូនមួយក៏ស្លាប់ចោលកូនទៅ។ មេមាន់ឃើញកូនទាកំព្រា ក៏យកមកចិញ្ចឹមបីបាច់ដូចកូនបង្កើតដែរ។ រាល់ថ្ងៃមេមាន់បណ្តើរកូនទាំងអស់រកចំណីគ្រប់ទីកន្លែង។ ថ្ងៃមួយ កូនមាន់តូចជាងគេឆ្ងល់នឹងទង្វើរបស់មេក៏សួរ៖ "ម៉ែ! ហេតុអ្វីបានជាម៉ែមើលថែកូនទា?"។ មេមាន់ឆ្លើយ៖ "ពីព្រោះកំព្រាអត់មេ ហើយវានៅតូចណាស់។ វាត្រូវការការថែទាំដូចកូនដែរ ម៉ែចិញ្ចឹមវាព្រោះវាក៏មានសិទ្ធរស់រានមានជីវិតដូចក្មេងទូទៅដែរ។ បើម៉ែមិនយកវាមកចិញ្ចឹមទេ តើវារស់នៅដូចម្តេច?"។ កូនមាន់សួរមេវាទៀត៖ " ម៉ែគិត

	ចិញ្ចឹមវាហូតឬ? ″ ។ មេមាន់ឆ្លើយ៖ ″ ទេ! ដល់វាគ្រប់អាយុ ម៉ែឱ្យវាទៅរៀនជាមួយកូន ហើយដល់ វាចេះចិញ្ចឹមខ្លួនបាន ម៉ែឈប់ជួយវាហើយ ″ ។ ″ យី! ម៉ែខ្ញុំចិត្តល្អណាស់ ″ កូនមាន់លាន់មាត់។

មេរៀនទី4	**អំណាន៖ រឿង អ្នកគ្រូរបស់គុណ**
រយៈពេល	2ម៉
វត្ថុបំណង	បំពេញកាតព្វកិច្ចជាកុមារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី150 ដល់ទី151
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. គុណជាក្មេងឆ្លាត ស្លូតបូតហើយឧស្សាហ៍ព្យាយាម ខិតខំរៀនសូត្រនិងធ្វើកិច្ចការដោយម៉ត់ចត់។ 2. អ្នកបានជួយគុណគឺអ្នកគ្រូរបស់គុណនិងពូធឿន។ អ្នកគ្រូជួយណែនាំ គុណឱ្យរៀនគូរគំនូរជាមួយឪពុកមាគាត់គឺពូធឿន ហើយគាត់ជួយផ្គត់ផ្គង់ផ្នែកសម្ភារៈ។ ចំណែកពូធឿន ជួយបង្រៀនគំនូរដល់គុណនិងណែនាំគុណឱ្យចូលរួមប្រឡងគំនូរ។ 3. បានជាគាត់ជួយគុណព្រោះគុណជាក្មេងក្រីក្រ តែមានចរិតស្លូតបូត សុភាពរាបសានិងឧស្សាហ៍ព្យាយាម។ 4. នៅទីបញ្ចប់គុណក្លាយជាជាងគំនូរដ៏ល្បីម្នាក់។ 5. អ្នកគ្រូក្នុងរឿងនេះ ជាមនុស្សល្អណាស់ មានសន្តានចិត្តទូលាយសប្បុរសចេះសន្តោសប្រណីដល់កុមារកំព្រាក្រីក្រ។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងបង្រៀនសិស្សឱ្យចេះដឹងឱ្យក្លាយជាមនុស្សល្អគ្រូបានជ្រោមជ្រែងនិងលះបង់ថវិកាខ្លះ ដើម្បីឱ្យសិស្សដែលជួបការលំបាកអាចកសាងអនាគតខ្លួនឱ្យបានរុងរឿងទៀតផង។ 6. គួរយកគំរូតាមគុណ ព្រោះគុណជាសិស្សឆ្លាត ស្លូតបូត ហើយឧស្សាហ៍ព្យាយាមរៀនសូត្រ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ឧស្សាហ៍ (គុ) ដែលព្យាយាម ខំប្រឹង សង្វាត។ ខ. ជីវភាព (ន) ភាពនៃការរស់នៅ ការចិញ្ចឹមជីវិត។ គ. សម្ភារៈ (ន) ទ្រព្យរបស់ដែលមានដោយខានពុំបាន គ្រឿងប្រើប្រាស់។ ឃ. កម្រិត (ន) កន្លែងដែលក្រិត ដែលគូសចំណាំ។ **លំហាត់ទី2៖** ក. គុណជាសិស្សឆ្លាត ស្លូតបូត ហើយឧស្សាហ៍ព្យាយាមរៀនសូត្រ។ **លំហាត់ទី3៖** ក្រីក្រ ក្សត់ លំបាក ទាល់ក្រ។ **លំហាត់ទី4៖** គ. ក្រោយមកគុណក្លាយជាមនុស្សគ្មានការងារធ្វើ។ **លំហាត់ទី5៖** (ចម្លើយជាក់ស្តែង)

មេរៀនទី5	**វេយ្យាករណ៍៖ គុណនាមសំណួរ**

រយៈពេល	1ម៉
វត្ថុបំណង	ប្រើប្រាស់គុណនាមសំណួរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី152
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** តើសិស្សានុសិស្សកំពុងអានអ្វី? តើនរណាខ្លះនាំគ្នាទៅសាលារៀន? **លំហាត់ទី2៖** ក. អ្វី ខ. ប៉ុន្មាន **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) - តើនេះជាសៀវភៅអ្នកណា? - តើសត្វអ្វីដែលមានប្រយោជន៍សម្រាប់កសិករ? - តើសៀវភៅនេះថ្លៃប៉ុន្មាន? - តើសព្វថ្ងៃឯងរស់នៅខេត្តណា? - តើយើងរៀនមុខវិជ្ជាអ្វីខ្លះថ្ងៃនេះ? - តើមុខវិជ្ជាណាខ្លះដែលឯងចូលចិត្តជាងគេ?

មេរៀនទី6	**សំណេរ៖ សំណេររបាយការណ៍ស្តីពីអំណានរឿងសម្រាប់អ្នកស្តាប់**
រយៈពេល	2ម៉
វត្ថុបំណង	សរសេររបាយការណ៍ស្តីពីអំណានរឿងសម្រាប់អ្នកស្តាប់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី153 ដល់ទី154
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** រឿង ព្រាហ្មណ៍និងស្មារ គម្រោងតែង ១. សេចក្តីផ្តើម - ពេលវេលា - ទីកន្លែង ២. តួសេចក្តី - ការសង្ខេបរឿង..... - មូលហេតុនៃការជ្រើសរើស..... - អ្នកដែលគួរចាប់អារម្មណ៍..... - ការពិពណ៌នាអំពីប្រតិកម្មរបស់អ្នកស្តាប់..... - ការវាយតម្លៃអំណាន ចំណុចល្អ ចំណុចអាក្រក់ ៣. បញ្ចប់សេចក្តី រឿង ព្រាហ្មណ៍និងស្មារជារឿង.....

បញ្ជាក់៖ អ្នកអាចជ្រើសរើសរឿងផ្សេងទៀត ដែលរឿងនោះផ្តល់ការអប់រំល្អ។

ជំពូកទី១៣

ធនធានរ៉ែនៅប្រទេសកម្ពុជា

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ការកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន
មេរៀនទី2	អំណាន៖ ធនធានធម្មជាតិនៅក្នុងដី
មេរៀនទី3	ស្តាប់៖ ត្បូងពណ៌ស្វាយមួយគ្រាប់
មេរៀនទី4	វេយ្យាករណ៍៖ គុណនាមចង្អុល
មេរៀនទី5	អំណាន៖ រ៉ែប្រេងកាត
មេរៀនទី6	អំណាន៖ រ៉ែមាសនៅកម្ពុជា
មេរៀនទី7	សំណេរ៖ អត្ថបទព័ត៌មានខ្លី

មេរៀនទី1	**បំណិន៖ ការកត់ត្រាចំណុចសំខាន់ៗនៃព័ត៌មាន**
រយៈពេល	2ម៉
វត្ថុបំណង	កត់ត្រាចំណុចសំខាន់ៗនៃព័ត៌មានបានត្រឹមត្រូវ។
សម្ភារៈបង្រៀនទេស	ស.ស. ទំព័រទី156ដល់ទី157
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់៖** ចំណុចសំខាន់ៗនៃអត្ថបទខាងលើមាន៖ - ប្រទេសកម្ពុជាសម្បូររ៉ែច្រើនប្រភេទ - ទីកន្លែងមានរ៉ែ នៅស្រទាប់ខាងលើ ក្រោមបាតសមុទ្រ - ការប្រើប្រាស់ រ៉ែប្រេងកាតគេចម្រាញ់ ឱ្យបានជាប្រេងឥន្ធនៈផ្សេងៗ។ រ៉ែដែកស្លឱ្យបានជាដែកសុទ្ធ។ រ៉ែមាស គេយកទៅធ្វើអគ្គិសនីវិភាគយកមាសសុទ្ធ។ រ៉ែត្បូង គេយកទៅច្នៃធ្វើគ្រឿងអលង្ការ។

មេរៀនទី2	**អំណាន៖ ធនធានធម្មជាតិនៅក្នុងដី**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីធនធានធម្មជាតិនៅក្នុងដីបានត្រឹមត្រូវ។
សម្ភារៈបង្រៀនទេស	ស.ស. ទំព័រទី158 ដល់ទី160
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ប្រទេសកម្ពុជាមានរ៉ែនៅក្នុងខេត្តព្រះវិហារ កំពង់ធំ រតនគិរី ប៉ៃលិន មណ្ឌលគិរី កោះកុង បឹងទន្លេសាប និងខេត្តព្រះសីហនុ។

2. រ៉ែប្រទេសកម្ពុជាមាន រ៉ែដែក រ៉ែមាស រ៉ែត្បូង រ៉ែប្រេងកាត។
3. រ៉ែទាំងអស់នោះ មានប្រយោជន៍ទៅតាមប្រភេទរបស់វា ប៉ុន្តែសំខាន់គឺសម្រាប់ទាញយកថវិកាបានយ៉ាងច្រើនមកអភិវឌ្ឍប្រទេសជាតិ។
4. បានជាយើងត្រូវប្រុងប្រយ័ត្នក្នុងការទាញយកធនធានរ៉ែទាំងនោះ ព្រោះក្នុងការទាញយកគោគទ្រព្យធម្មជាតិដ៏មានតម្លៃទាំងនេះ ដោយមិនដឹកយករ៉ែដែលនៅខ្ចី ឬខុសបច្ចេកទេសដែលធ្វើឱ្យហិនហោច ខាតបង់ដល់ប្រទេសជាតិនៅថ្ងៃអនាគតនោះទេ។
5. គេសរសេរព័ត៌មានទាំងនេះ សម្រាប់ប្រជាជនក្នុងប្រទេសជាតិខ្លួន ជាពិសេសប្រជាជនដែលរស់នៅតំបន់មានរ៉ែ ដើម្បីឱ្យប្រជាជនមានមោទនភាពនិងមានទឹកចិត្តស្រឡាញ់ប្រទេសជាតិខ្លួន។

កំណែលំហាត់

លំហាត់ទី1៖

ក. ព័ត៌មាន (ន) ព្រឹត្តិការណ៍ ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន។

ខ. ភូមិសាស្ត្រ (ន) គម្ពីរសម្តែងអំពីផែនដី អំពីភូមិ ប្រទេសផ្សេងៗ។

គ. បច្ចុប្បន្ន (ន) ពេលដែលមាននៅចំពោះមុខ ពេលឥឡូវនេះ។

ឃ. វិនិយោគ (ន) ការដាក់ទុនលើអ្វីមួយដើម្បីចង់បានផលមកវិញ។

ង. អលង្ការ (ន) គ្រឿងប្រដាប់សម្រាប់តុបតែងខ្លួន។

លំហាត់ទី2៖

ក. ស្នេហា ខ. ដំណឹង គ. ពេលឥឡូវនេះ ឃ. ប្រទេសក្រៅ។

លំហាត់ទី3៖

ក. ខេត្តព្រះវិហារ ⇨ រ៉ែមាស

ខ. ខេត្តកំពង់ធំ ⇨ រ៉ែដែក

គ. ខេត្តកោះកុង ⇨ រ៉ែប្រេងកាត

ឃ. ខេត្តប៉ៃលិន ⇨ រ៉ែត្បូង

លំហាត់ទី4៖

ឈ្មោះរ៉ែ	ទីកន្លែងមានរ៉ែ	
	ឈ្មោះភូមិ ស្រុក	ឈ្មោះខេត្ត
១. រ៉ែដែក	ស្រុករវៀង	ព្រះវិហារ
	ភ្នំដី ស្រុកសណ្តាន់	កំពង់ធំ
២. រ៉ែមាស	ស្រុករវៀង ស្រុកអណ្តូងមាស	ព្រះវិហារ - រតនគិរី
	ស្រុកតាវែង ស្រុកថ្មបាំង	កោះកុង
៣. រ៉ែត្បូង	កាទី មេម៉ង់ ស្រុកកែវសីមា	មណ្ឌលគិរី
	ភ្នំយ៉ាត បយ៉ាខា បតាំងស៊ូ	ប៉ៃលិន
	ស្រុកបកែវ ស្រុកកូនមុំ	រតនគិរី
	ស្រុកលំផាត់	

៤. រ៉ែប្រេងកាត	សមុទ្រខ្មែរ	ព្រះសីហនុ-កោះកុង បឹងទន្លេសាប
	បឹងទន្លេសាប	បឹងទន្លេសាប

មេរៀនទី3	**ស្តាប់៖ ត្បូងពណ៌ស្វាយមួយគ្រាប់**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីលក្ខណៈនិងការប្រែប្រួលរបស់ត្បូងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី161ដល់ទី162 រូបភាពទំព័រ161
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ខេត្តរតនគិរីសម្បូរសម្បត្តិធម្មជាតិដ៏មានតម្លៃ។ 2. គេជីកត្បូងពណ៌ស្វាយបាននៅអូរខ្វេះ ឃុំត្រពាំងក្រហម ស្រុកកូនមុំមានទម្ងន់ប្រហែល៥គីឡូក្រាម។ 3. ថ្មកែវណាមហ្វានមានពណ៌ស្វាយល្អណាស់ពេលគេជីកបានពីក្នុងដីភ្លាមៗ។ 4. ប្រធានមន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្តរតនគិរីបានបញ្ជាក់ថាត្បូងពណ៌ស្វាយមួយគ្រាប់នេះ មិនមែនប្រភេទត្បូងធម្មតានោះទេ គឺជាកែវណាម ហ្វានពណ៌ស្វាយ។ កែវណាមហ្វាននេះជាត្បូងប្រភេទខ្ចី។ ថ្មកែវណាមហ្វានមានពណ៌ស្វាយល្អណាស់ ពេលគេជីកបានពីក្នុងដីភ្លាមៗ។ តែក្រោយមកវាប្រែពណ៌រាងស្លេក មិនសូវល្អដូចពេលគេជីកបានភ្លាមទេ។
កំណែលំហាត់	**លំហាត់ទី1៖** (១)ខេត្តរតនគិរី (២)ត្បូងពណ៌ស្វាយ (៣)កែវណាមហ្វាន(៤)ពណ៌ស្វាយ (៥)រាងស្លេក **លំហាត់ទី2៖** ក. ត្បូងប្រភេទខ្ចី ខ. ត្បូងពណ៌ស្វាយមួយគ្រាប់នៅខេត្តរតនគិរី

មេរៀនទី4	**វេយ្យាករណ៍៖ គុណនាមចង្កុល**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់គុណនាមចង្កុលបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី163ដល់ទី164
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. ទាំងនេះ ខ. នេះ គ. ទាំងនោះ ឃ. នោះ ង. នោះ **លំហាត់ទី2៖** ក. នោះ ខ. នេះ គ. នេះ ឃ. ទាំងនោះ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

	តុនេះខ្លីបន្តិច។ ខ្ញុំចង់បានផ្ការុណាបនោះ។ ក្មេងទាំងនេះជាកូនកំព្រា។ ក្រុមនិស្សិតទាំងនោះកំពុងជញ្ជូនកៅអី។

មេរៀនទី5	**អំណាន៖ រ៉ែប្រេងកាត**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីផលប្រយោជន៍របស់រ៉ែប្រេងកាតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី165 ដល់ទី166 រូបភាពទំព័រ165
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រ៉ែប្រេងកាតមាននៅក្នុងដី ក្រោមបាតសមុទ្រ និងក្រោមបាតបឹងទន្លេសាប។ 2. ដើម្បីយកប្រេងកាតឆៅបានគេបុកទម្លុះដីមិនជ្រាបទឹកដោយឆ្លងកាត់ស្រទាប់ដែលមានឧស្ម័ន។ 3. គេទទួលបានប្រេងកាត ប្រេងម៉ាស៊ូត ប្រេងរម្អិល និងកាកសំណល់សម្រាប់ចាក់ក្រាលផ្លូវថ្នល់ពីការចម្រាញ់ប្រេងកាតឆៅ។ 4. ចំពោះសម្បត្តិធម្មជាតិទាំងនេះ កូនខ្មែរគ្រប់រូបចូលរួមថែរក្សាសម្បត្តិធម្មជាតិទាំងក្នុងដី ទាំងក្នុងទឹកឱ្យបានគង់វង្សជារៀងរហូត។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចរចា (កិ) និយាយប្រស្រ័យ សំណេះសំណាលរកគ្នា។ ខ. ឧស្ម័ន (ន) ការៈដែលគ្មានរូប សម្រាប់មនុស្ស សត្វដកដង្ហើម ខ្យល់។ គ. ចម្រាញ់ (កិ) ចំហៀរ រៀងរស់ចម្រាញ់ឱ្យជាច់ទឹក។ ឃ. បារ៉ែល (ន) ឧបករណ៍វាល់ប្រេងមានរង្វាស់ចំណុះចន្លោះពី100លីត្រ ពី200 លីត្រ។ **លំហាត់ទី2៖** ក. ទឹកសាប ≠ ទឹកសាប ខ. ឆាប់រហ័ស ≠ យឺតយ៉ាវ គ. ក្រោមទឹក ≠ លើទឹក ឃ. រីកចម្រើន ≠ អន់ថយ។ **លំហាត់ទី3៖** ក. ប្រេងកាតជារ៉ែមួយប្រភេទដែលមានតម្លៃជាងគេនៅលើពិភពលោក។ ខ. ក្រុនហ៊ុនវិនិយោគទុនជាច្រើនកំពុងចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ឃ. អ្នកស្រាវជ្រាវបានឱ្យដឹងថា ប្រេងកាតនៅប្រទេសកម្ពុជាមានរាប់ពាន់បារ៉ែល។ ង. កូនខ្មែរគ្រប់រូបត្រូវចូលរួមថែរក្សាសម្បត្តិធម្មជាតិឱ្យបានគង់វង្សជារៀងរហូត។ **លំហាត់ទី4៖** បង្ហាញពីទីតាំងនិងសារប្រយោជន៍នៃរ៉ែប្រេងកាតនៅក្នុងប្រទេសកម្ពុជា។

	លំហាត់ទី5៖ - ប្រភេទរ៉ែ ប្រេងកាត - ទីតាំងរ៉ែ ក្នុងដី បាតសមុទ្រ បាតបឹងទន្លេសាប - ផលិតផលប្រេងកាតនៅ ប្រេងយន្តហោះ ប្រេងសាំង ប្រេងកាត ប្រេងម៉ាស៊ូត ប្រេងរម្អិល និងកាកសំណល់សម្រាប់ចាក់ក្រាលផ្លូវថ្នល់ - សារប្រយោជន៍ប្រេងកាត ទាញយកថវិកាជួយដល់សេដ្ឋកិច្ចជាតិ

មេរៀនទី6	**អំណាន៖ រ៉ែមាសនៅកម្ពុជា**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីផលប្រយោជន៍របស់រ៉ែមាសនៅកម្ពុជាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី167ដល់ទី168 រូបភាពទំព័រ167
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. គេរកឃើញរ៉ែមាសមាននៅខេត្តមណ្ឌលគិរី។ 2. ដើម្បីយករ៉ែមាសបាន គេធ្វើគេជីកលុងដីរហូតដល់ប្រទះឃើញស្រទាប់ដីពណ៌លឿងជាខ្សែៗ។ 3. ដើម្បីឱ្យរ៉ែមាសទៅជាមាសសុទ្ធគេយកដីដែលជីកបានទៅរែង រួចយកទៅធ្វើអគ្គិសនីវិភាគ។ 4. រ៉ែមាសផ្តល់ប្រយោជន៍ ដល់ប្រជាជននិងប្រទេសជាតិធំធេងណាស់តាមរយៈការផ្តល់ការងារចិញ្ចឹមជីវិតប្រចាំថ្ងៃដល់ប្រជាជន និងផ្តល់រូបិយបណ្ណសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច។ 5. ការជីកយកមាសជាលក្ខណៈគ្រួសារមិនអាចធ្វើឱ្យសម្បត្តិធម្មជាតិហិនហោចឆាប់រហ័សទេ ព្រោះជាទ្រង់ទ្រាយតូច។
កំណែលំហាត់	**លំហាត់ទី1៖** ក. អគ្គិសនី (ន) ភ្លើង រន្ទះ។ ខ. រូបិយប័ណ្ណ (ន) ក្រដាសតំណាងរូបិយវត្ថុនៃប្រទេសនីមួយៗ។ គ. សេដ្ឋកិច្ច (ន) មុខការដែលមានប្រយោជន៍។ ឃ. អាស៊ីអាគ្នេយ៍ (ន) ឈ្មោះតំបន់មួយក្នុងភូមិភាគអាស៊ី។ **លំហាត់ទី2៖** នេះ ទីនោះ នោះ ទាំងនេះ **លំហាត់ទី3** ក្នុងនាមជាកុលបុត្រកុលធីតា ខ្មែរត្រូវជួយថែរក្សាសម្បត្តិធម្មជាតិទាំងនេះឱ្យបានគង់វង្សយូរអង្វែង ដើម្បីឱ្យប្រទេសជាតិ បានរីកចម្រើនដូចប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍និងប្រទេសជឿនលឿនលើ ពិភពលោក។

មេរៀនទី7	**សំណេរ៖ អត្ថបទព័ត៌មានខ្លី**
រយៈពេល	2ម៉

វត្ថុបំណង	សរសេរអត្ថបទពត៌មានខ្លីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី169ដល់170
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

ជំពូកទី១៤

ប្រយោជន៍នៃធម្មជាតិ

រយៈពេល	14ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ ព្រឹត្តិការណ៍រឿង
មេរៀនទី2	អំណាន៖ រឿង ការភ្ញាក់រលឹករបស់ អ៊ំ សែម
មេរៀនទី3	ស្តាប់៖ រឿង ស្រីកណ្តុរល្អោច
មេរៀនទី4	វេយ្យាករណ៍៖ កិរិយាអកម្ម
មេរៀនទី5	អំណាន៖ យើងរួមគ្នាថែរក្សាបរិស្ថាន
មេរៀនទី6	វេយ្យាករណ៍៖ សញ្ញាផាត់លើ ឬសំយោគសញ្ញា
មេរៀនទី7	និយាយ៖ ការពណ៌នាអំពីប្រយោជន៍នៃព្រៃឈើ
មេរៀនទី8	សំណេរ៖ សំណេររឿងនិទាន

មេរៀនទី1	**បំណិន៖ ព្រឹត្តិការណ៍រឿង**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីកត្តាដែលបំផ្លាញបរិស្ថានធម្មជាតិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី172ដល់ទី173
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់៖** - កូនសេកបាក់ជើងធ្លាក់មុខខ្នមពូត្រីង។ - ពូត្រីងសន្យានឹងមេសេកថា៖ ចាំជើងកូនសេកជានឹងលែងឱ្យជួបនឹងមេវាវិញ។ - ពីរបីថ្ងៃក្រោយមកជើងរបស់កូនសេកបានជាដូចដើម។

មេរៀនទី2	**អំណាន៖ រឿង ការភ្ញាក់រលឹករបស់អ៊ំ សែម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ព្រឹត្តិការណ៍រឿងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី174 ដល់ទី176 រូបភាពទំព័រ174
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. អ៊ំសែមជាក់ស្លាកសញ្ញាដើម្បីលក់ដី។ 2. អ្នកទិញដីមានគម្រោងកាប់ឈើ លុបព្រៃក សង់អគារ និងបង្ហូរកាកសំណល់ចូលទន្លេ។

	3. បានជាអំសែមសម្រេចចិត្តឈប់លក់ ព្រោះកាលណាគាត់លក់ដីនោះមានន័យថាគាត់បានចូលរួមចំណែកក្នុងការបំផ្លាញបរិស្ថានដែរ។ 4. ខ្ញុំចូលចិត្តតួអង្គអំសែម ព្រោះអំសែមជាមនុស្សម្នាក់មានការយល់ដឹងខ្ពស់និងចេះស្រឡាញ់ថែរក្សាបរិស្ថាន។
កំណែលំហាត់	**លំហាត់ទី1៖** ក. កសិករ (ន) អ្នកធ្វើកសិកម្ម។ ខ. អាគារ (ន) មន្ទីរ ផ្ទះ រោង។ គ. បរិសុទ្ធ (គុ) ដែលស្អាត ឥតសៅហ្មង ឥតមោះមៃ។ **លំហាត់ទី2៖** ក. លក់ ≠ ទិញ ខ. ទំនើប ≠ សាមញ្ញ គ. ថយក្រោយ ≠ ទៅមុខ ឃ. ក្តៅ ≠ ត្រជាក់ ង. អង្គុយ ≠ ឈរ ច. ល្អ ≠ អាក្រក់ **លំហាត់ទី3៖** ដ៏ (និ) ដែល ដែលជា។ ដ (ន) ទីចម្លង កំពង់ចម្លង កំពង់ដ។ ដរ (គុ) អំពីរោគដែលរើឡើងដោយប៉ះទង្គិច។ ឧ. ដំបៅដរ ជាដើម។ សួរ (កិ) ពោលពាក្យឆ្ពោះទៅរកអ្នកដទៃឲ្យគេឆ្លើយតប។ ឧ. សួរដំណឹង។ សួ (កិ) ដើរលើស្នួឬលើអ្វីៗដែលមានគ្រឿងតោងផង។ ឧ. សួមែកឈើ។ កំពុង (គុ) ដែលពេញកំពូក កណ្តាលឡើងមិនរាបស្មើ។ ឧ. ពេញកំពុង។ កំពង់ (ន) ទីកន្លែងនៅមាត់ទឹកដែលជនានុជនចុះឡើងឬចតទូកជាដើម។ ឧ. កំពង់ទូក។ **លំហាត់ទី4៖** ក. អ្នកចម្ការ ខ. ឡាន **លំហាត់ទី5៖** ក. ស្រឡាញ់និងថែរក្សាបរិស្ថានធម្មជាតិ ខ. ភ័យខ្លាចបាត់បង់សម្បត្តិធម្មជាតិ **លំហាត់ទី6៖** - អំសែមបោះស្លាកចង់លក់ដី។ - អ្នកទិញដីនោះមានបំណង សង់អគារ កាប់ឈើ បង្ហូរកាកសំណល់ចូលទន្លេ។ - អំសែមសម្រេចមិនលក់ដីនោះវិញ។

មេរៀនទី3	**ស្តាប់៖ រឿង ស្រីកណ្តុរល្អោច**
រយៈពេល	2ម៉ោ
វត្ថុបំណង	ការពារប្រភពដែលផ្តល់ប្រយោជន៍បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី177 ដល់ទី178
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21

ចម្លើយនៃសំណួរ	1. បុរសមានមុខរបរជាអ្នកកាប់ចម្ការ។ 2. ពេលដែលគាត់កាប់ចម្ការដល់ដើមជ្រៃ ស្តេចកណ្តុរសដែលរស់នៅនឹងដើមជ្រៃនោះមានសេចក្តីកិតក័យ ហើយបានអង្វរបុរសដែលកាប់ព្រៃធ្វើចម្ការនោះថា " សុំឱ្យបុរសទុកដើមជ្រៃមួយនេះ ខ្ញុំនឹងឱ្យរង្វាន់ក្នុងមួយថ្ងៃមាស ១ដុំ "។ 3. គាត់យកមាសទៅប្រគល់ឱ្យប្រពន្ធ។ 4. បានជាប្រពន្ធបុរសនោះប្រើប្តីឱ្យកាប់ដើមជ្រៃ ព្រោះប្រពន្ធបុរសនោះជាមនុស្ស លោភលន់ចង់បានហួសហេតុ។ 5. នៅពេលគាត់រំលំដើមជ្រៃ បុរសរកមាសមិនឃើញទេ។ 6. នៅទីបញ្ចប់នៃរឿង ស្តេចកណ្តុរសនាំគ្នា ទៅលួចយកមាសពីផ្ទះបុរសនោះអស់មកវិញ
កំណែលំហាត់	**លំហាត់ទី1៖** ក. លោភលន់ ខ. ចង់ស៊ីកុំតាមឃ្លាន គ. 4. ស្តេចកណ្តុរសនាំគ្នាទៅយកមាសពីផ្ទះបុរសនោះមកវិញអស់។ 2. ស្តេចកណ្តុរសប្រគល់មាសមួយដុំទៅបុរសរាល់ថ្ងៃ។ 1. បុរសជួបស្តេចកណ្តុរសនៅដើមជ្រៃ។ 3. ប្រពន្ធឱ្យប្តីកាប់ដើមជ្រៃដើម្បីយកមាសទាំងអស់។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី3៖** រឿងនេះអប់រំយើងកុំឱ្យមានការលោភលន់ចង់បានហួសហេតុ។ **សុភាសិតមួយឃ្លាបានពោលថា ៖ (ស៊ី កុំតាមឃ្លាន ហ៊ានកុំតាមចង់)**

មេរៀនទី4	**វេយ្យាករណ៍៖ កិរិយាអកម្ម**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់កិរិយាអកម្មបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី179 ដល់ទី180
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. ព្រាបកំពុងហើរ។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី3៖** អង្គុយ និយាយ ឈរ បក់ រត់ ធ្លាក់ គ្រហឹម យំ

មេរៀនទី5	**អំណាន៖ យើងរួមគ្នាថែរក្សាបរិស្ថាន**
រយៈពេល	2ម៉ោ
វត្ថុបំណង	ចូលរួមថែរក្សាបរិស្ថានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី181 ដល់ទី183

	រូបភាពទេសភាពវាលស្រែមានដើមត្នោត
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រដ្ឋានិងឪពុករបស់គេធ្វើដំណើរទៅកសិដ្ឋានរបស់លោកតាគេ។ 2. នៅទីនោះ រដ្ឋាមានគម្រោងនឹងទៅហែលទឹកលេងក្នុងទន្លេដ៏ធំនឹងចាប់ត្រីមួយចំនួន និងឡើងដើមឈើទៀត។ 3. រដ្ឋាវាមិនអាចហែលទឹក មិនអាចជិះទូក ហើយមិនអាចចាប់ត្រីបានទេ ព្រោះទន្លេត្រូវបានបំពុលហើយ វាកខ្វក់ណាស់ ត្រីមិនអាចរស់នៅបានទេ។ 4. ទឹកទន្លេត្រូវបំពុលដោយរោងចក្របានបង្ហូរទឹកកខ្វក់ចូលក្នុងទន្លេ ចំណែកមនុស្សក៏បំពុលទឹកទន្លេ ដោយបោះកាកសំណល់ផ្សេងដែរ។ 5. ដើម្បីថែរក្សាបរិស្ថានធម្មជាតិយើងកុំកាប់បំផ្លាញ នឹងដាំកូនឈើឱ្យបានច្រើននៅតាមកសិដ្ឋាននានា។ 6. បានជាពេលមានទឹកជំនន់ធំនាំឱ្យដីអស់ជីជាតិ ព្រោះគ្មានដើមឈើជួយការពារទឹកជំនន់បណ្តាលឱ្យហូរច្រោះដី។
កំណែលំហាត់	**លំហាត់ទី1៖** ក. រថភ្លើង (ន) រទេះភ្លើង, អាយស្មុយយាន។ ខ. ក្រៀមក្រំ (គុ) ដែលស្រងូតស្រងាត់ ដែលមិនរីករាយ។ គ. បង្ហូរ (កិ) ធ្វើឱ្យហូរ។ ឧ. បង្ហូរទឹក, បង្ហូរទឹកភ្នែក ។ ឃ. កសិដ្ឋាន (ន) ទីកន្លែងបណ្តុះកូនឈើ ឬចិញ្ចឹមសត្វ។ **លំហាត់ទី2៖** ក. សប្បាយចិត្ត ≠ ពិបាកចិត្ត ខ. ល្អ ≠ អាក្រក់ គ. លឿន ≠ យឺត ឃ. កខ្វក់ ≠ ស្អាត ង. ឃូរ ≠ ធាប់ ច. តិចតួច ≠ ច្រើនសន្ធឹក **លំហាត់ទី3៖** ចិត្ត (ន) ធម្មជាតិសម្រាប់សន្សំអារម្មណ៍ , សម្រាប់គិត ។ឧ. ចិត្តត្រង់, ចិត្តល្អ, ចិត្តអាក្រក់ ។ល។ ចិត (កិ) កាត់ជាចំណិត។ ឧ. ចិតបន្លែ។ **លំហាត់ទី4៖** ខ. ត្រូវចូលរួមថែរក្សាបរិស្ថានធម្មជាតិ **លំហាត់ទី5៖** យំ និយាយ ហែល ចូល **លំហាត់ទី6៖** - រដ្ឋានិងឪពុករបស់គេធ្វើដំណើរទៅកសិដ្ឋាន របស់លោកតាគេ។ គេសង្ឃឹមថានឹងបានហែលទឹកលេងក្នុងទន្លេដ៏ធំ ខ្ញុំនឹងចាប់ត្រីមួយចំនួន និងឡើងដើមឈើទៀត"។ - លោកតាបានប្រាប់វាថា៖ "ទន្លេត្រូវបានបំពុលហើយ វាកខ្វក់ណាស់ ត្រីមិនអាចរស់នៅបានទេ" ។

	- រដ្ឋាសួរឪពុកទាំងមិនអស់ចិត្ត៖ "ប៉ា! តើយើងអាចស្តារស្ថានភាពនេះបានឬទេ"?

មេរៀនទី6	**វេយ្យាករណ៍៖ សញ្ញាផាត់លើ ឬសំយោគសញ្ញា**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាផាត់លើ ឬសំយោគសញ្ញាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី184
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. ព័ណ៌ ខ. ន័យ គ. ទំព័រ ឃ. ពាយ័ព្យ ង. ញ័រ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) - គុណប្រកួតបាល់ទាត់ទទួលបានជ័យលាភីលេខ១។ - ប៉ុលពតប្រល័យពូជសាសន៍ឯង។ - យើងមិនត្រូវកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ។

មេរៀនទី7	**និយាយ៖ ការពណ៌នាអំពីប្រយោជន៍នៃព្រៃឈើ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាពីប្រយោជន៍នៃព្រៃឈើបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី185ដល់ទី186
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. សម្បូរនិងសម្បត្តិបាននាំគ្នាទៅកម្សាន្តនៅក្នុងឧទ្យានជាតិមួយ។ 2. ពួកគេបានសន្ទនាគ្នាអំពីប្រយោជន៍នៃព្រៃឈើ។ 3. ដើម្បីឱ្យព្រៃឈើគង់វង្ស យើងត្រូវតែនាំគ្នាជួយថែរក្សា ព្រៃឈើដែលនៅសេសសល់ឱ្យបានគង់វង្សនិងដាំកូនឈើបន្ថែមឱ្យបានច្រើនទៀត។ 4. ព្រៃឈើមានប្រយោជន៍ផ្តល់ ជាជម្រកសត្វព្រៃ ជាគ្រឿងសំណង់និងគ្រឿងប្រើប្រាស់ផ្សេងៗ។ ព្រៃឈើ ផ្តល់អុសជុត ថ្នាំសង្កូវ ចំណីអាហារមនុស្ស សត្វ ឯស្លឹកឈើធ្វើឱ្យដីមានជីជាតិ។ ដើមឈើបញ្ចេញចំហាយទឹក ហើយបង្កើតជាពពកឱ្យមានភ្លៀងទៀងទាត់។ ដើមឈើជួយការពារយើងពីកម្តៅព្រះអាទិត្យនិងស្រូបទឹកភ្លៀង ដែលអាចការពារ កុំឱ្យមាន ទឹកជំនន់លិចលង់ខ្លាំងខុសពីធម្មតា។
កំណែលំហាត់	**លំហាត់ទី1៖** ក. រុក្ខជាតិ ខ. គ្រឿងសំណង់ គ. ចំហាយទឹក ភ្លៀងធ្លាក់ ឃ. កម្តៅ ទឹកភ្លៀង ង. រុក្ខជាតិ ដាំដើមឈើ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)
មេរៀនទី8	**សំណេរ៖ សំណេររឿងនិទាន**
រយៈពេល	2ម៉ោ

វត្ថុបំណង	សរសេររឿងនិទានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី187
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)

ជំពូកទី១៥

ធនធានជលផលនៅកម្ពុជា

រយៈពេល	15ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	បំណិន៖ តម្លៃអប់រំនៃរឿង
មេរៀនទី2	អំណាន៖ រឿង វាសនាបឹងទន្លេសាប
មេរៀនទី3	សំណេរ៖ អត្ថបទពណ៌នា
មេរៀនទី4	ស្តាប់៖ រឿង ដើមកំណើតសត្វផ្សោត
មេរៀនទី5	វេយ្យាករណ៍៖ កិរិយាសកម្ម
មេរៀនទី6	អំណាន៖ រឿង សុបិនចម្លែក
មេរៀនទី7	និយាយ៖ ការរៀបរាប់ពីធនធានជលផល
មេរៀនទី8	សំណេរ៖ ការរៀបរាប់ឡើងវិញព្រឹត្តិការណ៍មួយក្នុងរឿង

មេរៀនទី1	**បំណិន៖ តម្លៃអប់រំនៃរឿង**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីតម្លៃអប់រំនៃរឿងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី189 ដល់ទី190
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ខ. មិនត្រូវជឿគេដោយខ្វះការពិចារណា **លំហាត់ទី2៖** ត្រូវចេះស្តាប់ការទូន្មានរបស់ចាស់ទុំ

មេរៀនទី2	**អំណាន៖ រឿង វាសនាបឹងទន្លេសាប**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីកត្តាដែលធ្វើឱ្យធនធានជលផលកាន់តែវិនាសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី191ដល់ទី193 រូបភាពទំព័រ191
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. គ្រួសារពូប្រាក់រស់នៅក្នុងភូមិឆ្នុកទ្រូ ខេត្តកំពង់ឆ្នាំង។ 2. គ្រួសារពូប្រាក់ប្រកបមុខរបរនេសាទត្រីនិងធ្វើប្រហុក ផ្អក ត្រីងៀត ត្រីឆ្អើរ។ 3. ពូប្រាក់គាត់ភ្ជួញត្បែរប្រាប់ប្រពន្ធដោយអស់សង្ឃឹមម៉ែវាអើយ! ថ្ងៃនេះ ខ្ញុំរកត្រីមិនបានទេយើងប្រហែលជាត្រូវដូរមុខរបរហើយ។

	4. បឹងទន្លេសាបកំពុងទទួលរងគ្រោះធ្ងន់ធ្ងរដោយសារអំពើអគតិរបស់ជនខ្លះ។ ពួកគេបានទៅកាប់បំផ្លាញព្រៃលិចទឹកជុំវិញបឹងដែលជាជម្រកត្រីពង និងបន្តពូជដើម្បី យកដីធ្វើស្រែ។ 5. កត្តាទាំងអស់នេះហើយដែលធ្វើឱ្យមានផលប៉ះពាល់ ដល់ធនធានជលផលរបស់យើងចេះតែខ្សត់ទៅៗ។ 6. យើងទាំងអស់គ្នាត្រូវតែចូលរួមថែរក្សាបឹងទន្លេសាបឱ្យបានល្អដើម្បីឱ្យធនធានជលផលរបស់យើងមានកំណើនកើនឡើងនិងដើម្បីលើកស្ទួយសេចដ្ឋកិច្ចជាតិរបស់យើងឱ្យកាន់តែរីកចម្រើនឡើងថែមទៀត។
កំណែលំហាត់	**លំហាត់ទី1៖** ខ. សេចក្តីវិនាសធំ **លំហាត់ទី2៖** ខ. ការផ្តើមធ្វើ **លំហាត់ទី3៖** គ. ថែរក្សាព្រៃលិចទឹក សម្អាតបរិស្ថានទឹក មិនប្រើឧបករណ៍ឆក់ត្រី **លំហាត់ទី4៖** ក. ការបង្ហូរកាកសំណល់ពីលំនៅឋាននិងរោងសិប្បកម្ម។ ខ. ការហៀរប្រេងចេញពីម៉ាស៊ីនពីកាណូត ឬកប៉ាល់។ ឃ. ការតាំងលំនៅឋានរបស់ប្រជាពលរដ្ឋមួយចំនួន។ **លំហាត់ទី5៖** គ. ការថែរក្សាការពារធនធានជលផលនៅបឹងទន្លេសាប

មេរៀនទី3	**សំណេរ៖ អត្ថបទពណ៌នា**
រយៈពេល	2ម៉
វត្ថុបំណង	សរសេរអត្ថបទពណ៌នាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី194 ដល់ទី196 រូបភាព៖ ត្រីរ៉ស់ ត្រីប៉ាសេអ៊ី
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) ចូរសរសេរអត្ថបទពណ៌នាអំពី "ត្រីរ៉ស់" តាមគម្រោងតែងខាងក្រោម៖ គម្រោងតែង ក. សេចក្តីផ្តើម - ពេលវេលា និងទីកន្លែងចិញ្ចឹម - ឈ្មោះត្រី កន្លែងរស់នៅ ខ. តួសេចក្តី - រូបរាង ពណ៌សម្បុរ ប្រវែង ទម្ងន់ ក្បាល ព្រុយ ស្រកា ស្រកី កន្ទុយ... - ចំណី គ. សេចក្តីបញ្ចប់ ចំណាប់អារម្មណ៍របស់អ្នកសរសេរ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

	សរសេរអត្ថបទពណ៌នាអំពីទីកន្លែងទេសចរណ៍មួយដែលខ្លួនបានស្គាល់។ គម្រោងតែង ១. សេចក្តីផ្តើម - ឈ្មោះរមណីយដ្ឋាន - ទីតាំង ភូមិឃុំ ស្រុក ខេត្ត ២. តួសេចក្តី - ទិដ្ឋភាពដែលយើងមើលឃើញពីចម្ងាយ - ទិដ្ឋភាពដែលយើងមើលឃើញពេលចូលទៅជិត ៣. សេចក្តីបញ្ចប់ - បង្ហាញចំណាប់អារម្មណ៍ ឬផលប្រយោជន៍

មេរៀនទី4	**ស្តាប់៖ រឿង ដើមកំណើតសត្វផ្សោត**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីតម្លៃនៃអន្លង់ត្រីផ្សោតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី197 ដល់ទី198 រូបភាពសត្វផ្សោត
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. នារីម្នាក់ដែលបានមកចាប់បដិសន្ធិចូលចិត្តរាប់អានរុក្ខជាតិ (ដើមពោធិ៍)។ 2. នារីម្នាក់នោះត្រូវជាប្រពន្ធនឹងរុក្ខទេវតាកាលពីអតីតជាតិ។ 3. រុក្ខទេវតាបាននិម្មិតខ្លួនជាសត្វពស់ថ្លាន់ ដើម្បីចូលទៅជួបនាងជាប្រពន្ធ។ 4. ក្រុមគ្រួសាររបស់នាងជាប្រពន្ធមានជីវភាពធូរធារមានរបស់ទ្រព្យសម្បត្តិហូរហៀរឥតខ្វះ។ 5. ប្តីប្រពន្ធនៅភូមិផ្សេងគាត់ដើររកពស់ថ្លាន់ដើម្បីយកមកធ្វើជាកូនប្រសា។ 6. ពស់ថ្លាន់នោះរឹតតែនាងជាប្រពន្ធរួចលេបចូលទៅក្នុងពោះ។ 7. នាងជាប្រពន្ធបានសម្រេចចិត្តទម្លាក់ខ្លួនទាំងចិត្តមួរហ្មង។ 8. នាងជាប្រពន្ធពស់ថ្លាន់បានក្លាយទៅជាសត្វផ្សោត។
កំណែលំហាត់	**លំហាត់ទី1៖** ក. ភាពលោភលន់នាំមកនូវក្តីវិនាសអន្តរាយ ខ. ដើមកំណើតសត្វផ្សោត **លំហាត់ទី2៖** 3. ក 5. ខ 8. គ 2. ឃ 7. ង 9. ច 6. ឆ 4. ជ 1. ឈ

មេរៀនទី5	**វេយ្យាករណ៍៖ កិរិយាសកម្ម**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់កិរិយាសកម្មបានត្រឹមត្រូវ។

សម្ភារៈបង្រៀន	ស.ស. ទំព័រទី199ដល់ទី200
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ខ. ពូសុខជួសជុលឡាន។ គ. អ៊ំឈុំចូលចិត្តក្តាមប្រៃ។ ង. ឡានដឹកអ្នកជំងឺទៅមន្ទីរពេទ្យ។ **លំហាត់ទី2៖** ក. ពិសា ខ. ស្ងួច គ. ជួស ឃ. ទិញ ង. ការពារ ច. ចិញ្ចឹម ឆ. ធ្វើ ជ. អាំង **លំហាត់ទី3៖** ទិញ ស្ងួច លក់ នេសាទ រុត ចាប់ កាប់ ធ្វើ មើល **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង)

មេរៀនទី6	**អំណាន៖ រឿង សុបិនចម្លែក**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីការនេសាទត្រីតាមបែបបទនៃរដូវកាលបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី201 ដល់ទី202 រូបភាពទំព័រ201
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. ស្លេះប្រកបមុខរបរលក់ត្រី។ 2. បានជាស្លេះ សម្រេចចិត្តទៅនេសាទត្រីខ្លួនឯង ព្រោះអ្នកនេសាទចេះតែតម្លើងថ្លៃត្រី ឥតឈប់ឈរ។ 3. ត្រីដែលស្លេះនេសាទបានជាស្តេចត្រី។ 4. បានជាគេមិនឱ្យនេសាទនៅរដូវត្រីពង ព្រោះនាំឱ្យពាយត្រី។ 5. រឿងនេះមានព្រឹត្តិការណ៍៖ ស្លេះបង់សំណាញ់បានត្រីធំមួយ។ ថ្ងៃមួយម៉ារីក្តៅខ្លួន។ ស្លេះភ័យរហូតដឹងខ្លួន។
កំណែលំហាត់	**លំហាត់ទី1៖** ក. នេសាទ (ន) អ្នកសម្លាប់សត្វព្រៃ ឬសត្វទឹក ជារបរចិញ្ចឹមជីវិត។ ខ. បរិភោគ (ន) ការចម្អែតអាត្មា។ គ. អង្វរ (កិ) ពោលពាក្យលំអុតទទូចបន្ទន់ចិត្ត ឱ្យអាណិត, ឱ្យចុះសម្រុង, ឱ្យយល់ព្រម តាមបំណងរបស់ខ្លួន។ **លំហាត់ទី2៖** ក. លំបាក ≠ ស្រណុក ខ. ត្រេកអរ ≠ បារម្ភ គ. ថ្លៃ ≠ ថោក ឃ. ឈឺ ≠ ជា ង. ដំឡើង ≠ ទម្លាក់ ច. ស្លាប់ ≠ រស់ **លំហាត់ទី3៖**

	ក៏ (និ) ពាក្យជាសន្ធានមានសំឡេងកញ្ចក់ខ្លីសម្រាប់និយាយតប្រយោគដោយឡែក។ ឧ. អ្នកក៏ទៅ, ខ្ញុំក៏ទៅ, ធ្វើដូច្នេះក៏បាន, របស់នេះរូបក៏ល្អ តម្លៃក៏ថោក។ ក (ន) អវយវៈដែលតពីក្បាលទៅស្មា ឬទៅខ្លួននៃមនុស្សសត្វ។ ក (កិ) តាំងផ្តើម, តាំងធ្វើ។ ឧ. កសាង, កកើត, កចេតិយ, កភូមិ។ **លំហាត់ទី4៖** ថែរក្សាជលផលធនធានធម្មជាតិ កុំឱ្យនេសាទត្រី នៅរដូវត្រីពងមិនត្រូវប្រើឧបករណ៍នេសាទខុសច្បាប់។

មេរៀនទី7	**និយាយ៖ ការរៀបរាប់ពីធនធានជលផល**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីធនធានជលផលបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី203 រូបភាពទំព័រ203
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. សុធានិងកញ្ញាសន្ទនាគ្នាអំពីធនធានជលផល។ 2. កញ្ញារស់នៅក្នុងខេត្តស្ទឹងត្រែង។ ក្នុងខេត្តរបស់នាងមានធនធានជលផលច្រើនប្រភេទ មានត្រីមានស្រកានិងឥតស្រកា។ 3. សុធារស់នៅក្នុងខេត្តណាព្រះសីហនុ។ ក្នុងខេត្តរបស់សុធាមានធនធានជលផលដូច ជាក្តាម បង្គា មឹក ងាវ ខ្យង គី បបែលនិងត្រីជាច្រើនប្រភេទទៀត។ 4. យើងត្រូវថែរក្សាធនធានជលផល ដោយមិនត្រូវនេសាទត្រីខុសច្បាប់នៅរដូវត្រីពង។
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)

មេរៀនទី8	**សំណេរ៖ ការរៀបរាប់ឡើងវិញព្រឹត្តិការណ៍មួយក្នុងរឿង**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ឡើងវិញព្រឹត្តិការណ៍មួយក្នុងរឿងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី204 ដល់ទី205
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) សរសេរអត្ថបទខ្លីមួយរៀបរាប់អំពីធនធានជលផលនៅក្នុងភូមិ ស្រុក ឬខេត្តរបស់អ្នកដោយ៖ - ប្រាប់ឈ្មោះភូមិស្រុក ឬខេត្តរបស់អ្នក - រៀបរាប់អំពីជលផល ដែលអ្នកបានដឹងនៅក្នុងភូមិ ស្រុកនោះ - ប្រាប់ពីការចូលរួមថែរក្សា ការពារធនធានទាំងនោះមិនឱ្យបាត់បង់ផុតពូជត្រី

ជំពូកទី១៦

ទំនៀមទម្លាប់ប្រពៃណីខ្មែរ

រយៈពេល	9ម៉ោង
	ចំណងជើងសមត្ថភាព
មេរៀនទី1	អំណាន៖ ពិធីបំបួសនាគ
មេរៀនទី2	វេយ្យាករណ៍៖ សញ្ញាវង់ក្រចក (…)
មេរៀនទី3	អំណាន៖ រឿង ទំនៀមទម្លាប់ជាក់ប្រាក់កាក់ក្នុងមាត់អ្នកស្លាប់
មេរៀនទី4	និយាយ៖ ការបញ្ចេញមតិ
មេរៀនទី5	សំណេរ៖ ការពណ៌នាអំពីពិធីផ្សេងៗ

មេរៀនទី1	**អំណាន៖ ពិធីបំបួសនាគ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីពិធីបំបួសនាគបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី207 ដល់ទី208 រូបភាពទំព័រ 207
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. (ចម្លើយជាក់ស្តែង) 2. មុននឹងបួសអ្នកបួសត្រូវរៀនធម៌ឱ្យចេះដឹងជាមុនល្មមអាចសូត្របាននៅថ្ងៃបំបួសនាគ។ 3. ពិធីបំបួសនាគមិនមានការកំណត់ពេលវេលាជាក់លាក់ តែចាំបាច់ត្រូវចៀសវាងពេលដែលព្រះសង្ឃចូលព្រះវស្សា។ 4. គេធ្វើពិធីបំបួសនាគនៅទីវត្តអារាមតែម្តងក៏បាន ឬក៏ធ្វើពីធីចូលរោងនៅផ្ទះពីល្ងាចលុះដល់ព្រឹកថ្ងៃបន្ទាប់គេត្រូវដង្ហែនាគចេញពីផ្ទះទៅកាន់វត្តតែម្តងក៏បាន។ 5. ក្នុងពិធីបំបួសនាគ គេរៀបចំធ្វើបាយសីពីរដើមចេកមួយដើមមាន១៩ថ្នាក់។ នៅលើកំពូលបាយសីនោះ មានកន្ទោងស្លឹកចេកដាក់បាយ១៩ពំនូត។ 6. នាគត្រូវមានសម្លៀកបំពាក់ សំពត់ងូត ហូល និងក្រមាពណ៌ាស។ 7. បានជាខ្មែរយើងនិយមឱ្យកូនបួសជាព្រះសង្ឃ ដើម្បីឱ្យកូនមានការយល់ដឹងផ្លូវលោកផ្លូវធម៌ ហើយចេះតបស្នងសងគុណឪពុកម្តាយ។
កំណែលំហាត់	**លំហាត់ទី1៖** ក. នាគ (គុ. ឬ ន.) ប្រសើរ, ចម្បង, បរិសុទ្ធ ខ. ឧបជ្ឈាយ៍ (ន) គ្រូបង្រៀនធម៌ ឬគ្រូបង្រៀនច្បាប់។ គ. ចីវរ (ន) គ្រឿងស្លៀកដណ្តប់សម្រាប់អ្នកបួសក្នុងពុទ្ធសាសនា

	លំហាត់ទី2៖ សង្ឃ (ន) ពួក, ប្រជុំ, បន, ហ្វូង។ តាមលទ្ធិពុទ្ធសាសនាសំដៅចំពោះអ្នកបួស។ សង់ (កិ) ប្រជុំគ្រឿងទព្វសម្ភារៈធ្វើឱ្យកើតបានជាលំនៅ។ ឧ. សង់ផ្ទះ , សង់សាលា វត្ត (ន) អាវាស ឬអារាមជាទីនៅអាស្រ័យរបស់ពួកសមណៈ។ ឧ. វត្តអារាម វាត់ (កិ) រលាស់ចុងឡើង។ ឧ. វាត់សន្ទូច វែ (កិ) ដួសឆ្នុះខ្លាំងដោយចុងស្នែង។ ឧ. ក្របីវែ ទៀន (ន) គ្រឿងសម្រាប់អុជ ធ្វើដោយក្រមួន ឬខ្លាញ់មានអំបោះជាប្រឆេះ។ ទាន (ន) អំណោយ, ការឱ្យ, អ្វីៗដែលគួរឱ្យ។ ទាន (និ) ពាក្យគោរពសម្រាប់អ្នកតូចនិយាយទៅរកអ្នកធំ។ ឧ. សូមទានមេត្តាប្រោស, សូមទានជ្រាប **លំហាត់ទី3៖** ក. សេះ ឬគោជាជំនិះសម្រាប់នាគ ខ. នាគត្រូវស្លៀកសង្ហប់ចីវរតាមច្បាប់វិន័យ

មេរៀនទី2	**វេយ្យាករណ៍៖ សញ្ញាវង់ក្រចក** (...)
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាវង់ក្រចកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី209 ដល់ទី210
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. មុននឹងសរសេររឿងអ្នកត្រូវកំណត់ (ទីកន្លែងកើតនៅឯណា ?និងពេលវេលារឿងនោះកើតនៅពេលណា ?) ខ. នគរថ្កើនប្លែក សប្បាយតែភ្នែក ក្នុងចិត្តរងកម្ម កូនប្រុសបណ្តាច់ កុំភ្លេចបណ្តាំ កប្បាសសូត្រថ្នាំ ត្រីមុំលែងថោក។ (ក្រមង៉ុយ) គ. នរជនមិនឡើងកាន់សេចក្តីសង្ស័យមើលមិនឃើញសេចក្តីចម្រើនទេ... ។ (ដកស្រង់ចេញពីស្រីហិតោបទេស) ឃ. ខ្ញុំដឹងតែមួយមុខ គឺខ្ញុំគ្មានចេះអ្វីទាំងអស់។ (សូក្រាត) **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី3	**អំណាន៖ រឿង ទំនៀមទម្លាប់ដាក់ប្រាក់កាក់ក្នុងមាត់អ្នកស្លាប់**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទំនៀមទម្លាប់ដាក់ប្រាក់កាក់ក្នុងមាត់អ្នកស្លាប់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី211 ដល់ទី212 រូបភាពទំព័រ211

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រឿងនេះមានតួអង្គ បុរសជាប្តី ប្រពន្ធ ស្តេច។ 2. តួអង្គប្តីស្លាប់មុន។ 3. ប្រពន្ធយកមាសមួយបាតដាក់មាត់សពប្តី។ 4. ប្រាក់ដែលបង់ក្នុងមាត់អ្នកស្លាប់មានអានុភាពទៅលើទឹកចិត្តមនុស្សណាស់សូម្បីព្រះមហាក្សត្រក៏ចុះចាញ់អានុភាពនេះដែរ។ 5. បានជាព្រះមហាក្សត្រឈប់រៃអង្គាសមាស ឬប្រាក់ពីរាស្ត្រ ព្រោះព្រះមហាក្សត្រទ្រង់ស្តាប់រឿងរ៉ាវដែលស្ត្រីជាប្រពន្ធបានរៀបរាប់ដំណើររឿងប្រាប់ហើយក៏កើតក្តីសង្វេគស្តុតព្រះទ័យទើបទ្រង់លើកលែងការរៃយកមាសពីបណ្តារាស្ត្រតទៅទៀត។ 6. ប្រពន្ធតួអង្គអ្នកស្លាប់ បានទូលស្តេចថា៖ "ក្រាបទូលព្រះករុណា! មាសនេះពីដើមពេញមួយបាត តែខ្ញុំម្ចាស់បានយកទៅបង់មាត់ឱ្យប្តីខ្ញុំម្ចាស់នៅពេលគាត់ស្លាប់ក៏ត្រូវភ្លើងឆេះអស់នៅសល់តែប៉ុណ្ណឹង" ។ សូមព្រះករុណាមេត្តាដល់សត្វ ទ័លក្រផងចុះ។ 7. អ្នកប្រាជ្ញបុរាណឱ្យយកប្រាក់ ឬមាសទៅដាក់ក្នុងមាត់ខ្មោច ដើម្បីធ្វើជាប្រស្នាឱ្យពិចារណាថា យើងមិនអាចយករបស់អ្វីមួយជាប់នឹងខ្លួនបានទេនៅពេលដែលយើងស្លាប់ទៅ។
កំណែលំហាត់	**លំហាត់ទី1៖** - ប្រពន្ធ ភរិយា មហេសី - ស្តេច ព្រះករុណា ព្រះមហាក្សត្រ ព្រះរាជា - សព ខ្មោច បុគ្គលស្លាប់ - ព្រះទ័យ ចិត្ត **លំហាត់ទី2៖** បាត (ន) ប៉ែកខាងក្រោមនៃជម្រៅ។ ឧ. បាតបឹង, បាតទន្លេ បាត (ន) ផ្ទៃដៃ ឬជើង ឧ. បាតដៃ បាតជើង។ បាត (ន) គូទ ឧ. ឈឺបាត, ឫសដូងបាត។ បាទ (ន) ជើង។ ឧ. ព្រះបាទ។ បាទ (ន) ឈ្មោះប្រាក់បុរាណតម្លៃ ៦០ សេន។ ឧ. ប្រាក់បាទ បាទ (និ) អើ; ពាក្យសម្រាប់បុរសឆ្លើយ។ ឧ. ឆ្លើយបាទ បាត្រ (ន) ភាជន:ធ្វើដោយដែក ឬដោយដី មានរាងជ្រៅក្រឡូមសម្រាប់។ បព្វជិតក្នុងពុទ្ធសាសនាប្រើការទទួលចង្ហាន់។ ឧ. បាត្រដែក សព (ន) ខ្មោចស្រស់ , រូបបុគ្គលស្លាប់។ ឧ. ធ្វើបុណ្យសព សប់ (កិ) ស្រូបដោយស្នប់, ទាញរុញដៃស្នប់រឿយៗ ឱ្យមានខ្យល់។ ឧ. សប់ទឹក សព្វ (គុ. ឬ កិ. វិ.) ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់។ ឧ. ឃើញសព្វ, ចេះសព្វ, ដឹងសព្វ, សព្វកាល, សព្វគ្នា **លំហាត់ទី3៖** ឧ. នឹងដាក់មាសមួយបាតក្នុងមាត់អ្នកណាដែលស្លាប់មុន។
មេរៀនទី4	**និយាយ៖ ការបញ្ចេញមតិ**
រយៈពេល	2ម៉

វត្ថុបំណង	ប្រើប្រាស់សំនួនរៀហារដើម្បីបញ្ចេញមតិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី213 ដល់ទី214
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. អង្គប្រជុំនេះមានចំនួនមនុស្ស 4នាក់គឺ ប្រធានអង្គប្រជុំ ណារិន ស្រីនាង ណារ៉ុង។ 2. ការប្រជុំនេះពិភាក្សាលើ "ត្រូវប្រកាន់តវិយោបថល្អនៅពេលចូលរួមក្នុងពិធីបុណ្យផ្សេងៗ" 3. ម្នាក់ៗមានតួនាទីបញ្ចេញមតិផ្លាស់ប្តូរយោបល់គ្នានៅពេលប្រជុំ។ 4. សំនួនរៀហារដែលត្រូវប្រើក្នុងការបញ្ចេញមតិមានពាក្យ ទស្សនៈដែលថា ខ្ញុំយល់ថា ទស្សនៈនេះត្រឹមត្រូវណាស់។
កំណែលំហាត់	**លំហាត់ទី1៖** ក. បញ្ចេញមតិ ខ. ជ្រើសរើសប្រធាននិងអ្នកកត់ត្រា **លំហាត់ទី2៖** ក ⇨ បញ្ជាក់ពីគំនិតដែលត្រូវបន្ថែម។ ខ ⇨ បញ្ជាក់ពីមតិស្របៗ គ ⇨ បញ្ជាក់ពីគំនិតស្របទៅនឹងគំនិតខាងលើ។ ឃ ⇨ បញ្ជាក់ពីការយល់ទស្សនៈដែលបានផ្តើម។

មេរៀនទី5	**សំណេរ៖ ការពណ៌នាអំពីពិធីផ្សេងៗ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាអំពីពិធីផ្សេងៗបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី215ដល់ទី217
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖**

លរ	ខ្លឹមសារ	សេចក្តីផ្តើម	តួសេចក្តី	សេចក្តីបញ្ចប់
ក	នៅឯវត្ត ក្រោយប្រគេនភោត្តាហារ នាពេលរសៀល គេបានដង្ហែអង្គកឋិនទានចូលព្រះវិហារ... ។		✓	
ខ	ពេលរសៀលជាថ្ងៃសូត្រមន្ត នៅឯផ្ទះអ្នកផ្តើមបុណ្យមានការទទួលភ្ញៀវដែលអញ្ជើញមកពីគ្រប់ទិសទី។		✓	
គ	មុនថ្ងៃចាប់ផ្តើមពិធីបុណ្យអ្នកផ្តើមបុណ្យបានអញ្ជើញភ្ញៀវជិតឆ្ងាយនិងទិញរណ្តាប់អង្គកឋិនទានមានដូចជា ស្បង់ ចីវរ...។		✓	

ឃ	កឋិនទានជាពិធីបុណ្យបែបសាសនាដែលអ្នកកាន់ព្រះពុទ្ធសាសនាតែងតែប្រារព្ធធ្វើ មានរយៈពេល២៩ថ្ងៃ គឺចាប់ពីថ្ងៃ១រោជខែអស្សុជដល់ថ្ងៃ ១៥កើតខែកត្តិក...។	✓		
ង	ក្នុងព្រះវិហារ គេបានរៀបចំពិធីនមស្ការ សមាទានសីលប្រកាសបច្ច័យ សង្កត់ត្រៃវេរអង្គកឋិនចំពោះព្រះសង្ឃ ។		✓	
ច	ក្នុងពិធីបុណ្យកឋិននេះមានភាពសប្បាយរីករាយណាស់ ដោយមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករនិងបានចូលបច្ច័យ ដើម្បីកសាងព្រះវិហារ។			✓

លំហាត់ទី2៖

កឋិនទានជាពិធីបុណ្យបែបសាសនាដែលអ្នកកាន់ព្រះពុទ្ធសាសនាតែងតែប្រារព្ធធ្វើមានរយៈពេល២៩ថ្ងៃ គឺចាប់ពីថ្ងៃ១រោជខែអស្សុជដល់ថ្ងៃ១៥កើតខែកត្តិក។ មុនថ្ងៃចាប់ផ្តើមពិធីបុណ្យ អ្នកផ្តើមបុណ្យបានអញ្ជើញភ្ញៀវជិតឆ្ងាយនិងទិញរណ្តាប់អង្គកឋិនទានមានដូចជា ស្បង់ ចីវរ...។

ពេលរសៀលជាថ្ងៃសូត្រមន្ត នៅឯផ្ទះអ្នកផ្តើមបុណ្យមានការទទួលភ្ញៀវដែលអញ្ជើញមកពីគ្រប់ទិសទី។ នៅឯវត្ត ក្រោយប្រគេនភោគ្តាហារនាពេលរសៀលគេបានដង្ហែអង្គកឋិនទានចូលព្រះវិហារ... ។ ក្នុងព្រះវិហារ គេបានរៀបចំពិធីនមស្ការ សមាទានសីលប្រកាសបច្ច័យសង្កត់ត្រៃវេរអង្គកឋិនចំពោះព្រះសង្ឃ។

ក្នុងពិធីបុណ្យកឋិននេះ មានភាពសប្បាយរីករាយណាស់ដោយមានពុទ្ធបរិស័ទចូលរួមយ៉ាងច្រើនកុះករនិងបានចូលបច្ច័យ ដើម្បីកសាងព្រះវិហារ។

លំហាត់ទី3៖ (ចម្លើយជាក់ស្តែង)

គម្រោងតែង

១. សេចក្តីផ្តើម

ពេលវេលា ទីកន្លែង ឈ្មោះពិធីបុណ្យ គោលបំណងនៃពិធីបុណ្យ

២. តួសេចក្តី

- មុនពេលចាប់ផ្តើមពិធីបុណ្យ
  - ការអញ្ជើញភ្ញៀវ
  - ការរៀបចំផ្សេងៗ (ការបោសសម្អាត ធ្វើរោង ការតុបតែង)
- ពេលពិធីបុណ្យ
  - ការទទួលភ្ញៀវ
  - ការសូត្រមន្តនិងសម្តែងធម៌ទេសនា
  - ការវេរចង្ហាន់ប្រគេនព្រះសង្ឃនិងបង្សុកូល
- ក្រោយពិធីបុណ្យ

- ការថ្លែងអំណរគុណចំពោះភ្ញៀវ
- ការរៀបចំផ្សេងៗ

៣. សេចក្តីបញ្ចប់

ចំណាប់អារម្មណ៍របស់អ្នកសរសេរចំពោះពិធីបុណ្យ

ជំពូកទី១៧

តន្ត្រីនិងសិល្បៈបុរាណ

រយៈពេល	5ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណានៈ របាំក្ងោក
មេរៀនទី2	វេយ្យាករណ៍ៈ សព្វនាមសំណួរ
មេរៀនទី3	អំណានៈ របាំត្រុដិ

មេរៀនទី1	**អំណានៈ របាំក្ងោក**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីរបាំក្ងោកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី219 ដល់ទី220 រូបភាពរបាំក្ងោក
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. អត្ថបទខាងលើនិយាយអំពីការណែនាំពីរបៀបសម្តែងរបាំក្ងោក។ 2. របាំក្ងោកមានអ្នកសម្តែងពីរនាក់។ ម្នាក់ដើរតួក្ងោកប្រកបដោយសម្លៀកបំពាក់និងពាក់ស្លាបដូចសត្វក្ងោក ហើយម្នាក់ទៀតដើរតួជាព្រានព្រៃ ដែលនៅដៃមានស្នានិងបំពង់ព្លុញព្យុរពីក្រោយខ្នង។ 3. ដើម្បីរាំរបាំក្ងោកអ្នកលេងត្រូវធ្វើតាមការណែនាំដូចតទៅ៖ - ដំបូងអ្នកវាយស្គរចាប់បន្លឺមុនគេរួចវង់ភ្លេងទាំងមូលចាប់ប្រគំព្រមគ្នា។ - បន្ទាប់មកអ្នកដើរតួក្ងោកអង្គុយលុតជង្គង់នៅលើតុមួយខ្ពស់ ដៃទាំងពីរប្រណមទំនងជាកំពុងភាវនាធម៌។ - បន្ទាប់មកទៀតក្ងោកលោតចុះមកដីកាងដៃត្រដាងស្លាបហើយបត់រលាស់មានសណ្ឋានដូចជាក្ងោកហើរដើងទាំងពីរលោតបន្តើរៗជាចង្វាក់រាំឆ្ងែលជុំវិញទីកន្លែង។ 4. ប្រជាជននៅខេត្តប៉ៃលិនដែលនិយមលេងរបាំប្រភេទនេះ។ 5. ប្អូនចូលចិត្តមើលរបាំក្ងោកណាស់ព្រោះរបាំនេះបង្ហាញបីសកម្មភាពរហ័សរហួននិងក្រមិចក្រមើមរបស់សត្វក្ងោក...។
កំណែលំហាត់	**លំហាត់ទី1៖** សម្លៀកបំពាក់ ក្បាលនិងស្លាបសត្វក្ងោក បំពង់ព្លុញ និងស្នា ...។ **លំហាត់ទី2៖** ដើរតួ ពាក់ សម្តែង វាយ រៀបចំ

មេរៀនទី2	**វេយ្យាករណ៍ៈ សព្វនាមសំណួរ**

រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សព្វនាមសំណួរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី221ដល់ទី222
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. អ្នកណា ខ. នរណាខ្លះ គ. អ្វីខ្លះ ឃ. ស្អីខ្លះ **លំហាត់ទី2៖** ក. គោស៊ីស្មៅនៅតាមវាលស្រែ។ ⇨ តើស្អីស៊ីស្មៅនៅតាមវាលស្រែ? ខ. ខ្មែរយើងនិយមឱ្យកូនប្រុសបួសជាព្រះសង្ឃ។ ⇨ តើអ្នកណានិយមឱ្យកូនប្រុសបួសជាព្រះសង្ឃ? គ. ភ្នំនេះមានឈ្មោះថាភ្នំថ្មកំបោរ។ ⇨ តើភ្នំនេះមានឈ្មោះថាភ្នំអ្វី? ឃ. ខ្ញុំជាគ្រូបង្រៀន។ ⇨ តើនរណាជាគ្រូបង្រៀន? ង. អាវនេះជារបស់ខ្ញុំ។ ⇨ តើអាវនេះជារបស់នរណា? **លំហាត់ទី3៖** ក. ស្អី ខ. អ្វី គ. អ្នកណាខ្លះ ឃ. ស្អីខ្លះ ង. អ្នកណាខ្លះ **លំហាត់ទី4៖** សព្វថ្ងៃឯងរៀនអ្វីខ្លះ? តើឯងចង់ញុំាអ្វី? តើអ្នកណារបាសថ្នាក់ថ្ងៃនេះ?

មេរៀនទី3	**អំណាន៖ របាំត្រុដិ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់របាំត្រុដិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី223 ដល់ទី224 រូបភាពទំព័រ223
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. របាំត្រុដិមានប្រភពមកពីជនជាតិសំរែ នៅក្នុងខេត្តសៀមរាប។ 2. គេលេងរបាំត្រុដិនៅពេលចូលឆ្នាំខ្មែរគឺ កាត់ផ្តាច់ឆ្នាំចាស់ឈានចូលឆ្នាំថ្មី។ 3. គេលេងរបាំនេះ ដើម្បីជូនពរសព្វសាធុការ ជ័យមង្គលដល់អ្នកស្រុកក្នុងឱកាសចូលឆ្នាំ

	ថ្មី។ 4. របាំនេះ មានតួសំខាន់ៗមានតួប្រើស ទន្សោង ក្ងោក និងឧបករណ៍ភ្លេងជាច្រើន។ 5. កូនចូលចិត្តមើលការសម្តែងរបាំត្រុដិ ព្រោះរបាំនេះថ្វាយព្រះពរសិរីសួស្តីជ័យមង្គលដល់ព្រះរាជាខ្មែរ ដែលគង់នៅក្រុងអង្គរ។ 6. នៅក្នុងរបាំត្រុដិមានឧបករណ៍តន្ត្រី កញ្ឆារ ចង្រ្កង់ ជំបែរ ចង្រ្កង់រ៉ូង ស្គរ ប៊ីពក ទ្រអ៊ូ ទ្រសោនិងដងសន្ធូច និងគ្រឿងតុបតែងតួមានមុខត្តុក មកុដ ស្នែងប្រើស ស្នែងទន្សោង កន្ទុយក្ងោក ក្រចក។ល។
កំណែលំហាត់	**លំហាត់ទី1៖** ក. ត្រុដិ (ន) ដំណើរកាត់ , ការផ្តាច់។ ខ. ប្រារព្ធ (កិ) តាំងផ្តើម, ផ្តួចផ្តើម , ផ្តងជាមុន។ គ. មង្គល (ន) សេចក្តីសុខចម្រើន។ ឃ. ទន្សោង (ន) ឈ្មោះសត្វជើងបួនពួកគោព្រៃ។ ង. សំរែ (ន) ជាតិមនុស្សអ្នកព្រៃពួកមួយកើតនៅកម្ពុជរដ្ឋ។ **លំហាត់ទី2៖** (១) របាំត្រុដិ (២)ខេត្តសៀមរាប (៣)សត្វព្រៃ (៤)តួ (៥) ប្រើស (៦) ក្បាលប្រើស (៧) ព្រាន

ជំពូកទី១៨

ជំនឿនិងសាសនា

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ កំណាព្យ៖ ព្រះពុទ្ធសាសនា
មេរៀនទី2	ស្តាប់៖ កំណាព្យ៖ អ្នកបួសតាមពុទ្ធសាសនា
មេរៀនទី3	វេយ្យាករណ៍៖ សព្ទនាមចង្អុល
មេរៀនទី4	អំណាន៖ បុណ្យតាមជំនឿព្រះពុទ្ធសាសនា
មេរៀនទី5	សំណេរ៖ ការគោរពសាសនា
មេរៀនទី6	និយាយ៖ ការរៀបរាប់អំពីជំនឿសាសនាផ្សេងៗ

មេរៀនទី1	**អំណាន៖ កំណាព្យ៖ ព្រះពុទ្ធសាសនា**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីសាសនាព្រះពុទ្ធបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី226ដល់ទី227
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. នៅលើលោកយើងនេះមានសាសនាគ្រិស្ត សាសនាអ៊ីស្លាម សាសនាហិណ្ឌូ និងសាសនាព្រះពុទ្ធ។ 2. ប្រទេសកម្ពុជាភាគច្រើនប្រកាន់យកសាសនាព្រះពុទ្ធ។ 3. បានជាយើងមិនត្រូវស្អប់ខ្ពើមសាសនាដ៏ទៃទៀតពីព្រោះសាសនាណាក៏ដោយសុទ្ធតែអប់រំមនុស្សឱ្យប្រព្រឹត្តអំពើល្អជានិច្ច។
កំណែលំហាត់	**លំហាត់ទី1៖** ក. សាសនា (ន) ពាក្យបណ្តាំ, ពាក្យផ្តាំផ្ញើ។ ខ. ទូន្មាន (កិ) ប្រៀនប្រដៅ។ គ. សុចរិត (ន) ការប្រព្រឹត្តល្អ។ ឃ. យាន (ន) គ្រឿងដឹកនាំ, គ្រឿងសម្រាប់ជិះ។ **លំហាត់ទី2៖** - លំនៅ ផ្ទះ សម្បុក វិមាន - រាប់រកយកជាគ្នា ប្រព្រឹត្ត ប្រើប្រាស់ បរិភោគ ធឹក រួមបវេណី - សាង ធ្វើ ស្ថាបនា ក កសាង **លំហាត់ទី3៖**

	សុចរិត ‡ ទុច្ចរិត សុខសាន្ត ‡ ទុក្ខព្រួយ **លំហាត់ទី4៖** ក. សាងអំពើសុចរិត ខ. ការអប់រំតាមពុទ្ធសាសនា

មេរៀនទី2	**ស្តាប់៖ កំណាព្យ៖ អ្នកបួសតាមពុទ្ធសាសនា (បទកាកគតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីវិន័យអ្នកបួសតាមព្រះពុទ្ធសាសនាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី228 ដល់ទី229 រូបភាពទំព័រ228
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ខ្មែរយើងមានជំនឿលើសាសនាព្រះពុទ្ធ។ 2. ខ្មែរយើងឱ្យកូនប្រុសកោរសក់បួស ដើម្បីសងគុណឪពុកម្តាយ។ 3. ដើម្បីរក្សាពុទ្ធសាសនា អ្នកបួសត្រូវប្រតិបត្តិតាមពុទ្ធោវាទឱ្យបានខ្ជាប់ខ្ជួន។
កំណែលំហាត់	**លំហាត់ទី1៖** ខ. ៤ព្យាង្គក្នុង១ឃ្លា **លំហាត់ទី2៖** គ. ៧ឃ្លា **លំហាត់ទី3៖** គ. អ្នកបួសតាមព្រះពុទ្ធសាសនា

មេរៀនទី3	**វេយ្យាករណ៍៖ សព្វនាមចង្អុល**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សព្វនាមចង្អុលបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី230 ដល់ទី231
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. មួយនេះ ខ. មួយនេះ មួយនោះ **លំហាត់ទី2៖** អ្នកនេះ អ្នកនោះ **លំហាត់ទី3៖** ក. មួយនេះ មួយនោះ ខ. នេះ នោះ គ. នោះ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) - សៀវភៅនេះខ្ញុំចូលចិត្តអានវាណាស់ ព្រោះសម្បូរអត្ថបទល្អៗ។ - មាន់មួយសំបុកនេះល្អៗណាស់។ អានេះល្អជាងគេបំផុត។ - ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរសិស្សទាំងអស់នាំគ្នាលេងល្បែងប្រជាប្រិយ។ អ្នកនេះចូលចិត្តលេងលាក់កន្សែង ឯអ្នកនោះចូលចិត្តលេងចោលឈូង។

មេរៀនទី4	**អំណាន៖ បុណ្យតាមជំនឿព្រះពុទ្ធសាសនា (បទព្រហ្មគីតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីប្រភេទបុណ្យតាមជំនឿព្រះពុទ្ធសាសនាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី232ដល់ទី234 រូបភាពទំព័រ232
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. កំណាព្យនេះ និយាយអំពីជំនឿព្រះពុទ្ធសាសនា។ 2. បុណ្យដែលរៀបរាប់នៅក្នុងកំណាព្យខាងលើមានបុណ្យផ្កា បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំ។ 3. ខ្ញុំចូលចិត្តធ្វើបុណ្យទាំងអស់នេះណាស់ ព្រោះធ្វើឱ្យខ្ញុំសប្បាយរីករាយនិងយល់ពីបាបបុណ្យ។ 4. ដើម្បីឱ្យបុណ្យទាំងអស់នេះ នៅមានជារៀងរហូតខ្ញុំត្រូវចូលរួមថែរក្សានិងចងក្រងក្បួនច្បាប់របៀបធ្វើបុណ្យ។
កំណែលំហាត់	**លំហាត់ទី1៖** ក ⇨ ជំនឿ ខ ⇨ សេចក្តីសុខ គ ⇨ ថ្វាយបង្គំ **លំហាត់ទី2៖** ក. វ័យ៖ អាយុ ជន្មវស្សា ខ. សង្ខារ៖ ជីវិត ជន្ម គ. វារី៖ គង្គា ទឹក **លំហាត់ទី3៖** កុសល ± អកុសល **លំហាត់ទី4៖** ចួនក្នុងវគ្គ កម្ពុជា ចួន ប្រជា មន្ត្រី ចួន ស្រី ក្តី សាសនា ចួន ផ្កា សាមគ្គា ចួន វិហារ ទ្វារ ទៀត ចួន ឃ្មាត លៃ ចួន ស្រី ស្តី កុសល ចួន ផល ដូនតា ចួន សង្ខារ លោកា ប្តី ចួន សួស្តី មក ចួន ជម្រក រក

	ទេព្តា ចួន ស្លា វ៉ារី ចួន ភ្ញី វន្ឋីយ៍ ចួនឆ្លងវគ្គ សទ្ធា ចួន សាមគ្គា វិហារ ទ្វារ ចេតិយ ចួន លៃ ស្រី ទ្រឹស្តី សាសនា ចួន ដួនតា សង្ខារ លោកា យក ចួន មក ជម្រក រក ភ្ញី ចួន វ៉ារី វន្ឋីយ៍ **លំហាត់ទី5៖** ក. ប្រមូលបច្ច័យយកទៅកសាងសមិទ្ធិផលនានា ទាំងផ្នែកពុទ្ធចក្រនិងអាណាចក្រ ខ. គោរពវិញ្ញាណក្ខន្ធរបស់បុព្វបុរស ញាតិសន្តានដែលបានទទួលមរណកាលទៅ គ. ទៀន ធូប ផ្កា បាយសី ស្លាធម៌ និងផ្លែឈើ

មេរៀនទី5	**សំណេរ៖ ការគោរពសាសនា**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីការគោរពសាសនាបានត្រឹមត្រូវ។
សម្ភារៈបរទេស	ស.ស. ទំព័រទី235 រូបភាពទំព័រ235
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** (១)លោកា (២)ផ្សេងៗ (៣)យាយី (៤)កម្លាំង (៥)កម្លោច (៦)ចិត្ត **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី6	**និយាយ៖ ការរៀបរាប់អំពីជំនឿសាសនាផ្សេងៗ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីជំនឿសាសនាផ្សេងៗបានត្រឹមត្រូវ។
សម្ភារៈបរទេស	ស.ស. ទំព័រទី236 ដល់ទី237
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ចៅៗសួរជីតាអំពីរឿងសាសនា។ 2. ជនជាតិដទៃដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងមានសិទ្ធិជឿលើជំនឿនិងសាសនាផ្សេងៗបាន ព្រោះជនជាតិដទៃរស់នៅលើទឹកដីកម្ពុជាមានសិទ្ធិពេញលេញក្នុងការជឿជំនឿសាសនារបស់ជនជាតិខ្លួន។ 3. បានជាយើងមិនត្រូវរើសអើងសាសនា ព្រោះប្រជាជនទាំងអស់នឹងរួមរស់ជាមួយគ្នាក្នុងធម៌សាមគ្គីហើយសាមគ្គីធម៌នេះធ្វើឱ្យយើងបានសុខសន្តិភាព។

កំណែលំហាត់	**លំហាត់ទី1៖** ក. សាសនាព្រះពុទ្ធ ខ. ចេះស្រឡាញ់រាប់អានគ្នា **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

ជំពូកទី១៩

រមណីយដ្ឋានទេសចរណ៍នៅកម្ពុជា

រយៈពេល	6ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ អន្លង់ព្រីង
មេរៀនទី2	ស្តាប់៖ ទេសភាពមាត់សមុទ្រ
មេរៀនទី3	អំណាន៖ រឿង បឹងយក្សឡោម

មេរៀនទី1	**អំណាន៖ អន្លង់ព្រីង**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីតំបន់អភិរក្សសត្វក្រៀលអន្លង់ព្រីងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី239 ដល់ទី240 រូបភាពទេសភាពមានសត្វ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. អន្លង់ព្រីងជាតំបន់អភិរក្សសត្វក្រៀល។ ស្ថិតនៅក្នុងឃុំសាលាខាងត្បូង ស្រុកកំពង់ត្រាចខេត្តកំពត។ កើតនៅឆ្នាំ2004។ 2. ក្រៀលជាប្រភេទសត្វកម្រនិងជិតផុតពូជនៅលើភពផែនដី។ 3. សត្វក្រៀលរស់នៅតំបន់អន្លង់ព្រីងនៅរដូវប្រាំង។ 4. ដើម្បីចូលរួមថែរក្សាពូជសត្វដ៏កម្រនេះ យើងមិនត្រូវបរបាញ់និងមិនបំផ្លាញព្រៃដែលជាជម្រករបស់សត្វ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ល្ហល្លៃ ⇨ វាលធំគ្មានអ្វីទើស ខ. ដ្ឋេបាលព្រៃឈើ ⇨ អ្នករក្សាព្រៃឈើ គ. អភិរក្ស ⇨ រក្សាដោយប្រុងប្រយ័ត្ន **លំហាត់ទី2៖** ពី (និ) អំពី; ខាង, ឯ។ ឧ. មកពីណា? ពីរ (ប. សំ.) មួយគួបគ្នា គឺមួយនិងមួយ (២)។

មេរៀនទី2	**ស្តាប់៖ ទេសភាពមាត់សមុទ្រ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីទេសភាពមាត់សមុទ្របានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី241 រូបភាព៖ ទេសភាពមាត់សមុទ្រ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. មាត់សមុទ្រ ឬឆ្នេរសមុទ្រជារមណីយដ្ឋានប្រភេទធម្មជាតិ។ 2. មនុស្សគ្រប់វ័យចូលចិត្តទៅកម្សាន្តនៅមាត់សមុទ្រ។ 3. បានជាគេចូលចិត្តទៅកម្សាន្តនៅមាត់សមុទ្រ ព្រោះនៅទីនោះមានខ្យល់អាកាសល្អ បរិសុទ្ធនិងបានងូតទឹកកម្សាន្ត។
កំណែលំហាត់	**លំហាត់ទី1៖** គ. ស្រូបយកខ្យល់បរិសុទ្ធដែលបក់ពីលំហសមុទ្រ **លំហាត់ទី2៖** គ. ខ្សាច់ម៉ដ្ឋសក្បុស សម្បកលៀស គ្រំ ខ្វៅ ខ្សង... **លំហាត់ទី3៖** ក. ដើរកម្សាន្តនៅលើវាលខ្សាច់និងមុជទឹកលេងជាមួយក្រុមគ្រួសារ

មេរៀនទី3	**អំណាន៖ រឿង បឹងយក្សឡោម**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីប្រវត្តិបឹងយក្សឡោមបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី242ដល់ទី243 រូបភាពបឹងយក្សាឡោម
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. បឹងយក្សឡោមស្ថិតនៅក្នុងខេត្តរតនគិរី។ 2. បឹងនេះមានប្រវត្តិ កាលពីយូរលង់ណាស់មក ហើយមានស្តេចយក្សមួយអង្គមានឫទ្ធិអំណាចខ្លាំងពូកែណាស់។ ព្រះអង្គមានបុត្រីមួយ ដែលមានរូបស្អាតនិងមានសក់ក្រអូប។ ព្រះអង្គឱ្យឈ្មោះថា **"នាងសក់ក្រអូប"។** លុះដល់ព្រះនាងធំពេញវ័យ មានមនុស្សម្នាក់ខ្លាំងពូកែ បានចូលទៅលបលួច ស្នេហាជាមួយព្រះនាង។ ដោយភ័យខ្លាចបិតាដឹង អ្នកទាំងពីរបាននាំគ្នារត់ចូលព្រៃមួយ។ ក្រោយមក ស្តេចយក្សបានដឹងរឿងរ៉ាវនេះ ក៏ផ្តើលធោឡោកេណ្ឌពលយក្សទៅតាមរកបុត្រី។ លុះដល់ព្រៃស្តុកមួយ ស្តេចយក្សសង្ស័យថា ប្រហែលបុត្រីខ្លួននៅជិតនោះ ទើបបញ្ជាឱ្យបរិវារមួយក្រុមយាមល្បាតហ៊ុមព័ទ្ធព្រៃនោះយ៉ាងមាំ ហើយមួយក្រុមទៀតជកព្រៃព្រឹក្សាគ្រវែងចោលនិងជីក កកាយរកនាង។ ទោះបីពួកយក្សប្រឹងជីកយ៉ាងណាក្តី ក៏នៅតែរកពុំឃើញ ទើបស្តេចក្រុងយក្សត្រឡប់ទៅវិញ។ អាស្រ័យដោយពួកយក្សកកាយរកនាងសក់ក្រអូប ទើបទីនោះក្លាយជាស្រះមួយនៅក្នុងតំបន់ ឡាបានសៀក ស្រុកលំផាត់ ខេត្តរតនគិរី ដែលគេហៅថា **"ស្រះយក្សឡោម"** រហូតមកដល់សព្វថ្ងៃ។ 3. បឹងនេះមានរាងរង្វង់មូលស្មើ មានជម្រៅ70ម៉ែត្រ។ 4. តាមយោបល់របស់ខ្ញុំ បឹងយក្សឡោមជាបឹងធម្មជាតិ។ 5. ខ្ញុំស្រឡាញ់បឹងយក្សឡោមណាស់។
កំណែលំហាត់	**លំហាត់ទី1៖**

ក. ទីនោះជារមណីយដ្ឋានមួយដ៏ល្អ នៅក្នុងភូមិភាគឦសាន

ខ.

- ការចាកចេញចោលនគររបស់បុត្រីយក្ស **"នាងសក់ក្រអូប"**
- ស្តេចយក្សនិងបរិវារដកព្រៃគ្រវែងចោល និងដីកដីរកបុត្រីសក់ក្រអូប
- កន្លែងដែលយក្សកកាយរកនាងសក់ក្រអូបបានក្លាយជាស្រះ១យ៉ាងធំ

លំហាត់ទី2៖ ក. កូន ខ. ត្រី គ. ឪពុក

ជំពូកទី២០

សេចក្តីថ្លៃថ្នូរ

រយៈពេល	14ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី1	អំណាន៖ រឿង ក្តីស្រមៃ
មេរៀនទី2	សំណេរ៖ ពណ៌នាអំពីមនុស្សល្អ
មេរៀនទី3	វេយ្យាករណ៍៖ សព្វនាមឈ្នាប់
មេរៀនទី4	អំណាន៖ កំណាព្យ៖ បុត្រល្អ
មេរៀនទី5	សំណេរ៖ ពណ៌នាអំពីលំនៅឋាន
មេរៀនទី6	អំណាន៖ សេចក្តីថ្លៃថ្នូររបស់មនុស្ស
មេរៀនទី7	និយាយ៖ ការរៀបរាប់ពីមនុស្សថ្លៃថ្នូរ
មេរៀនទី8	អំណាន៖ រឿង បុរសចិត្តធម៌

មេរៀនទី1	**អំណាន៖ រឿង ក្តីស្រមៃ**
រយៈពេល	2ម៉ោ
វត្ថុបំណង	កំណត់គោលដៅនៃជីវិតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី245 ដល់ទី246
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រឿងនេះមានតួអង្គស៊ីថានិងសុភាព។ 2. សុភាពជាមនុស្សពិការជើង។ 3. សុភាពមានបំណងរៀនកាច់ផ្តាលក់។ 4. សុភាពអាចសម្រេចបំណងរបស់ខ្លួនបានដោយសារការខិតខំប្រឹងប្រែង។ 5. (ចម្លើយជាក់ស្តែង)។
កំណែលំហាត់	**លំហាត់ទី1៖** - ផ្ទះ លំនៅឋាន ជម្រក ភូមិគ្រឹះ - អាជីព មុខរបរ អាជីវកម្ម - សិក្សា រៀនសូត្រ ហ្វឹកហាត់ ស្វាធ្យាយ - ផ្តាំ បុប្ផា **លំហាត់ទី2៖** ក. សប្បាយ ⇨ កើតទុក្ខ ខ. ប្រឹងប្រែង ⇨ ទម្រន់ គ. ទំនេរ ⇨ រវល់ ឃ. អនាគត ⇨ អតីតកាល ង. បន្ថែម ⇨ បន្ថយ

	លំហាត់ទី3៖ ក. ការ កិ. ⇨ មូរសរសៃសូត្រ។ ខ. ចិត្ត ន. ⇨ ធម្មជាតិសម្រាប់សន្សំអារម្មណ៍។ គ. ទុក្ខ ន. ⇨ សេចក្តីព្រួយ។ ឃ. កាណ៌ ន. ⇨ ត្រចៀក។ ង. ចិត កិ. ⇨ កាត់ជាចំណិតៗ។ ច. ទុក កិ. ⇨ ដាក់វត្ថុអ្វីក្នុងទីណាមួយឱ្យគង់នៅ។ **លំហាត់ទី4៖** ក. ជោគជ័យ ខ. បុគ្គលគ្រប់រូបត្រូវខិតខំរៀបចំខ្សែជីវិតដោយខ្លួនឯងមុននឹងឱ្យអ្នកដ៏ទៃជួយ។

មេរៀនទី2	**សំណេរ៖ ពណ៌នាអំពីមនុស្សល្អ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាអំពីមនុស្សល្អបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី247 ដល់ទី248
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) ចូរពណ៌នាពីមនុស្សណាម្នាក់ ដែលអ្នកយល់ថា ជាមនុស្សល្អ។ **គម្រោងតែង** **១. សេចក្តីផ្តើម** - ឈ្មោះ អាយុ មុខរបរ (មន្ត្រី កម្មករ កសិករ) - ទីកន្លែងរស់នៅ (ភូមិ ឃុំ ជនបទ ទីក្រុង) **២. តួសេចក្តី** - រូបសម្បត្តិ៖ រូបរាង សម្បុរ... - ចរិយាសម្បត្តិ៖ ស្លូត ព្យាយាម យោគយល់ អធ្យាស្រ័យ - សកម្មភាព៖ ទំនាក់ទំនងល្អ (មិនរើសអើង...) - អំពើសប្បុរស (ជួយគ្នាទៅវិញទៅមកធ្វើអំណោយ) - សេចក្តីក្លាហាន (ហ៊ានទទួលខុសត្រូវ ជំនះឧបសគ្គធ្វើជាគំរូ) - ការគោរព (ឪពុកម្តាយ អ្នកជិតខាង ស្តាប់ ដំបូន្មាន...)។ **៣. សេចក្តីបញ្ចប់** ចំណាប់អារម្មណ៍របស់អ្នកផ្ទាល់។

មេរៀនទី3	**វេយ្យាករណ៍៖ សព្វនាមឈ្មោះ**
រយៈពេល	1ម៉ោ
វត្ថុបំណង	ប្រើប្រាស់សព្វនាមឈ្មោះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី249ដល់ទី250

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ18
កំណែលំហាត់	**លំហាត់ទី1៖** ក. មនុស្ស ខ. គាត់ គ. សៀវភៅ **លំហាត់ទី2៖** ក. ខ្ញុំយកតម្រាប់តាមសុភាព ដែលជាសិស្សឧស្សាហ៍រៀនសូត្រជាងគេ។ ខ. យើងថែរក្សាប្រាសាទបុរាណ ដែលជាមរតកជាតិយើង។ **លំហាត់ទី3៖** ក. គាត់ជាសប្បុរសជន។ សប្បុរសជន ជួយសង់អគារសិក្សាឱ្យយើង។ ខ. យើងគោរពស្រឡាញ់ពូសុខ។ គាត់ជាមនុស្សថ្លៃថ្នូរ។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) - ខ្ញុំស្រឡាញ់មនុស្សស្មោះត្រង់ដែលនាំខ្ញុំឱ្យប្រព្រឹត្តអំពើល្អ។ - ប្រទេសកម្ពុជាសម្បូរសម្បត្តិធម្មជាតិដែលមានប្រយោជន៍ដ៏សំខាន់សម្រាប់មនុស្ស។ - សុភាពចូលចិត្តអានប្រលោមលោកដែលបង្ហាញពីមនោសញ្ចេតនា។

មេរៀនទី4	**អំណាន៖ កំណាព្យ៖ បុត្រល្អ (បទពំនោល)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីបុត្រល្អបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី251 ដល់ទី252 រូបភាពទំព័រ251
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ20
ចម្លើយនៃសំណួរ	1. កូនល្អត្រូវមានចិត្តស្មោះត្រង់ស្រឡាញ់ឪពុកម្តាយ គោរពចាស់ទុំ ខិតខំរៀនសូត្រនិងជួយធ្វើការងារផ្ទះ។ 2. គេប្រៀបធៀបកូនល្អទៅនឹងក្បួន។ 3. កំណាព្យនេះនិយាយពីអាកប្បកិរិយានិងសកម្មភាពរបស់បុត្រល្អ។
កំណែលំហាត់	**លំហាត់ទី1៖** - មាតា ម្តាយ ម៉ែ ម៉ាក់ មេ - សូត្រ ទន្ទេញ ចាំមាត់ - បុត្រ កូន កុលបុត្រ កុលធីតា **លំហាត់ទី2៖** ទុំ (គុ) ដែលទីទៃពីខ្ចីពីចាស់ ដែលដល់កម្រិតជិតជ្រុះពីមែក ឬពីទង។ ឧ. ចេកទុំ។ ទំ (កិ) បិតលើទ្រនំ។ ឧ. ព្រាបទំលើដំបូលព្រះវិហារ។ ចិត្ត (ន) ធម្មជាតិសម្រាប់សន្សំអារម្មណ៍,សម្រាប់គិតគឺវិញ្ញាណ។ ឧ. សប្បាយចិត្ត។ ចិត (កិ) កាត់ជាចំណិត។ ឧ. ចិតបន្លែ។ ទុក្ខ (ន) សេចក្តីព្រួយ, សេចក្តីលំបាក។ ឧ. កើតទុក្ខ។ ទុក (កិ) ដាក់វត្ថុអ្វីក្នុងទីណាមួយដើម្បីឱ្យគង់នៅ ឬរក្សាអ្វីឱ្យគង់។ ឧ. ទុកទ្រព្យ។ **លំហាត់ទី3៖** ពាក្យចួនក្នុងវគ្គ

	ល្អ ចួន សរ រក្សា ចួន ណា ទុំ ចួន ទម្ង វៃ ចួន ជ័យ រសោយ ចួន ម្តាយ ក្មួន ចួន ប្អូន ពាក្យចួនឆ្លងវគ្គ បិតា ចួន រក្សា ចួន ណា រំ ចួន ទុំ ចួន ទម្ង ប្រពៃ ចួន វៃ ចួន ជ័យ សប្បាយ ចួន រសោយ ចួន ម្តាយ កូន ចួន ក្មួន ចួន ប្អូន

មេរៀនទី5	**សំណេរ៖ ពណ៌នាអំពីលំនៅឋាន**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាអំពីលំនៅឋានបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី253ដល់ទំព័រ254 រូបភាពផ្ទះ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) ក. សេចក្តីផ្តើម ទីកន្លែង (ភូមិ ស្រុក ខេត្ត ផ្លូវ) ខ. តួសេចក្តី - ទិដ្ឋភាពមើលពីចម្ងាយ (រូបរាង ពណ៌ សម្បុរ ទាប ខ្ពស់) - ទិដ្ឋភាពចូលទៅជិត (សួនច្បារ សួនផ្កា រុក្ខជាតិហូបផ្លែ សោភ័ណភាព) - ទិដ្ឋភាពខាងក្រៅ (លក្ខណៈសំណង់ បុរាណ សម័យ របង វានហាល) - ទិដ្ឋភាពខាងក្នុង (ល្វែង បន្ទប់ទទួលភ្ញៀវ បន្ទប់គេង តុ ទូ គ្រែ...) - ការរៀបចំតុបតែង (វត្ថុតាំងលម្អ វត្ថុប្រើប្រាស់តាមបន្ទប់ របៀបរៀបរយ) - សារប្រយោជន៍ (ផ្តល់ជម្រក...) គ. សេចក្តីបញ្ចប់ ចំណាប់អារម្មណ៍របស់អ្នកសរសេរ (សប្បាយ ចូលចិត្ត ពេញចិត្ត ស្អប់ មិនពេញចិត្ត អាកប្បកិរិយា) **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី6	**អំណាន៖ សេចក្តីថ្លៃថ្នូររបស់មនុស្ស**
រយៈពេល	2ម៉ោ

វត្ថុបំណង	រៀបរាប់ពីលក្ខណៈសម្បត្តិរបស់មនុស្សថ្លៃថ្នូរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី255 ដល់ទី256
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. សេចក្តីថ្លៃថ្នូររបស់មនុស្សជាគុណសម្បត្តិមួយដ៏ប្រសើរថ្លៃថ្លា។ 2. មនុស្សមានសេចក្តីថ្លៃថ្នូរ ជាមនុស្សមានភាពស្មោះត្រង់ ប្រកាន់សច្ចៈ យុត្តិធម៌ មានវិន័យ សីលធម៌ និងមានមនសិការវិជ្ជាជីវៈ។ 3. មនុស្សត្រូវការសេចក្តីថ្លៃថ្នូរ ព្រោះសេចក្តីថ្លៃថ្នូរធ្វើឱ្យមនុស្ស ទទួលបាននូវកេរ្តិ៍ឈ្មោះល្អ មានកិត្តិយសប្តុំប្តើង រស់នៅសុខសាន្ត និងប្រៀបដូចជាគ្រឿងអលង្ការធ្វើឱ្យមនុស្សមានសោភ័ណ។ 4. បានជាមនុស្សមានចំណេះវិជ្ជាមានសេចក្តីថ្លៃថ្នូរ ព្រោះចំណេះវិជ្ជាធ្វើឱ្យមនុស្សចេះគិតពិចារណា ស្គាល់អំពើល្អ អាក្រក់ និងធ្វើអ្វីគួរធ្វើ អ្វីមិនគួរធ្វើ។ 5. (ចម្លើយជាក់ស្តែង)
កំណែលំហាត់	**លំហាត់ទី1៖** សោភ័ណ សម្រស់ សម្ផស្ស ផ្លូវ វិថី មាគ៌ា គន្លង បរិភោគ ស៊ី ហូប ញ៉ាំ ឆាន់ សោយ អាស្រ័យ ទទួលទាន **លំហាត់ទី2៖** សុភមង្គល ≠ អពមង្គល វិជ្ជា ≠ អវិជ្ជា សីលធម៌ ≠ អសីលធម៌ ថ្លៃថ្នូរ ≠ ថោកទាប ក្រអូប ≠ ស្អុយ គុណ ≠ ទោស **លំហាត់ទី3៖** ក. កេរ្តិ៍ ⇨ សេចក្តីសរសើរ ការល្បីលេចឮ។ ខ. សុក ⇨ អាការៈមួយប្រភេទជាស្រោមស្រោបកូនដែលនៅក្នុងផ្ទៃ។ គ. វារ ⇨ លូនដោយប្រវា។ ឃ. បត់ ⇨ ត្រឡប់តាមផ្លូវដែលមកវិញ។ ង. សុខ ⇨ ដែលសប្បាយ។ ច. វៀរ ⇨ លើកលែង ឈប់ខាន។ ឆ. កេរ ⇨ ដំណែលជាសម្បត្តិរបស់ជូនតា ឬមាតាបិតា។ ជ. វា ⇨ ពាក្យសម្រាប់និយាយជាជំនួសឈ្មោះមនុស្សក្មេងជាង ឬជំនួសសត្វ វត្ថុ។ ឈ. បទ ⇨ លំនាំនៃសំឡេងដែលសូត្រ ឬច្រៀង។ ញ. សុក្រ ⇨ ឈ្មោះថ្ងៃទី៦។ **លំហាត់ទី4៖** ខ. ឧស្សាហ៍ព្យាយាមរៀនសូត្រ

	ច. ជួយជនរងគ្រោះដោយសេចក្តីជ្រះថ្លា ឆ. គោរពសិទ្ធិមនុស្ស

មេរៀនទី7	**និយាយ៖ ការរៀបរាប់ពីមនុស្សថ្លៃថ្នូរ**
រយៈពេល	1ម៉ោ
វត្ថុបំណង	រៀបរាប់ពីលក្ខណៈសម្បត្តិរបស់មនុស្សថ្លៃថ្នូរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី257
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. មករាននិងសារិននិយាយគ្នាពីគ្រូពេទ្យដូង។ 2. ពូដូងមានមាឌធំល្មម សម្បុរសណ្តែកបាយ ហើយមានទឹកមុខញញឹម ស្លូតបូត រាក់ទាក់ និងមិនរើសអើង។ 3. ពូដូងជាមនុស្សថ្លៃថ្នូរ ព្រោះគាត់មានចំណេះ ចេះជួយទុក្ខធុរៈអ្នកដទៃនិងមិនរើសអើង។
កំណែលំហាត់	**លំហាត់ទី1៖** មានចរិតស្លូតបូត មុខញញឹម រាក់ទាក់មិនរើសអើង **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី8	**អំណាន៖ រឿង បុរសចិត្តធម៌**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រកាន់ឥរិយាបថជាមនុស្សថ្លៃថ្នូរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី258 ដល់ទី259 រូបភាពទំព័រ258
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ19
ចម្លើយនៃសំណួរ	1. រឿងដែលកើតឡើងចំពោះសេដ្ឋីគឺ ចោរមួយក្រុមបានវាយដំរហូតដល់សេដ្ឋីសន្លប់បាត់ស្មារតីហើយយកមាសប្រាក់រួចរត់គេចខ្លួនបាត់ទៅ។ 2. មនុស្សទី១ជាស្ត្រីចំណាស់ គាត់មិនបានជួយសេដ្ឋីទេ ព្រោះគាត់ចាស់កម្លាំងខ្សោយ។ 3. អ្នកដែលបានជួយសេដ្ឋីគឺ បុរសកម្សត់ម្នាក់។ 4. ប្រសិនបើខ្ញុំជួបរឿងបែបនេះ ខ្ញុំត្រូវជួយជនរងគ្រោះឱ្យផុតពីគ្រោះថ្នាក់ 5. បុរសកម្សត់ជាមនុស្សមានចិត្តធម៌។
កំណែលំហាត់	**លំហាត់ទី1៖** ក. អ្នកមានស្តុកស្តម្ភ ខ. មនុស្សប្រុស **លំហាត់ទី2៖** ក៏ (និ) ពាក្យមានសំឡេងកញ្ឆក់ខ្លីសម្រាប់សម្រាប់និយាយតបប្រយោគដោយឡែក។ ក (ន) អវយវៈតពីក្បាលទៅស្មា ឬទៅខ្លួននៃមនុស្សសត្វ។ ក (កិ) តាំងផ្តើម តាំងធ្វើ។ **លំហាត់ទី3៖**

នាម	គុណនាម	កិរិយាសព្ទ	សព្វនាម
សេដ្ឋី បុណ្យ	កម្សត់ ខ្លាំង ចាស់	ដណ្តើម បរ គ្រាហ៍	គេ គាត់

	ពីរ នោះ	ថ្លៃង ដើរ	

លំហាត់ទី4៖ (ចម្លើយជាក់ស្តែង)

លំហាត់ទី5៖

- ឃើញដូច្នោះ គាត់ក៏ប្រញាប់ជួយគ្រាហ៍សេដ្ឋីនោះយកទៅដាក់ក្នុងខ្ទមរបស់ស្ត្រីម្នាក់ដែលនៅមិនឆ្ងាយប៉ុន្មានពីទីនេះ។
- ស្ត្រីនោះបានប្រាប់គាត់ថា «អ្នកដែលបានជួយលោកនោះមិនមែនខ្ញុំទេ គឺជាបុរសកម្សត់ម្នាក់។

ក្រសួងអប់រំ យុវជន និងកីឡា

និង

អង្គការដើម្បីភាពញញឹមនៃកុមារ





សូមថ្លែងអំណរគុណ

ចំពោះអ្នកខ្ចប់ត្តម្ភថវិកាដល់ដំណើរការគម្រោងចងក្រង និងបោះពុម្ពស្បៀវភៅពន្លឿនការសិក្សាដូចជា ៖













រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៦៥៖ *រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាដំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់លើវិស័យអប់រំកាយនិងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។*

មាត្រា៦៦៖ *រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។*

មាត្រា៦៧៖ *រដ្ឋអនុវត្តកម្មវិធីសិក្សានិងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យានិងភាសាបរទេស។ រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សានិងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា។*

មាត្រា៦៨៖ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតមានបង់ថ្លៃយ៉ាងតិច ៩ឆ្នាំ។

ច្បាប់ស្តីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣១៖ *ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩(ប្រាំបួន)ឆ្នាំប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងវិធានការជាដំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ។*

ការអប់រំសម្រាប់ទាំងអស់គ្នា!

ទាំងអស់គ្នាសម្រាប់ការអប់រំ!